ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ មជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ប្រចាំនៅអាស៊ីអាគ្នេយ៍

◆ ជនរងគ្រោះនៅតែរង់ចាំចម្លើយពីអង្គជំនុំជម្រះវិសាមញ្ញ៖ ចម្លើយនឹងត្រូវផ្ដល់ជូន

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ៩៩ ខែមីនា ឆ្នាំ២០០៨

# ស្វែងរកការពិត

លេខ៩៩ ខែមីនា ឆ្នាំ២០០៨


## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


◆ សំបុត្រ ៖ មជ្ឈមណ្ឌលស្រាវជ្រាវប្រចាំនៅអាស៊ីអាគ្នេយ៍ ....................១

**ផ្នែកឯកសារ**

◆ ឌឹម សារឿន ហៅ ម៉េន....................................................៥

◆ នារីក្នុងជួរបដិវត្តន៍........................................................៦

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ គុកខ្មែរក្រហម.............................................................១០

◆ ជួបជាមួយជនរងគ្រោះនៅខេត្តកំពត.....................................១៤

◆ ចាន់ រ៉ាយៈ មិនចង់ចងពៀរ ប៉ុន្តែចង់បានយុត្តិធម៌ ..........................១៧

◆ ជនរងគ្រោះស្វែងរកចម្លើយពីការកាត់ទោស.................................២១

◆ កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម...............................២៤

◆ កុលសម្ព័ន្ធស្មៀងក្រោមរបបខ្មែរក្រហម ......................................២៦

**ផ្នែកច្បាប់**

◆ សេចក្តីជូនដំណឹងរបស់អង្គជំនុំជម្រះវិសាមញ្ញ .............................៣១

◆ ក្រមសីលធម៌ចៅក្រម.......................................................៣២

◆ សេចក្តីជូនដំណឹងអំពីការដាក់សារណា .......................................៣៦

◆ គណៈកម្មាធិការប្រព្រឹត្តិកម្ម-សមាគមការពារសិទ្ធិមនុស្ស...............៤០

◆ ជនរងគ្រោះនៅតែទន្ទឹងរង់ចាំចម្លើយពីអង្គជំនុំជម្រះវិសាមញ្ញ .........៤១

**វេទិកាពិភាក្សាសាធារណៈ**

◆ ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ ....................................៤៤

◆ បញ្ហានៃការធ្វើបណ្តឹងឧទ្ធរណ៍ដោយ អៀង សារី ..........................៥០

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ជីវិតពិតឆ្លងកាត់របបខ្មែរក្រហម ..............................................៥៦

◆ដំណើរជីវិតក្នុងរបបវាលពិឃាដ ....................................ក្របខាងក្នុង






## រក្សាសិទ្ធិ


មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ ០២៩១ពម/៩៩

ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា

និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នាលេខនេះ ៖** អេង កុកថាយ, ដេង ពង្សរ៉ាស៊ី, អេនទ្រូ ស្តាញមេន, នៀល ប៉ាយ, កែជ្រាអ៊ីក ក្លាសស្ប៉ាយ, គង់ សុគឿន, អានី លីនស្តី, អែម សុឃីម, សូហ្វារីណា, សារ៉ា ថមម៉ាស់, អេតែល ហ៊ីហ្គូនេត, អ៊ែន ហាញឧល, សាន្ត សុខ និង ប៉ាំង ឆន **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** គាត លក្ខិណា, សោម ប៊ុនថន **អ្នកបកប្រែ៖** ជា ផល្លា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ជំនួយការនិពន្ធនាយក ៖** លី សុផល **ក្រាហ្វិកកុំព្យូទ័រ ៖** ស៊ីម សុភ័ក្រ្ត **គ្រប់គ្រងការចែកផ្សាយ ៖** វ័ត្ន គារាពិដោរ



Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ :*

# មជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ប្រចាំនៅអាស៊ីអាគ្នេយ៍

នៅក្នុងសន្និសីទប្រចាំឆ្នាំរបស់សមាគមបញ្ញាជនអំពើប្រល័យពូជសាសន៍អន្តរជាតិនៅទីក្រុងបូស្នី នាខែកក្កដា ឆ្នាំ ២០០៧ លោក អេង កុកថាយ ដែលជានាយកផ្នែកស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានដាក់សំណើទាក់ទងនឹងភាពចាំបាច់ក្នុងការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍សម្រាប់តំបន់អាស៊ីអាគ្នេយ៍ ការបង្កើតមជ្ឈមណ្ឌលនេះនឹងធ្វើឡើងតាមរយៈការប្រែក្លាយពីមជ្ឈមណ្ឌលឯកសារកម្ពុជាឲ្យទៅជាអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានមានដំណើរការយ៉ាងសកម្មនៅក្នុងប្រទេសកម្ពុជាអស់រយៈពេលជាង១០ឆ្នាំមកហើយ ។ មជ្ឈមណ្ឌលពេលនេះបានបង្កើតឲ្យមានការចាប់អារម្មណ៍ឡើងវិញចំពោះលើអំពើប្រល័យពូជសាសន៍ខ្មែរក្រហមដែលត្រូវបានបំភ្លេចចោលអស់រយៈពេលជាយូរមកហើយ ។ តាមរយៈការបោះពុម្ពផ្សាយសៀវភៅប្រវត្តិសាស្ត្រខ្មែរក្រហមសម្រាប់ថ្នាក់វិទ្យាល័យរួមនឹងការបោះពុម្ពផ្សាយសៀវភៅប្រវត្តិសាស្ត្រផ្សេងទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានក្លាយខ្លួនជាមជ្ឈមណ្ឌលអប់រំអំពើប្រល័យពូជសាសន៍ដ៏សំខាន់មួយនៅក្នុងប្រទេសកម្ពុជា ។ ទស្សនាវដ្តីស្វែងរកការពិតដែលបានចាប់ផ្តើមបោះពុម្ពផ្សាយតាំងពីឆ្នាំ២០០០ ត្រូវបានអាននិងផ្សព្វផ្សាយទៅគ្រប់មជ្ឈដ្ឋានក្នុងប្រទេសកម្ពុជា ។ ទស្សនាវដ្តីនេះមានតួនាទីយ៉ាងសំខាន់នៅក្នុងការអប់រំប្រវត្តិសាស្ត្រនិងស្វែងរកការពិត ។ តាមរយៈបទពិសោធន៍នេះ មជ្ឈ-មណ្ឌលឯកសារកម្ពុជាចង់កែប្រែខ្លួនឲ្យទៅជាអង្គភាពអប់រំអំពើប្រល័យពូជសាសន៍នៅកម្ពុជា ព្រមទាំងនៅតំបន់អាស៊ីអាគ្នេយ៍ផងដែរ ។ ការអប់រំនឹងក្លាយជាផ្នែកមួយសំខាន់របស់មជ្ឈមណ្ឌលថ្មីនេះ ប៉ុន្តែការស្រាវជ្រាវអំពើប្រល័យពូជសាសន៍និងការអង្កេតមើលសភាពការណ៍ក្នុងតំបន់នឹងក្លាយជាផ្នែកដ៏សំខាន់មួយទៀត ។

ដូចតំបន់ផ្សេងទៀតនៅក្នុងពិភពលោក អាស៊ីអាគ្នេយ៍ស្ថិតនៅក្រោមការគំរាមកំហែងជាប្រចាំពីអំពើប្រល័យពូជសាសន៍ ។ អាស៊ីអាគ្នេយ៍ជាតំបន់ដែលមានជាតិពន្ធច្រើន ។ ក្រុមប្រទេសប្រជុំកោះដូចជា ឥណ្ឌូណេស៊ី ម៉ាឡេស៊ី ហ្វីលីពីន និងប្រទេសផ្សេងទៀតកំពុងតែស្ថិតនៅក្នុងគ្រោះថ្នាក់ ពីព្រោះថា ប្រទេសទាំងនេះមានវប្បធម៌ច្រើនដែលធ្លាប់តែនៅឆ្ងាយពីគ្នា ។ បច្ចុប្បន្ននៅក្រោមឥទ្ធិពលនៃសាកលភាវូបនីយកម្ម ព្រមទាំងសមាហរណកម្មផ្នែកសង្គមនិងសេដ្ឋកិច្ចនៅក្នុងតំបន់ វប្បធម៌ទាំងនេះប៉ះទង្គិចគ្នា ខ្លះបង្កឲ្យមានជម្លោះ លើសពីនេះការវិវត្តនិងការបែកខ្ញែកក្រុមជាបាតុភូតដែលកើតមានជាប្រចាំនៅក្នុងប្រទេសផ្សេងទៀត ។ ជនជាតិភាគតិចរស់នៅតំបន់ឆ្ពុសានប្រទេសកម្ពុជា វៀតណាមកណ្តាលនិងភាគខាងត្បូងប្រទេសឡាវ កំពុងតែស្ថិតនៅក្រោមសម្ពាធ ដោយរូបរួមជាមួយសហគមន៍អន្តរជាតិ ។ ការសិក្សានិងការស្វែងយល់ពីបាតុភូតនេះមានសារសំខាន់ក្នុងការការពារមិនឲ្យមានជម្លោះនៅថ្ងៃខាងមុខ ដែលជម្លោះនេះ អាចក្លាយទៅជាអំពើប្រល័យពូជសាសន៍ ។

នៅក្នុងអត្ថបទនេះ លោក អេង កុកថាយ ផ្តល់ចម្លើយចំនួន៩ទាក់ទងនឹងមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ថ្មី ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងនឹងបង្កើតនៅពេលខាងនេះ ។

**១) តើពេលណាដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានបំណងបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍សម្រាប់តំបន់អាស៊ីអាគ្នេយ៍?**

ប្រសិនបើយើងអាចបង្កើតស្ថាប័នបែបនេះកាន់តែឆាប់កាន់តែប្រសើរ ។ យើងរំពឹងថា ការងាររបស់យើងក្នុងទិសដៅនេះនឹងចាប់ផ្តើមជាបន្ទាន់ បន្ទាប់ពីតុលាការខ្មែរក្រហមត្រូវបានបញ្ចប់ ពីព្រោះពេលនោះ យើងអាចបង្វែរធនធានរបស់យើងទៅផ្តោតលើការងារទាក់ទងនឹងអំពើប្រល័យពូជសាសន៍ក្នុងតំបន់ ។ បទពិសោធន៍ដែលបានកើតឡើងពីមុននៅក្នុងប្រទេសកម្ពុជា ទីម័រខាងកើត និងប្រទេសផ្សេងទៀតបញ្ជាក់ថា ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ជាការចាំបាច់ ។ អ្វីដែលកំពុងតែកើតឡើងនៅភាគខាងត្បូងប្រទេសថៃបានបញ្ជាក់

ថា ទោះបីជាគ្មានសង្គ្រាមនៅក្នុងតំបន់ ជម្លោះហិង្សានៅតែអាចកើតមាន ។ នៅពេលដែលមានជម្លោះហិង្សាបែបនេះ យើងមិនគួរបោះបង់ចោលឱកាសដែលអំពើប្រល័យពូជសាសន៍អាចកើតមានបានឡើយ ទោះបីជា ឱកាសនេះវាតិចតួចក៏ដោយ ។

**២) តើមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍មានគោលបំណងដូចម្តេចខ្លះ?**

យើងបានដាក់គោលដៅច្បាស់លាស់ចំពោះការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវ ។ អំពើហិង្សាដែលកំពុងតែកើតមាននៅភាគខាងត្បូងប្រទេសថៃ ជម្លោះផ្តាច់ខ្លួននៅខេត្តនានានៃប្រទេសឥណ្ឌូនេស៊ី របបផ្តាច់ការនៅប្រទេសភូមា ព្រមទាំងការរួមបញ្ចូលជាតិពន្ធុផ្សេងៗឲ្យចូលរួមក្នុងសមាគមអន្តរជាតិ និងភាពរង្គោះរង្គើនៃរចនាសម្ព័ន្ធសង្គម បានធ្វើឲ្យមានភាពចាំបាច់ក្នុងការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ ។ មជ្ឈមណ្ឌលនេះនឹងសហការជាមួយមជ្ឈមណ្ឌលនៅក្នុងតំបន់ផ្សេងទៀតដូចជាសមាគមអំពើប្រល័យពូជសាសន៍អន្តរជាតិ ។ មជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ថ្មីនេះនឹងស្រាវជ្រាវអំពើឃោរឃៅនៅក្នុងអតីតកាល ព្រមទាំងព្យាករណ៍ការពារមិនឲ្យកើតមាននិងធ្វើអន្តរាគមន៍ក្នុងអំពើប្រល័យពូជសាសន៍នៅថ្ងៃមុខ ។

មជ្ឈមណ្ឌលថ្មីនេះនឹងបង្កើតការិយាល័យស្រាវជ្រាវការិយាល័យអង្កេតអំពើប្រល័យពូជសាសន៍ អប់រំអំពើប្រល័យពូជសាសន៍ វិភាគជម្លោះ និងផ្តល់ការប្រកាសអាសន្នមុនពេលអំពើប្រល័យពូជសាសន៍ណាមួយកើតឡើង ។

**៣) តើនៅក្នុងដំណាក់កាលទី១ ត្រូវការថវិកាប៉ុន្មាន បានមកពីណា តើរាជរដ្ឋាភិបាលកម្ពុជានឹងជួយប៉ុន្មាន?**

យើងមានគម្រោងស្វែងរកថវិកាចំនួនពីរលានដុល្លារអាមេរិក ដើម្បីធានាយ៉ាងណាអាចឲ្យការងាររបស់យើងអាចដំណើរការទៅដោយរលូននិងមានប្រសិទ្ធភាព ។ បច្ចុប្បន្នយើងកំពុងស្វែងរកប្រភពជំនួយ ជាទូទៅយើងមិនរំពឹងថារដ្ឋាភិបាលកម្ពុជានឹងអាចជួយបានច្រើនទេ ប៉ុន្តែឲ្យតែបានជួយខ្លះ ទោះជាក្នុងរូបភាពណាក៏ដោយក៏យើងពេញចិត្តដែរ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលថវិកាពីគ្រប់ទិសទីនៅក្នុងពិភពលោក ជាពិសេសពីប្រទេសស៊ុយអែត ណ័រវេ អាមេរិក ញ៉ូសេឡែន ។ នៅពេលដែលយើងពង្រីកការងាររបស់យើងឲ្យមានលក្ខណៈអន្តរជាតិ និងកាន់តែទូលំទូលាយ យើងព្យាយាមស្វែងរកថវិកាពីមូលនិធិធំៗដូចជា ចច សូរូ និងហ្វត ។ ជាមួយគ្នានេះ យើងក៏មានបំណងសុំថវិកាពីមហាវិទ្យាល័យនិងប្រទេសនានានៅតំបន់អាស៊ីអាគ្នេយ៍ដែរ ។

**៤) តើស្ថាប័ននេះត្រូវការឲ្យមានបុគ្គលិកប៉ុន្មាននាក់?**

មជ្ឈមណ្ឌលឯកសារកម្ពុជាមានការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងកម្មវិធីបណ្តុះបណ្តាលបុគ្គលិក ។ បើប្រៀបធៀបចំនួនបុគ្គលិកទាំងអស់ទៅនឹងបុគ្គលិកដែលបានទៅបន្តការសិក្សានៅបរទេស ខ្ញុំជឿថា មជ្ឈមណ្ឌលឯកសារមានភាគរយខ្ពស់ជាងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ។ កន្លងមកយើងបានបញ្ជូនបុគ្គលិកចំនួនជិត២០នាក់ឲ្យទៅបន្តការសិក្សាជាន់ខ្ពស់នៅសហរដ្ឋអាមេរិក ចក្រភពអង់គ្លេស ស៊ុយអែត ហូល្លង់ ហុងកុង អូស្ត្រាលី និងប្រទេសផ្សេងៗទៀត ។ បុគ្គលិកម្នាក់នឹងបញ្ចប់ការសិក្សាថ្នាក់បណ្ឌិតនៅខែឧសភាខាងមុខនេះ ពីរនាក់ទៀតកំពុងសរសេរនិក្ខេបបទថ្នាក់បណ្ឌិត ។ លើសពីនេះ យើងបានបញ្ជូនបុគ្គលិកឲ្យទៅទទួលការបណ្តុះបណ្តាលរយៈពេលខ្លីក្រោមមួយឆ្នាំជាច្រើននាក់ទៀតនៅប្រទេសអាហ្វ្រិកខាងត្បូង ផ្នែកយុត្តិធម៌អន្តរកាល អៀរឡង់ខាងជើង ផ្នែកច្បាប់សិទ្ធិមនុស្សអន្តរជាតិ ប្រទេសអូស្ត្រាលី ផ្នែករៀបចំប្រព័ន្ធទិន្នន័យកុំព្យូទ័រ ទីក្រុងហាហ្គ បូស្ន៊ី ប៉ាគីស្ថាន ឥណ្ឌូនេស៊ី អ៊ីរ៉ាក់និងប្រទេសផ្សេងៗទៀត ។

ក្រោយពីទទួលបានសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកច្បាប់ ប្រវត្តិសាស្ត្រ វិទ្យាសាស្ត្រនយោបាយ ទំនាក់ទំនងអន្តរជាតិ ផ្នែកសិក្សាជម្លោះ បុគ្គលិកទាំងនេះនឹងវិលត្រឡប់មកប្រទេសកម្ពុជាវិញដើម្បីបង្កើតជាកម្លាំងការងារស្នូលសម្រាប់មជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍ ។ ក្នុងពេលជាមួយគ្នានេះដែរ យើងក៏បានធ្វើការទាក់ទងជាមួយបញ្ញាជនអន្តរជាតិជាច្រើននាក់ ពិសេសទាក់ទងនឹងផ្នែកអំពើប្រល័យពូជសាសន៍ សង្គ្រាម ប្រវត្តិសាស្ត្រនរវិទ្យា ច្បាប់សិទ្ធិមនុស្សអន្តរជាតិ និង ផ្នែកផ្សេងទៀតដែលចាំបាច់ក្នុងការស្រាវជ្រាវអំពើប្រល័យពូជសាសន៍ក្នុងតំបន់ ។ លើសពីនេះយើងក៏មានបំណងធ្វើការជាមួយស្ថាប័នស្រាវជ្រាវផ្សេងទៀតដែរ ។ ជាមួយនឹងបុគ្គលិកស្នូលជិត២០នាក់នេះ យើងនឹងធ្វើការជ្រើសរើសបុគ្គលិកបន្ថែមចំនួន២០-៣០នាក់ដើម្បីបម្រើការងារ

ផ្នែកហិរញ្ញវត្ថុ រដ្ឋបាល គ្រប់គ្រង ស្រាវជ្រាវតាមខេត្ត បកប្រែភាសា និងចងក្រងឯកសារ ។

### ៥) តើមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍នឹងផ្តល់អត្ថប្រយោជន៍យ៉ាងណាខ្លះដល់ប្រជាជនអាស៊ាននៅថ្ងៃអនាគត?

ប្រយោជន៍គឺធំធេងណាស់ ។ ក្នុងនាមជាពលរដ្ឋកម្ពុជា យើងមិនចង់ឃើញប្រជាជននៃប្រទេសផ្សេងទៀតទទួលរងភាពលំបាកវេទនាដែលយើងធ្លាប់ឆ្លងកាត់ឡើយ ។ យើងចង់ឲ្យប្រជាជនអាស៊ានរស់នៅក្នុងភាពសុខសាន្ត និងពោរពេញទៅដោយការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន ពិសេសសិទ្ធិរស់រានមានជីវិត ។ នៅពេលដែលយើងអាចការពារមិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើង យើងនឹងមានការសប្បាយចិត្ត ពីព្រោះនោះជាអ្វីដែលយើងចង់បាន ។ ការការពារអំពើប្រល័យពូជសាសន៍ប្រសើរជាងការកែកុនភាពខូចខាតក្រោយអំពើនេះបានកើតឡើង ។ អ្វីដែលបាត់បង់ទៅហើយ មិនអាចជួសជុលបានទេ ។ នៅពេលដែលអំពើប្រល័យពូជសាសន៍មួយបានកើតឡើងហើយ សង្គមនោះនឹងត្រូវបែកបាក់កែមិនបាន លុះត្រាតែមានកម្មវិធីស្តាបនាឡើងវិញល្អណាស់ទើបអាចកែកុនបាន ។ ហេតុនេះខ្ញុំគិតថា យើងគួរតែពិចារណាអំពីការការពារជាជាងការព្យាបាល ។ ហេតុនេះការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវអំពើប្រល័យពូជសាសន៍គឺជាការចាំបាច់បំផុត ។

### ៦) តើអ្វីទៅជាអំពើប្រល័យពូជសាសន៍?

នៅក្នុងសង្គ្រាមលោកលើកទី២ ពួកណាហ្ស៊ី បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែលបានសម្លាប់មនុស្សអស់ប្រហែលជាង៦លាននាក់ ៣ឆ្នាំក្រោយពីសង្គ្រាមត្រូវបានបញ្ចប់ អង្គការសហប្រជាជាតិបានបង្កើតអនុសញ្ញាស្តីពីការការពារនិងដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ។ អនុសញ្ញានោះបានដាក់អំពើប្រល័យពូជសាសន៍ជាបទឧក្រិដ្ឋអន្តរជាតិ ហើយបានចែងថា អំពើប្រល័យពូជសាសន៍គឺជា «ទង្វើទាំងឡាយណាដែលប្រព្រឹត្តឡើងក្នុងគោលបំណងបំផ្លិចបំផ្លាញទាំងមូល ឬមួយផ្នែក ជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា» រួមមាន ១) បណ្តាលឲ្យមានការខូចខាតធ្ងន់ធ្ងរផ្នែករាងកាយនិងផ្លូវចិត្ត ២) បង្កើតដោយចេតនានូវលក្ខខណ្ឌក្នុងគោលបំណងបំផ្លិចបំផ្លាញក្រុមមនុស្សទាំងមូលឬមួយផ្នែក ៣) បង្កើតជាលក្ខខណ្ឌដើម្បីទប់ស្កាត់មិនឲ្យមានការផ្តល់កំណើតកូន ៤) ការផ្ទេរកុមារពីក្រុមមួយទៅក្រុមមួយទៀត ៥) ការសម្លាប់មនុស្សក្នុងក្រុម ។ និយមន័យនៃអំពើប្រល័យពូជសាសន៍នេះត្រូវបានប្រើប្រាស់នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី រ៉្វាន់ដា និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

### ៧) តើអាស៊ីអាគ្នេយ៍មានសង្គ្រាមញឹកញាប់ដែរឬទេ?

បច្ចុប្បន្នប្រទេសមួយចំនួននៅក្នុងតំបន់អាស៊ីអាគ្នេយ៍កំពុងស្ថិតនៅក្នុងគ្រោះថ្នាក់អំពើប្រល័យពូជសាសន៍ ។ លក្ខខណ្ឌមួយដែលច្រើនតែកើតមាននៅពេលដែលអំពើប្រល័យពូជសាសន៍កើតមានសង្គ្រាម ពិសេសនៅក្នុងប្រទេសដែលទើបចាកចេញពីនឹមអាណានិគមបរទេស ។ ឧទាហរណ៍ អំពើប្រល័យពូជសាសន៍នៅក្នុងប្រទេសកម្ពុជាកើតឡើងក្នុងសង្គ្រាមត្រជាក់នៅពេលដែលពិភពលោកត្រូវបានបែងចែកជាពីរ គឺខាងលិច និងខាងកើត ។ កម្ពុជា វៀតណាម និងឡាវបានក្លាយទៅជាកូនអុកនៅក្នុងសង្គ្រាមនេះ ។ លើសពីនេះ ប្រទេសបីទើបតែបានរំដោះខ្លួនចេញពីអាណានិគមបារាំងប្រហែល២០ឆ្នាំមុននឹងត្រូវចូលទៅក្នុងសង្គ្រាមត្រជាក់រវាងប្រទេសមហាអំណាច ។

ក៏ប៉ុន្តែបច្ចុប្បន្នគ្មានអាណានិគមនិយមនៅក្នុងអាស៊ីអាគ្នេយ៍ និងចលនាទាមទារឯករាជ្យទៀតទេ ហើយក៏គ្មានជម្លោះមនោគមវិជ្ជារវាងកុម្មុយនីស្តនិយម និងលោកសេរីទៀតដែរ ។

### ៨) ចុះហេតុអ្វីបានអាស៊ីអាគ្នេយ៍ស្ថិតនៅក្នុងគ្រោះថ្នាក់កើតមានអំពើប្រល័យពូជសាសន៍?

នៅក្នុងឆ្នាំ១៩៩៣ ប្រហែល៥ឆ្នាំក្រោយពីសង្គ្រាមត្រជាក់ត្រូវបានបញ្ចប់ អ្នកវិទ្យាសាស្ត្រនយោបាយអាមេរិកឈ្មោះ សាំមូអែល ហាន់ទីងតុន បានបង្កើតទ្រឹស្តីថ្មីមួយស្តីអំពីសង្គ្រាមនៅចុងសតវត្សរ៍ទី២០ ។ គាត់បានឲ្យឈ្មោះទ្រឹស្តីនេះថាជម្លោះវប្បធម៌បានចែងថា នៅថ្ងៃមុខប្រភពជម្លោះសំខាន់បំផុតនៅក្រោយសង្គ្រាមត្រជាក់គឺ អត្តសញ្ញាណវប្បធម៌ និងសាសនា ។ ហាន់ទីងតុន បានពោលថា «ពិភពជម្លោះសំខាន់បំផុតនៅក្នុងសម័យកាលថ្មី និងមិនមែនសេដ្ឋកិច្ចពីមនោគមវិជ្ជាទេ ពិភពជម្លោះ

សំខាន់ជាងគេបំផុតនោះគឺវប្បធម៌» ។ រដ្ឋទាំងឡាយនឹងនៅតែជាតួអង្គសំខាន់នៅក្នុងពិភពលោក ប៉ុន្តែជម្លោះនឹងលេចចេញរវាងវប្បធម៌ធំៗ ។ ជម្លោះវប្បធម៌នឹងគ្របសង្កត់នយោបាយសាកលលោក ។ បន្ទាត់ខណ្ឌរវាងវប្បធម៌ផ្សេងៗនឹងក្លាយទៅជាសមរភូមិនៅថ្ងៃមុខ ។ ហាន់នីងតុន បានលើកឡើងពីមូលហេតុនៃសង្គ្រាមនៅតំបន់បាល់កង់ និងសង្គ្រាមរវាងឥណ្ឌានិងប៉ាគីស្ថានជាភ័ស្តុតាង ។ ទ្រឹស្តីរបស់ ហាន់នីងតុន ត្រូវបានទទួលស្គាល់ដោយអ្នកនយោបាយអ្នកស្រាវជ្រាវនិងសង្គមស៊ីវិល អ្នកខ្លះបានយកទ្រឹស្តីនេះដើម្បីពន្យល់មូលហេតុនៃអំពើភេរវកម្មដូចជា ការវាយប្រហារទៅលើអគារពាណិជ្ជកម្មពិភពលោកនៅទីក្រុងញូវយ៉កនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០០១ ។

ដើម្បីពន្យល់អំពីមូលហេតុនៃអំពើប្រល័យពូជសាសន៍ដែលអាចកើតមាននៅអាសីអាគ្នេយ៍ យើងត្រូវពិចារណាទៅលើបាតុភូតពីរធំគឺ សាកលភាវូបនីយកម្ម និងការបែកបាក់របស់សាកលភាវូបនីយកម្មសំដៅទៅលើការច្របល់ចូលគ្នារវាងក្រុមមនុស្ស និងប្រទេសតាមរយៈសមាហរណកម្មសេដ្ឋកិច្ច និងការរីកចម្រើនបច្ចេកវិទ្យាដូចជា អ៊ីនធឺណិត និងទូរគមនាគមន៍ ។ សាកលភាវូបនីយកម្មមានចំណុចល្អច្រើន តែថា មានចំណុចអវិជ្ជមានខ្លះដែរ ។ ក្រុមខ្លះបានបដិសេធទាំងស្រុងនូវការច្របល់ចូលគ្នារវាងប្រទេសនិងជនជាតិ ហើយជ្រើសយកការអភិរក្សអត្តសញ្ញាណជាតិ និងសាសនា ហេតុនេះក្រុមទាំងនោះ ច្រានចោលអ្វីដែលពួកគេយល់ថា ធ្វើឲ្យបាត់បង់ទំនៀមទម្លាប់ប្រពៃណីខ្លួន ។

សាកលភាវូបនីយកម្មកំពុងតែមានឥទ្ធិពលខ្លាំងមកលើតំបន់ប្រទេសអាស៊ាន ។ ការរីកចម្រើនផ្នែកសេដ្ឋកិច្ចនៅប្រទេសសិង្ហបុរី ម៉ាឡេស៊ី ឥណ្ឌូណេស៊ី ថៃ និងវៀតណាម ជាភ័ស្តុតាងបញ្ជាក់ថា គេកំពុងតែបើកទ្វារចំហពីឥទ្ធិពលខាងក្រៅលើសទំនាក់ទំនងសេដ្ឋកិច្ចនិងសង្គមរវាងប្រទេសអាស៊ានក៏មានលក្ខណៈខ្លាំងក្លា ។ សមាគមអាស៊ានមានបំណងជំរុញបន្ថែមនូវការធ្វើសមាហរណកម្មលើសាខាផ្សេងៗទៀតដែលបណ្តាលឲ្យសាកលភាវូបនីយកម្មក្នុងតំបន់កាន់តែមានល្បឿនលឿនថែមទៀត ។ ប៉ុន្តែសន្ទុះលឿននេះអាចនាំមកនូវគ្រោះថ្នាក់ ។

ក្នុងពេលជាមួយគ្នានោះអាស៊ាន និងសង្គមមនុស្សជាច្រើនដែលមានវប្បធម៌ សញ្ញាណជាតិ សាសនា និងប្រវត្តិសាស្ត្រដោយឡែកៗពីគ្នា ។ នៅពេលដែលវប្បធម៌ទាំងនេះប៉ះទង្គិចគ្នាវាបណ្តាលឲ្យមានជម្លោះ ។ ជាក់ស្តែងជនជាតិភាគតិចនៅតំបន់ឦសានប្រទេសកម្ពុជា ភាគខាងត្បូងប្រទេសឡាវ និងភាគកណ្តាលប្រទេសវៀតណាម កំពុងតែទទួលឥទ្ធិពលពីខាងក្រៅដែលបណ្តាលឲ្យមានការរេចរិលបន្តិចម្តងៗនូវអត្តសញ្ញាណនិងវប្បធម៌របស់ជនជាតិភាគតិចទាំងនេះ ។ បច្ចុប្បន្នមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងសិក្សាស្រាវជ្រាវអំពីកម្រិតនៃការរេចរិលនេះនិងអំពីតួនាទីនៃការអប់រំដើម្បីរក្សាអត្តសញ្ញាណក្រុម ។

### ៩) តើតំបន់ណាមួយនៅអាស៊ីអាគ្នេយ៍ដែលស្ថិតក្រោមការគំរាមកំហែងពីអំពើប្រល័យពូជសាសន៍?

ក្រុមប្រទេសប្រជុំកោះដូចជាប្រទេសម៉ាឡេស៊ី ឥណ្ឌូណេស៊ី និងហ្វីលីពីន កំពុងតែស្ថិតនៅក្នុងភាពគ្រោះថ្នាក់ ។ ប្រទេសទាំងនេះមានទឹកដីធំធេង និងសម្ពាធប្រជាជនខ្ពស់ ។ ប្រទេសទាំងនេះកំពុងតែមានវិបត្តិបង្កើតជាអត្តសញ្ញាណជាតិរួម ពីព្រោះក្នុងប្រទេសទាំងនេះមានវប្បធម៌ផ្សេងៗច្រើន ។ ក្នុងប្រទេសឥណ្ឌូណេស៊ីមាន២០០សាសនា ។ ឥណ្ឌូណេស៊ី និងហ្វីលីពីនមានកោះរាប់ពាន់ ដែលធ្វើឲ្យប្រជាជនរស់នៅដោយឡែកពីគ្នា ។ ជីវិតនៅលើកោះទាំងនេះបានបង្កើតជាវប្បធម៌ខុសៗគ្នា ។ បច្ចុប្បន្ននៅពេលដែលប្រជាជនទាំងនោះប្រាស្រ័យទាក់ទងគ្នាក្រោមសម្ពាធសាកលភាវូបនីយកម្មជម្លោះនឹងកើតមាន ។ **អេង កុកថាយ**

## ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុFM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧:៣០ព្រឹក និងម៉ោង៧:០០-៧:៣០ល្ងាច ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។ **ស៊ិន សុធីតា**

# ឌឹម សារឿន ហៅ ម៉េនៈ អនុប្រធានពេទ្យតំបន់៧ ភូមិភាគពាយ័ព្យ

***(ឯកសារ D57)***

*ឌឹម សារឿន ហៅ ម៉េន មានស្រុកកំណើតនៅ កៀនស្វាយ ខេត្តកណ្ដាល ។ ម៉េន មានកូន៦នាក់ ជាប្រពន្ធរបស់ កែ គឹម ហួត លេខាតំបន់៧ ភូមិភាគពាយ័ព្យ ។ ហួត ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៧ ដោយចោទថា ១) ធ្វើសកម្មភាពប្រឆាំងនឹងបដិវត្តន៍ ២) សរសេរអត្ថបទកាសែតវាយប្រហារតាមរយៈស្ថានទូតអេហ្ស៊ីបនៅបរទេស ៣) ទុកស្បៀងឲ្យខូចមិនចែកឲ្យប្រជាជន និង៤) ត្រៀមកម្លាំងធ្វើរដ្ឋប្រហារពេលធ្វើបុណ្យជាតិធំៗ ដើម្បីសម្លាប់ក្បាលម៉ាស៊ីនដឹកនាំរបស់បក្ស ។ ម៉េន ប្រហែលជាត្រូវចាប់ខ្លួន៤ថ្ងៃបន្ទាប់ពីបានចាប់ខ្លួន ហួត នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៧ ព្រោះថានៅក្នុងប្រវត្តិរូបសង្ខេបរបស់ ម៉េន សរសេរនៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៧៧ ។ ប្រវត្តិរូបសង្ខេបរបស់ ឌឹម សារឿន ហៅ ម៉េន មានចំនួន១៩ទំព័រដែលមានខ្លឹមសារថា ៖*




*នៅឆ្នាំ១៩៦៥ ម៉េន ទទួលការអប់រំពីឈ្មោះ ភី(ប្រពន្ធរបស់ ម៉ៃ លន់) តាមរយៈមើលខ្សែភាពយន្តអាមេរិក ប្រើមនោសញ្ចេតនា សម្ភារៈនិងលើកតម្កើងអាមេរិករិះគន់បដិវត្តន៍ជាដើម ។*

*នៅឆ្នាំ១៩៦៦ ម៉េន ត្រូវបានបញ្ចូលជាសមាជិក សេ អ៊ី អា នៅផ្ទះ ម៉ៃ លន់ ។ ដើម្បីក្លាយជាសមាជិកពេញសិទ្ធិ ម៉េន ត្រូវគោរពទង់ជាតិអាមេរិក និងធ្វើសច្ចាប្រណិធាន ។ ពេលនោះ ម៉េន ទទួលភារកិច្ច រាយការណ៍ពីបដិវត្តទៅឲ្យ ភី និង ម៉ៃ លន់ បន្ទុចបន្ទាក់ បំបែកបំបាក់សាមគ្គី បង្កប់ស៊ីរ៉ូងផ្ទៃក្នុង និងប្រើយុទ្ធសាស្ត្រកម្ទេចបដិវត្តន៍ ។ បន្ទាប់មក ម៉ៃ លន់ បានខទ្ទេសនាម ម៉េន ឲ្យស្គាល់ ប៊ូ រ៉ុទ្ធី ជា សេ អ៊ី អា ដែរ ។ ម៉េន បានរាយការណ៍ពីឈ្មោះអ្នកបដិវត្តដូចជា លី, គិន និងប្រពន្ធរបស់គិន ព្រមទាំងយកកាសែតបដិវត្តន៍ទៅឲ្យ ម៉ៃ លន់ មើលជាបន្តបន្ទាប់ ។*

*នៅឆ្នាំ១៩៧១ ម៉េន ត្រូវបានចាត់តាំងចេញទៅនៅព្រៃ ពេលនោះ ម៉ៃ លន់ បានខទ្ទេសនាមឲ្យ ម៉េន ទាក់ទងជាមួយ ស៊ូ និង ម៉ៃ ដើម្បីធ្វើសកម្មភាពប្រឆាំងបដិវត្តន៍ និងបង្អាក់ចលនាបដិ-វត្តន៍ ។ ក្រោយមក ម៉េន ទៅនៅអមលាំងជាមួយ ធុច និង រិន មួយរយៈ ទើបផ្លាស់ទៅធ្វើការនៅមន្ទីរកាត់ដេរ ស្ថិតក្នុងភូមិបុល ឃុំសន្ត្រា តំបន់២ ភូមិភាគពាយ័ព្យ ។*

*នៅខែ៤ ឆ្នាំ១៩៧២ ម៉េន បានជួបប្រជុំជាមួយ ស៊ូ, ម៉ៃនិង សុត នៅភូមិបុល ឃុំសន្ត្រា តំបន់២ ភូមិភាគពាយ័ព្យ ដើម្បីរៀបចំផែនការប្រឆាំង បង្កប់ខ្លួនឲ្យជ្រៅនៅក្នុងជួរបដិវត្តន៍ និងកសាងកម្លាំង ។*

*នៅខែ២ ឆ្នាំ១៩៧៣ ម៉េន បានជួបប្រជុំជាមួយ ស៊ូ, ម៉ៃ និង សុត នៅស្រុកលាចហើយបានរាយការណ៍ពីសកម្មភាពប្រឆាំងបដិវត្តន៍កន្លងមក ពង្រឹងការងាររបស់ និងបង្កប់ខ្លួនក្នុងជួរបដិវត្តន៍ ។*

*នៅខែ៦ ឆ្នាំ១៩៧៥ ម៉េន មកនៅមន្ទីរពេទ្យតំបន់៧ស្រុកកណ្ដៀង ភូមិភាគពាយ័ព្យ រហូតដល់ខែ២ ឆ្នាំ១៩៧៧ ផ្លាស់មកនៅមន្ទីរប១ ត្រូវអង្គការចាប់ខ្លួន ។*

***ក្រៅពីនោះ ម៉េន បានអូសទាញកម្លាំងបង្កប់បាន៥នាក់គឺៈ***

*១) នារី ជ័យ នៅមន្ទីកាត់ដេរតំបន់២ ក្រោយមកផ្លាស់មកនៅពាណិជ្ជកម្មតំបន់៧ ភូមិភាគពាយ័ព្យ ២) សុខ រ៉េត នៅមន្ទីរវប្បធម៌ស្រុកក្រគរ ក្រោយមកផ្លាស់មកនៅពាណិជ្ជកម្មតំបន់៧ ភូមិភាគពាយ័ព្យ ៣) ផា នៅមន្ទីកាត់ដេរតំបន់២ ក្រោយមកផ្លាស់មកនៅកងនេសាទត្រីទន្លេសាបតំបន់៧ ភូមិភាគពាយ័ព្យ ៤) ណង នៅពាណិជ្ជកម្មតំបន់២ ក្រោយមកផ្លាស់មកនៅពាណិជ្ជកម្មតំបន់៧ ភូមិភាគពាយ័ព្យ និង៥) នារី រិន នៅមន្ទីកាត់ដេរស្រុកកណ្ដៀង តំបន់៧ ភូមិភាគពាយ័ព្យ ។*

**សោម ប៊ុនថន**

# នារីក្នុងជួរបដិវត្តន៍

នៅក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហមចាប់ពីអំឡុងឆ្នាំ ១៩៧៥-១៩៧៩ ប្រជាជនកម្ពុជាទាំងអស់មិនមាននរណាម្នាក់ ដែលគេចផុតពីការអត់ឃ្លាន ការងារធ្ងន់ធ្ងរ ទារុណកម្ម ការព្រាត់ប្រាសនិងការស្លាប់បាត់បងប្អូនឪពុកម្តាយឡើយ ។ ខ្មែរក្រហមយល់ថាដើម្បីធ្វើឲ្យប្រទេសជាតិរីកចម្រើនជឿនលឿនអ្នកដែលបម្រើការងារឲ្យរបបរបស់ខ្លួនត្រូវជ្រើសចេញពីវណ្ណៈកសិករ និងកម្មករ ។ ប្រជាជនទាំងចាស់ក្មេងត្រូវមានការងារធ្វើគ្រប់ៗគ្នា មិនតែប៉ុណ្ណោះត្រូវមានភាពស្មោះត្រង់និងលះបង់គ្រប់បែបយ៉ាងដើម្បីបក្សទៀតផង ។ ជាក់ស្តែង យុន សុខុំ ដែលទើបមានអាយុ ១២ឆ្នាំបានឆ្លងកាត់ការងារសង្គមជាច្រើនដូចជា ធ្វើជាគ្រូបង្រៀន កម្មករស្រែអំបិល ធ្វើបង្គី និងធ្វើស្រែជាដើម ។ ទោះបីជាខិតខំធ្វើការងារលំបាកៗយ៉ាងណាក្តី ក៏ខ្មែរក្រហមនៅតែចោទ ខ្ញុំ ថាខ្ជិលប្រអូសធ្វើការមិនបានតាមផែនការកំណត់និងមានគំនិតស្វនត្ត ។ ប៉ុន្តែដោយសារ ខ្ញុំ ធ្លាប់ចូលបម្រើក្នុងបដិវត្តន៍ ទើប ខ្ញុំ អាចមានជីវិតរស់រហូតមកដល់សព្វថ្ងៃ ។ រយៈពេលជាង២០ឆ្នាំមកហើយដែល ខ្ញុំ មិនបាននិយាយរឿងនេះ ប៉ុន្តែគាត់មិនអាចបំភ្លេចបានដែរនៅពេលនឹកឃើញរំពុកឡើងវិញម្តងៗ ។

យុន សុខុំ ហៅ ហាន កើតនៅភូមិបឹងធំខាងកើត ឃុំកន្តោរខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ។ ខ្ញុំ ជាកូនស្រីច្បងក្នុងចំណោមបងប្អូន៩នាក់ ស្រី៦ នាក់ ប្រុស៣នាក់ មានឪពុក-


យុន សុខុំ

ម្តាយជាកសិករ ។ ខ្ញុំ រៀនថ្នាក់ទី៩ (សង្គមចាស់) នៅសាលាបឋមសិក្សាអង្គសុភី ស្ថិតក្នុងឃុំកន្តោរខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ។ ក្រោយមកខ្ញុំឈប់រៀនមកជួយធ្វើការងារស្រែចម្ការឪពុកម្តាយនិងមើលប្អូនតូចៗនៅផ្ទះ ។ នៅពេលប្អូនៗរបស់ ខ្ញុំ យំនៅពេលយប់ម្តងៗ ម្តាយខ្ញុំតែងតែបន្ទាចថា «ប្រយ័ត្នខ្មែរក្រហមចូលមកចាប់» ប៉ុន្តែ ខ្ញុំ មិនបានដឹងថា ពាក្យនេះមានន័យដូចម្តេចឬមាន ព្រឹត្តិការណ៍អ្វីកើតឡើងក្នុងភូមិឡើយ ។

បន្ទាប់ពីរដ្ឋប្រហារទម្លាក់សម្តេចសីហនុឆ្នាំ១៩៧០ ខ្មែរក្រហម និងវៀតកុង(វៀតណាមខាងជើង) តែងតែចូលក្នុងភូមិនៅពេលយប់ដើម្បីឃោសនាអូសទាញឲ្យប្រជាជនចូលបម្រើបដិវត្តន៍ និងចាត់តាំងកម្លាំងដឹកនាំក្នុងភូមិជាបន្តបន្ទាប់ធ្វើឲ្យប្រជាជនក្នុងភូមិមួយចំនួននឹកភ័យខ្លាច ។

ឆ្នាំ១៩៧២ ភូមិសាស្ត្រស្រុកកំពង់ត្រាចស្ទើរទាំងមូលត្រូវកងទ័ពខ្មែរក្រហមវាយកាន់កាប់ នៅសល់តែទីប្រជុំជនទីរួមស្រុកប៉ុណ្ណោះ ។ ចុងឆ្នាំ១៩៧២ យន្តហោះប្រតិកម្មរបស់កងទ័ព លន់ នល់ បានវាយឆ្មក់ចូលមកទម្លាក់គ្រាប់នៅក្នុងភូមិបឹងធំកើតដើម្បីបណ្តេញខ្មែរក្រហមនិងវៀតកុងឲ្យចេញពីភូមិ ប៉ុន្តែមិនបណ្តាលឲ្យគ្រួសាររបស់ ខ្ញុំ និងប្រជាជនរងគ្រោះថ្នាក់ទេ ។

នៅឆ្នាំ១៩៧៣ ពេលដែលស្រុកកំពង់ត្រាចត្រូវបានរំដោះ កងទ័ពខ្មែរក្រហមបានប្រមូលប្រជាជននៅក្នុងភូមិទាំងអស់ឲ្យមកចូលរួមប្រជុំនិងស្តាប់គោលនយោបាយដឹកនាំថ្មីរបស់អង្គការ ។ ពេលនោះ ខ្ញុំ និងបេក្ខនារី១០នាក់ទៀតត្រូវបានប្រធានភូមិជ្រើសរើសឲ្យចូលរួមប្រឡងធ្វើជាគ្រូបង្រៀននៅមន្ទីរស្រុកកំពង់ត្រាចដែលការប្រឡងត្រូវ អានអក្សរ បូកលេខ ដកលេខ និងចែកលេខ ។ ក្រោយពីប្រឡងចប់ គណៈស្រុកបានចែកសៀវភៅពុម្ពម្នាក់មួយក្បាលទុកបង្រៀនកូនសិស្ស ។ នៅថ្ងៃបន្ទាប់ ខ្ញុំ ត្រូវបានចាត់តាំងឲ្យបង្រៀនកូនសិស្សអាយុត្រឹម៦ឆ្នាំចុះក្រោមនៅក្នុងភូមិបឹងធំខាងកើត ឃុំកន្តោរខាងលិច ស្រុកកំពង់ត្រាច ដែលក្នុងមួយថ្នាក់មានកូនសិស្សប្រហែល៣០នាក់ ។ ដំបូង ខ្ញុំ បង្រៀនកូនសិស្សឲ្យស្គាល់ព្យញ្ជនៈ និងស្រៈ បន្ទាប់មកឲ្យធ្វើពលកម្ម ដើររើសអាចម៍គោ និងកាប់ទន្រ្ទានខែត្រ ។

**នៅភូមិស្នាមគូ**

នៅដើមឆ្នាំ១៩៧៨ ប្រធានភូមិបឹងធំបានប្តូរ ខ្ញុំ ឲ្យទៅបង្រៀននៅភូមិស្នាមគូរ ឃុំកន្ទោរខាងលិច ស្រុកកំពង់ត្រាចវិញ ដោយសារកូនសិស្សនៅក្នុងភូមិបឹងធំមួយចំនួនពុំស្តាប់ការពន្យល់របស់គាត់ ។ នៅទីនេះ ខ្ញុំ ត្រូវទៅស្នាក់នៅផ្ទះយាយ ហុង និងជួយធ្វើការផ្ទះជំនួសគាត់ ព្រោះថាគាត់នៅតែម្នាក់ឯង ។ ខ្ញុំ ចាប់ផ្តើមបង្រៀនកូនសិស្សប្រហែល៤០នាក់នៅក្នុងរោងប្រក់ស្លឹកមួយខ្នងដែលសង់ឡើងដោយប្រធានភូមិនិងប្រជាជន ។ ខ្ញុំ ទទួលបានការឧបត្ថម្ភជាសៀវភៅ ប៊ិច ខ្មៅដៃ ដីស និងអង្ករពី តាគីម ជាគណៈឃុំកន្ទោរខាងលិច ។ នៅពេលសិស្សចេះអានបានខ្លះៗ ខ្ញុំ ចាប់ផ្តើមឲ្យសិស្សទន្ទេញមេរៀនមួយស្តីពី «ពុកម៉ែយើងខំធ្វើការ ពួកងឈ្លបយើងខំការពារភូមិ» ។ ពេលទំនេរក្រៅពីការងារនេះ ខ្ញុំ ត្រូវដឹកនាំកូនសិស្សលើករងដាំដំឡូង ដាំខ្ទឹម និងត្រកួន ។ បង្រៀនបានមួយរយៈ ខ្ញុំ ក៏លួចមកលេងផ្ទះ ។ នៅក្នុងឆ្នាំដដែលនេះ ក្នុងភូមិស្នាមគូ អង្គការអនុញ្ញាតឲ្យចាយលុយនៅឡើយមានប្រជាជនខ្លះលួចចូលទៅប្រទេសវៀតណាមដើម្បីទិញទំនិញយកមកលក់ ដោយប្រថុយនឹងគ្រោះថ្នាក់ព្រោះប្រសិនបើកងទ័ពខ្មែរក្រហមចាប់បានអ្នកទាំងនេះនឹងត្រូវបញ្ជូនទៅរៀនសូត្រមួយរយៈទើបអនុញ្ញាតឲ្យត្រឡប់មកផ្ទះវិញ ។

## ការងារធ្វើអំបិល

ចុងឆ្នាំ១៩៧៨ ខ្ញុំ ត្រូវបានប្តូរឲ្យទៅបង្រៀននៅភូមិមួយទៀត ស្ថិតក្នុងឃុំកន្ទោរខាងលិចវិញ ។ នៅខណៈដែល ខ្ញុំ កំពុងបង្រៀនសិស្សតាគីម គណៈឃុំកន្ទោរខាងលិចបានចាត់តាំង ខ្ញុំ ឲ្យទៅចូលរួមប្រជុំនៅមន្ទីរស្រុកកំពង់ត្រាច រួចគណៈស្រុកបានប្រកាសឈ្មោះ ខ្ញុំ និងស្រីចំនួន១០នាក់ ផ្សេងទៀតឲ្យទៅធ្វើការនៅស្រែអំបិល ។ ក្រោយពីប្រាប់ដំណឹងទៅឪពុកម្តាយហើយ ព្រឹកឡើង ខ្ញុំ បានដើរទៅស្រុកអង្គរជ័យ ជាមួយស្រីប្រហែល១០០នាក់ទៀតដែលមកពីភូមិឃុំផ្សេង និងមាននិរសារម្នាក់ជាអ្នកនាំផ្លូវទៅឃុំភ្នំលាវ ស្រុកកំពង់ត្រាច ។ ខ្ញុំ មានតួនាទីលើកភ្លឺស្រែ បង្ហាប់ដី ដែលមានទទឹង១៥ម៉ែត្រ និងបណ្តោយ២៥ម៉ែត្រ និងអូសរនាស់ កៀរអំបិលចាប់ពីម៉ោង៧ ដល់ម៉ោង៥ល្ងាច ។ នៅពេលខ្លះ ខ្ញុំ ត្រូវធ្វើការបន្ថែមម៉ោងគឺក្រោកម៉ោង២យប់ ដើម្បីកើបអំបិលឲ្យទាន់ផែនការកំណត់របស់អង្គការ ។ ប៉ុន្តែ «ទោះបីជាគាត់ខំធ្វើការច្រើនយ៉ាងណាក៏ដោយ ខ្ញុំ នៅតែទទួលការស្តីបន្ទោសពី សន ជាប្រធានកងថា បង្ហាប់ដីពុំបានហាប់ល្អចធ្វើឲ្យអំបិលខូច» ។ ក្នុងចំណោមស្ត្រី១០០នាក់ក្នុងកងរបស់ ខ្ញុំ មានបុរសបីនាក់ប៉ុណ្ណោះ សម្រាប់កាន់ម៉ាស៊ីនបូមទឹកបញ្ចូលស្រែអំបិល ។ នៅទីនេះ ខ្ញុំ រៀបរាប់ថា កម្មករស្រែអំបិលមួយចំនួនស្លាប់ដោយសារយន្តហោះទម្លាក់គ្រាប់បែក និងការបាញ់ផ្លោងពីទាហានលន់ នល់ ដែលបោះទីតាំងនៅកោះទន្សាយ ។ ចំណែក ខ្ញុំ ភ័យខ្លាចពេកក៏រត់ទៅពួននៅវត្តភ្នំលាវ ក្នុងភូមិភ្នំលាវ ឃុំភ្នំលាវ ស្រុកកំពង់ត្រាចបានមួយថ្ងៃ ប្រធានកងបានប្រមូលឲ្យមកធ្វើការក្នុងកងវិញ ។ ថ្ងៃមួយប្រធានកងឲ្យកម្មករទាំងអស់សរសេរប្រវត្តិរូបផ្ទាល់ខ្លួនម្នាក់មួយសន្លឹក ។ អ្នកមកពីខេត្តកណ្តាល អង្គការប្រមូលឲ្យទៅរស់នៅត្រើយកោះ (ខាងលិចទីរួមខេត្តកំពត) ដែលមានទឹកសមុទ្រព័ទ្ធជុំវិញ ។ នៅទីនោះមិនមានទឹកសាបសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ទេ បណ្តាលឲ្យកម្មករកើតជំងឺរមាស់ រលួយសាច់ និងខ្លះស្លាប់ ។

## ការងារធ្វើបង្គី

ឆ្នាំ១៩៧៥ ខ្ញុំ ត្រូវមិត្តនារី មៀន នៅក្នុងកងវរសេនាធំស្នើឲ្យទៅចូលរៀនធ្វើបង្គីនៅភូមិកែវក្រសាំង ឃុំកែប ស្រុកកំពតក្រោមការគ្រប់គ្រងរបស់ប្រធានកងនារីឈ្មោះ រឹម ។ ខ្ញុំ ស្ថិតនៅក្នុងកងកុមារចំនួន៨នាក់ត្រូវរៀនច្រៀកឫស្សី កាច់ទ្រនុង និងក្រងបង្គីដោយខ្លួនឯង ។ ដោយសារ ខ្ញុំ ធ្វើបង្គីមិនបានគ្រប់ចំនួន៣គូក្នុង



១ថ្ងៃ នៅពេលប្រជុំ ប្រធានកងតែងតែលើកពីគុណវិបត្តិរបស់គាត់ និងប្រាប់ឲ្យគាត់ខិតខំកសាងខ្លួនធ្វើបដ្ឋីឲ្យបានច្រើន ។

នៅដើមឆ្នាំ១៩៧៦ មៀន បានដក ខ្ញុំ ឲ្យទៅជួយបង្រៀនពីវិធីធ្វើបដ្ឋីដល់ប្រជាជនក្នុងភូមិកំពង់នង់ ឃុំកូនសត្វ ស្រុកកំពត ។ នៅទីនោះ ខ្ញុំ និងក្រុមរបស់គាត់ដែលមានសមាជិក១២នាក់ត្រូវស្នាក់នៅផ្ទះថ្មបាក់បែកមួយ ។ ក្រោយពីប្រជាជនចេះធ្វើបដ្ឋី ខ្ញុំ ត្រូវផ្លាស់មកជួយរែកអំបិលទុកក្នុងឃ្លាំង ជួសជុលបដ្ឋីចាស់ៗ និងកាប់ឫស្សីនៅទឹកឈូ ។ ក្រោយមកនារី រឹម ប្រធានកងប្ដូរគាត់ឲ្យទៅធ្វើអំបិលនៅម្តុំអុងម៉ុងទឹក (ខាងកើតទីរួមខេត្តកំពត) ។ ទោះជាធ្វើការហត់យ៉ាងណាក្ដី ក៏ ខ្ញុំ ទទួលបានត្រឹមតែបបរនិងសម្លម្ជូរដើមចេកប៉ុណ្ណោះ ។ ដូច្នេះ ពេលប្រធានកងឲ្យ ខ្ញុំ ដើររកបេះបន្លែមកដុតដុងរោងបាយម្ដងៗ ខ្ញុំ តែងតែឆ្លៀតឱកាសលួចបេះផ្លែខ្នុរក្នុងភូមិមកបន្ទំចែកគ្នាហូបក្នុងក្រុម ។

នៅទីនេះ រយៈពេល៣-៤ខែម្ដង ខ្ញុំ ត្រូវទៅចូលរួមមីទ្ទីងនៅត្នោតកំបុត (ជិតប៉ុស្ដិ៍វិទ្យុកែប) ដែលមាន កង ចាប ជាគណៈតំបន់ឡើងនិយាយស្ដីពី «ការខិតខំប្រឹងធ្វើការងារ ដើម្បីរួមចំណែកកសាងប្រទេសជាតិ ពិសេសធ្វើអំបិលឲ្យបានច្រើនយកទៅដុតដុងបងប្អូន ឪពុកម្ដាយនៅសមរភូមិក្រោយ» ។ បន្ទាប់ពីមីទ្ទីងបញ្ចប់ ប្រធានកងអនុញ្ញាតឲ្យកងធ្វើអំបិលសម្រាកពេលរសៀល ។ ដូច្នេះ ខ្ញុំ ឆ្លៀតពេលប៉ះខោអាវដែលរហែកបានខ្លះទុកសម្រាប់ស្លៀកពាក់ពេលធ្វើការងារ ។

ឆ្នាំ១៩៧៦ ខ្ញុំ ត្រូវផ្លាស់មកកងរកខុសសម្រាប់ដុតដុងរោងបាយវិញដែលស្ថិតនៅភូមិកំពង់កណ្ដាល ឃុំជុំគ្រៀល ស្រុកកំពត ។ ប្រធានកងជ្រើសរើសអ្នកមិនចេះអក្សរឲ្យចូលរៀន ចំណែក ខ្ញុំ ដែលចេះអក្សរប្រធានកងតម្រូវឲ្យលើករងដាំត្រកួន ជីឡូង និងជួយវែងអង្ករនៅរោងបាយ ។ បន្ទាប់ពីហូបបាយពេលល្ងាច ខ្ញុំ ត្រូវចូលរួមប្រជុំស៊័យទិតៀនជាមួយនារី រឹម ស្ដីអំពីអ្នកដែលខ្ជិលធ្វើការងារ ហើយឲ្យប្ដេជ្ញាចិត្តកុំឲ្យអ្នកផ្សេងយកតម្រាប់ ។ ពេលធ្វើជីវទស្សន៍ ប្រធានកងបានចាត់ ខ្ញុំ ចូលក្នុងវណ្ណៈកណ្ដាល និងចោទថា «គាត់លាក់ប្រវត្តិរូបពីមុន ដោយតម្រូវឲ្យឡើងសារភាពពីការបែងចែកវណ្ណៈមិនបានច្បាស់លាស់» ។ ខ្ញុំ ត្រូវចូលរួមប្រជុំនៅចុងសប្ដាហ៍ស្ដីអំពីសីលធម៌រស់នៅមិនឲ្យមានការទាក់ទងរវាងបុរសនិងនារី ។ សូម្បីតែនិយាយជាមួយគ្នាក៏ត្រូវហៅមកអប់រំដែរ ម្យ៉ាងវិញទៀត ប្រសិនបើខុសសីលធម៌រហូតមានផ្ទៃពោះនឹងត្រូវហៅទៅអប់រំទាំងពីរនាក់ ហើយមិនដែលឃើញត្រឡប់មកធ្វើការក្នុងកងវិញទេ ។

មួយរយៈក្រោយមក ខ្ញុំ បានទទួលដំណឹងពីកងសេដ្ឋកិច្ចដែលទៅរកបន្លែនៅជិតភូមិបឹងធំខាងកើតថា ម្ដាយរបស់គាត់ឈឺនៅផ្ទះ ។ ខ្ញុំទទួលបានការអនុញ្ញាតពីនារី រឹម ធ្វើដំណើរមកសួរសុខទុក្ខម្ដាយជាមួយនារី យន នៅភូមិព្រៃទទឹង និងនារី ពូ នៅភូមិស្នាមគួរដែលមានចម្ងាយប្រហែលជាង៣០គីឡូម៉ែត្រ ។ ខ្ញុំ មកដល់ផ្ទះនៅវេលាម៉ោង៦ល្ងាច ឪពុកគាត់បានទៅសុំបាយពីរោងសហករណ៍មកឲ្យគាត់ហូប ។ ពេលជួបបងប្អូនហើយ ម្ដាយរបស់ ខ្ញុំ ក៏យំរួចប្រាប់ថា «ឲ្យខ្ញុំត្រឡប់មករស់នៅជាមួយគ្រួសារវិញទៅ ទោះបីជាមិនមានអាហារគ្រប់គ្រាន់យ៉ាងណាក្ដី» ។ ប៉ុន្ដែ ខ្ញុំ បានបដិសេធ ព្រោះខ្លាចប្រធានកងសរសេរសំបុត្រមកឃុំឲ្យបញ្ជូនទៅកន្លែងលត់ដំនៅត្រើយកោះ ។ ស្នាក់នៅផ្ទះ២យប់ ខ្ញុំ ក៏ប្រញាប់ត្រឡប់ទៅនៅកងវិញ ។

## សហករណ៍សំរោង

ខែកក្កដា ឆ្នាំ១៩៧៧ អង្គការបានធ្វើលិខិតខុទ្ទេសនាម និងចាត់តាំងកងរបស់ ខ្ញុំ ចំនួន១០នាក់ឲ្យទៅគ្រប់គ្រងនៅសហករណ៍ភូមិសំរោង ឃុំបឹងបត់កណ្ដាល ស្រុកបាកាន ខេត្តពោធិ៍សាត់ ។ នៅទីនេះដំបូង ខ្ញុំ បានទៅសុំអង្ករពីប្រធានកងសេដ្ឋកិច្ចភូមិសំរោងបានតែមួយកំប៉ុងកន្លះនិងប្រហុកបន្ដិចបន្តួចប៉ុណ្ណោះ ។ ៣ថ្ងៃក្រោយមកអង្គការចាប់ផ្ដើមបែងចែកការងារឲ្យ ខ្ញុំ និងសមាជិកចំនួន១០០នាក់ដែលជម្លៀសពីភ្នំពេញ និងខេត្តផ្សេងទៀតចុះធ្វើស្រែប្រាំង និងស្រែវស្សា ។ កប ជាប្រធានកងរយត្រួតពិនិត្យពីលើ ។ ពេលស្ទូងម្ដងៗ កប បានចងខ្សែលួសឲ្យស្ទូងជាក្រឡាបួនជ្រុងស្មើ បើអ្នកណាស្ទូងឃើតមិនត្រង់ជួរត្រូវវាយនឹងខ្សែលួស ។ ចំណែកសំណាបម្នាក់ត្រូវដកឲ្យបាន២០កណ្ដាប់ក្នុងមួយថ្ងៃ បើធ្វើមិនហើយត្រូវធ្វើរហូតដល់យប់ទើបអាចសម្រាកនិងទទួលបានរបបអាហារអង្ករ១កំប៉ុង សម្រាប់១០នាក់ ។ ដោយសារ ខ្ញុំ ជាមនុស្សចំណូលថ្មីនារី កប បានបញ្ជាកងឈ្លបនៅជាមួយតាមដានគាត់ព្រោះខ្លាចធ្វើសកម្មភាពប្រឆាំង ។ នៅពេលរកកំហុសមិនឃើញអង្គការចាត់តាំងឲ្យ ខ្ញុំ ធ្វើមេកងជំនួស កប វិញ ។ នៅរដូវច្រូតស្រូវ ខ្ញុំ ដើរត្រួត

ពិនិត្យមើលការងាររកងដឹកជញ្ជូនស្រូវទៅដាក់ជង្រុកដើម្បីផ្គត់ផ្គង់ទៅរោង-បាយ ។ ខ្ញុំ តែងតែអនុគ្រោះដល់អ្នកមានកំហុសដូចជាធ្វើការយឺត និងលួចអង្ករបស់អង្គការជាដើម ដូច្នេះហើយទើបទទួលបានការគោរពរាប់អានពីសមាជិក ថែមទាំងស្នើសុំឲ្យ ខ្ញុំ បន្តធ្វើជាមេកងទៀតផង ។ យូរៗម្តង រ៉េម ជាគណៈស្រុកបាកានចុះទៅប្រជុំនៅសហករណ៍សំរោង ដោយលើកពីការវិវត្តរបស់អង្គការ ហើយត្រូវដើរតាមការដឹកនាំរបស់បក្សជាដាច់ខាត ។ ខ្ញុំបញ្ជាក់ថា នៅក្នុងកងផ្សេង កងឈ្លបតែងតាមដាន ពិសេស អ្នកខ្ជិលធ្វើការងារ អ្នកលួចសម្ភារៈរបស់អង្គការ ជាអតីតទាហាន ឬជានិស្សិត រួចចាប់យកទៅសម្លាប់នៅឃុំរំលេច ស្រុកបាកាន ។

នៅឆ្នាំ១៩៧៩ ទោះជាកងទ័ពវៀតណាម និងកងទ័ពរណៈសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជាវាយចូលដល់ស្រុកបាកានក៏ដោយ ក៏គ្មាននរណាម្នាក់នៅសហករណ៍សំរោងហ៊ានរត់ចេញពីកងដែរ ព្រោះគ្មានបញ្ជាពីអង្គការថ្នាក់លើ ។ មិនយូរប៉ុន្មានសំឡេងគ្រាប់ផ្លោងនិងរថក្រោះកាន់តែខិតចូលមកជិតភូមិ ខ្ញុំ និង យ៉ុត ប្រធានចុងភៅបានសម្រេចចិត្តភៀសខ្លួនទៅទំនប់ដំណាក់ចង្រ្កម ក្នុងស្រុកភ្នំក្រវាញ ។ តាមផ្លូវធ្វើដំណើរ កងទ័ពខ្មែរក្រហមបានឃោសនាថា «វៀតណាមច្បាស់ជា អារ-ក បើសិនជាមិនរត់ភៀសខ្លួនទេ» ។ ឮពាក្យនេះ ខ្ញុំ ក៏បន្តទៅរស់នៅលើភ្នំក្រវាញមួយរយៈ ប៉ុន្តែក្រោយមក ដោយគ្មានជំនឿទៅលើខ្មែរក្រហម ហើយខ្វះស្បៀងអាហារសម្រាប់បរិភោគ ខ្ញុំ ក៏ត្រឡប់មករស់នៅជាមួយមីងនៅភូមិបាក់ចិញ្ចៀន ឃុំបាក់ចិញ្ចៀន ស្រុកភ្នំក្រវាញវិញ ។ ការរស់នៅរបស់ ខ្ញុំ បានការឧបត្ថម្ភពីមីង ក្រោយមកមានបុរសម្នាក់បានសុំរៀបការនិងធានាចិញ្ចឹម ប៉ុន្តែត្រូវ ខ្ញុំ បដិសេធដោយមូលហេតុថា ស្រុកកំពុងមានសង្រ្គាម ម្យ៉ាងវិញទៀតមិនមានឪពុកម្តាយ និងបងប្អូនញាតិមិត្តដឹងឮ ។

### អាពាហ៍ពិពាហ៍គ្មានមេបា

ក្រោយមក ដោយគ្មានអ្នកជួយធ្វើការងារនិង អសន្តិសុខក្នុងភូមិ នៅចុងឆ្នាំ១៩៧៩ ខ្ញុំ បានរៀបការជាមួយបុរសឈ្មោះ ព្រាប សុផាត ។ នៅក្នុងភូមិកងទ័ពខ្មែរក្រហមមួយចំនួនដែលរស់នៅក្នុងព្រៃតែងចេញមកប្លន់ដណ្តើមយកអង្ករនិងរទេះគោពីប្រជាជនក្នុងភូមិជាញឹកញាប់ ខ្ញុំ ក៏ផ្លាស់មករស់នៅទីរួមខេត្តពោធិសាត់ ប្រកបមុខរបរបិតស្រាវិញ ។ មួយឆ្នាំក្រោយមក ខ្ញុំ និងប្តី ក៏ផ្លាស់ទៅរស់នៅជំរំ០៧ ព្រំដែនថៃ ក្រោមការឧបត្ថម្ភពីកាកបាទក្រហមអន្តរជាតិ ។ នៅទីនោះ ខ្ញុំ និងប្តីបានផ្លាស់ប្តូរមុខរបរជាច្រើនដើម្បីយកលុយមកផ្គត់ផ្គង់ជីវភាព ប៉ុន្តែដោយមានអំពើចោរកម្ម ខ្ញុំ បានសម្រេចចិត្តត្រឡប់មករស់នៅភូមិកំណើតវិញ ។ ខ្ញុំ បញ្ជាក់ថា គាត់រន្ធត់ចិត្តពេលឮឪពុកម្តាយប្រាប់ថា បានធ្វើបុណ្យឧទ្ទិសកុសលជូនគាត់ ដោយនឹកថាស្លាប់ទៅហើយ ។ ក្រោយមកប្តីរបស់ ខ្ញុំ ត្រូវបានប្រជាជនក្នុងភូមិស្នើសុំឲ្យធ្វើជាគ្រូបង្រៀន ប៉ុន្តែ ខ្ញុំ បានបដិសេធ ព្រោះចង់ឲ្យគាត់ទៅធ្វើជំនួញវិញ ។ មួយរយៈក្រោយមកប្តីរបស់គាត់បានចូលធ្វើជាអ្នកលេងភ្លេងប្រចាំស្រុកកំពង់ត្រាចដោយមានការជួយឧបត្ថម្ភពីរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជាដោយបានទទួលរបបសាប៊ូ ប្រេងកាត អង្ករ និងលុយបន្តិចបន្តួចសម្រាប់ចិញ្ចឹមគ្រួសារ ។

នៅឆ្នាំ១៩៨៧ ប្តីរបស់ខ្ញុំត្រូវខ្មែរក្រហមលបបាញ់សម្លាប់ពេលកំពុងជិះឡានជាមួយចៅហ្វាយស្រុកកំពង់ត្រាច នៅភូមិលកឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត (ជាប់ព្រំដែនវៀតណាម) ។ សព្វថ្ងៃ ខ្ញុំ ជាស្ត្រីមេម៉ាយប្រកបមុខរបរធ្វើនំបញ្ចុកនិងចិញ្ចឹមសត្វដើម្បីចិញ្ចឹមកូនស្រី២នាក់ ។

នៅពេលរំឭកដល់សម័យខ្មែរក្រហម ខ្ញុំ ចង់ឲ្យមេដឹកនាំខ្មែរក្រហមទទួលខុសត្រូវចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តមកលើប្រជាជនស្លូតត្រង់និងចង់ឲ្យនាំមេខ្មែរក្រហមមកកាត់ទោសដើម្បីផ្តល់យុត្តិធម៌ដល់ជនរងគ្រោះនិងឲ្យក្មេងជំនាន់ក្រោយបានដឹងឮ ។

**សោម ប៊ុនថន**



អ្នកភូមិក្នុងស្រុកកងមាស

# គុកខ្មែរក្រហម

(តចប់)

## ស្រុកព្រៃឈរ

### ១) មន្ទីរសន្តិសុខវត្តតាមាក់



មន្ទីរសន្តិសុខវត្តតាមាក់

បរិវេណវត្តជនតាណារាមទាំងមូល ហៅវត្តតាមាក់ត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខរបស់ខ្មែរក្រហម ។ វត្តតាមាក់ស្ថិតក្នុងភូមិស្វែង ឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ មន្ទីរសន្តិសុខនេះបានដំណើរការតាំងពីឆ្នាំ១៩៧៣ ប៉ុន្តែកាលនោះនៅជាមន្ទីរអប់រំកែប្រែរបស់ខ្មែររំដោះនៅឡើយ ។

ចាប់ពីឆ្នាំ១៩៧៥ មន្ទីរអប់រំកែប្រែនេះត្រូវបានប្រែក្លាយឲ្យទៅជាមន្ទីរសន្តិសុខវិញ ។ នៅមុនថ្ងៃជ័យជម្នះទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្នុងមន្ទីរអប់រំកែប្រែនៅវត្តតាមាក់មានអ្នកទោសជាច្រើន ។ ដែលអ្នកទាំងនោះជាទាហាន នគរបាលជីវពល ប្រធានឃុំ ជំទប់ឃុំ និងប្រជាជនខ្លះដែលនិយមរបបសាធារណរដ្ឋខ្មែរ ។ ការសម្លាប់បានកើតឡើងសម្រាប់អ្នកទោសដែលអប់រំមិនបាននិងអ្នកដែលចចេសរឹងរូស ។ ចាប់តាំងពីថ្ងៃជ័យជម្នះ មន្ទីរសន្តិសុខវត្តតាមាក់បានត្រូវខ្មែរក្រហមពង្រីកទីតាំងដោយយកកុដិទាំងអស់របស់វត្តតាមាក់ធ្វើជាមន្ទីរឃុំឃាំងអ្នកទោសដែលបញ្ជូនមកពីទីក្រុងភ្នំពេញនិងពីស្រុកមួយចំនួន ។ ការពង្រីកនេះមានទំហំលើសមុន២ដងបើប្រៀបធៀបនឹងមន្ទីរអប់រំកែប្រែពីមុន ។ កុដិចំនួន៥ និងសាលាឆាន់ចំនួន២ ត្រូវកងសន្តិសុខយកធ្វើជាកន្លែងឃុំឃាំងទាំងអស់ ។ ក្រៅពីនេះ ផ្ទះរបស់ ជុន ទូច ដែលស្ថិតនៅប៉ែកខាងក្រោយរបងវត្តតាមាក់ក៏ត្រូវដកហូតមកធ្វើជាមន្ទីរដាំបាយសម្រាប់មន្ទីរសន្តិសុខទាំងមូលដែរ ។ ការឃុំឃាំងមនុស្សនៅវត្តតាមាក់លើកក្រោយនេះគឺមានអ្នកទោសគ្រប់ប្រភេទដែលយកមកពីកន្លែងផ្សេងៗគ្នា ដូចជាពីស្រុកកងមាស បាធាយ ព្រៃឈរ ជើងព្រៃ និងប្រជាជនជម្លៀសមួយចំនួនទៀត ។

ជុន ចំរើន អាយុ៦១ឆ្នាំ ជាអាចារ្យវត្តតាមាក់បានរាយការណ៍ថា គាត់បានឃើញឈ្លបបណ្តើរអ្នកទោសចូលក្នុងមន្ទីរឃុំឃាំងវត្តតាមាក់ស្ទើរតែរាល់ថ្ងៃ ហើយអ្នកទាំងនោះសុទ្ធតែជ្រើសរើសចេញពីសហករណ៍នានាទូទាំងស្រុក ។ ចំរើន បានឲ្យដឹងទៀតថា មុនដំបូងជនរងគ្រោះទាំងនោះត្រូវជាប់ក្នុងគុកធំនៅ ឃុំថ្មពូនសិន បន្ទាប់មកទើបបញ្ជូនមកកាន់មន្ទីរឃុំឃាំងនៅភូមិតាទិត្យ ហើយចុងក្រោយបង្អស់បញ្ជូនមកកាន់វត្តតាមាក់ ។ ចំណែកកម្មាភិបាលបដិវត្តន៍ដែលអង្គការសង្កេតឃើញថាប្រព្រឹត្តខុសឆ្គងនឹងមាគ៌ាបដិវត្តន៍ក៏ត្រូវបញ្ជូនខ្លួនមកកាន់មន្ទីរសន្តិសុខនៅវត្តតាមាក់នេះដែរ ។ ចាប់ពីព្រលឹមរហូតដល់ម៉ោង៥ល្ងាចខ្មែរក្រហមបានបញ្ចេញអ្នកទោសទាំងអស់ឲ្យទៅធ្វើការងារជាប្រចាំដូចជា លើកទំនប់ ស្ទូងស្រូវ និងបាចទឹកបញ្ចូលស្រែជាដើម ហើយពេលយប់ត្រូវបញ្ចូលក្នុងកុដិដើម្បីដាក់ខ្នោះវិញ ។ នៅចុងឆ្នាំ ១៩៧៨ អ្នកទោសនៅមន្ទីរសន្តិសុខវត្តតាមាក់ត្រូវកងសន្តិសុខសម្លាប់ចោលទាំងអស់ ។

នៅក្រោយឆ្នាំ១៩៧៩ បរិវេណវត្តទាំងមូលត្រូវបានអ្នកស្រុកបំផ្លាញស្ទើរគ្មានសល់ ។ សំណល់វត្ថុតាងជាច្រើនដូចជាខ្នោះ ឃ្នាង រនុកដែក ស្នាមចោះជញ្ជាំងដើម្បីភ្ជាប់គន្លឹះសោត្រូវប្រជាជនរើយកទៅបោះចោល និងបិទស្នាមប្រហោងទាំងនោះជិតឈឹង ។

### ២) មន្ទីរសន្តិសុខមិត្តសុប

មន្ទីរសន្តិសុខមិត្តសុប ឬមន្ទីរសន្តិសុខតំបន់៤១ មានទីតាំង

នៅក្នុងភូមិតាកែវ ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ មន្ទីរនេះមានអគារ៤ខ្នងដែលសាងសង់ឡើងរបៀបសាលារៀនដំបូលប្រក់ក្បឿង ជញ្ជាំងក្តារ ហើយក្នុងមួយខ្នងៗមានប្រវែង បណ្តោយ ១២ម៉ែត្រ និងទទឹង៦ម៉ែត្រ ។ មន្ទីរនេះគ្រប់គ្រងដោយ មិត្ត សុប ដែលមានស្រុកកំណើតនៅឃុំសំរោង ស្រុកព្រៃឈរ ។ បច្ចុប្បន្ន មន្ទីរសន្តិសុខដែលមានផ្ទៃដីទំហំ៦០ម៉ែត្រ ទទឹង និងបណ្តោយ ១០០ម៉ែត្រនេះបានក្លាយជាដីកម្មសិទ្ធិរបស់លោក តាហ៊ុល យាយសៀប ។ ស្រះទឹកចំនួនបី ដែលជីកដោយកម្លាំងអ្នកទោសនៅមាននៅឡើយក្នុងអតីតបរិវេណមន្ទីរសន្តិសុខតំបន់៤១នេះ ។

ណៃ គឹមសាន់ អាយុ៥៣ឆ្នាំ មានស្រុកកំណើតនៅភូមិតាមាស ឃុំគរ ស្រុកព្រៃឈរ បច្ចុប្បន្នជាជំទប់លេខ២ ឃុំគរ ស្រុកព្រៃឈរ និយាយថា កាលពីជំនាន់ខ្មែរក្រហមមន្ទីរសន្តិសុខ មិត្តសុប មានឃុំឃាំងអ្នកទោសភាគច្រើនជាអ្នកជាប់និន្នាការ និង ទាហានរបបសាធារណរដ្ឋខ្មែរ ។ អ្នកទោសទាំងអស់ត្រូវកងសន្តិសុខដាក់ខ្នោះជាប់ជាប្រចាំសូម្បីតែពេលបាយ ពេលបត់ជើង ពេលដេកក៏មិនត្រូវដោះចេញដែរ ។ នៅពេលបរិភោគបាយម្តងៗ អ្នកទោសត្រូវដេកផ្ងាល់នឹងដីដើម្បីហូប ហើយពេលបត់ជើងធំម្តងៗមានពាងតូចល្មមមួយម្នាក់សម្រាប់ដាក់លាមកខ្លួនឯង ។ គ្មានការប្រជុំឬការអប់រំបំពាក់បំប៉នអ្វីដល់អ្នកទោសក្រៅតែពីបញ្ជាឲ្យអ្នកទោសចេញទៅធ្វើការងារនៅម៉ោង៧ព្រឹក និងត្រឡប់ចូលមកវិញនៅម៉ោង៦ល្ងាចប៉ុណ្ណោះ ។ ណៃ គឹមសាន់ ប្រាប់ថា អ្នកទោសទាំងប៉ុន្មានដែលជាប់ក្នុងមន្ទីរសន្តិសុខគ្មាននរណាម្នាក់គេចផុតពីសេចក្តីស្លាប់ឡើយ ។ សាកសពជនរងគ្រោះ ត្រូវសែងយកទៅកប់នៅទួលក្រសាំង ត្នោតជួរ អូរតាគង់ និងទួលដើមអម្ពិល ។

រហូតមកដល់សព្វថ្ងៃនេះអតីតមន្ទីរសន្តិសុខតំបន់៤១បានបន្សល់ទុកស្លាកស្នាមជាស្រះទឹកចំនួនបីដែលកាលនោះប្រធានសន្តិសុខបានឲ្យអ្នកទោសជីកដើម្បីយកទឹកមកប្រើប្រាស់ក្នុងមន្ទីរសន្តិសុខទាំងមូល ។ ដើមឫស្សីដើមត្នោតដែលដុះលូតលាស់យ៉ាងល្អសម្រាប់សម្គាល់របងអតីតមន្ទីរសន្តិសុខផង និងជារបងសម្គាល់ព្រំដីរវាងម្ចាស់មួយនិងម្ចាស់មួយទៀតផង ។

## ៣) មន្ទីរសន្តិសុខស្រុក៧៧លើ

មន្ទីរសន្តិសុខស្រុក៧៧លើ ស្ថិតនៅភូមិអណ្តូងតាពេជ្រ ឃុំថ្មពូន ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។ នៅឆ្នាំ១៩៧៣ ឃុំថ្មពូនជាទឹកដីមួយស្ថិតក្នុងតំបន់ខ្មែររំដោះ ។ ប្រជាជនដែលមិនទាន់ជម្រុះចោលគំនិតស្ទួនត្បូត្រូវអង្គការចាប់ខ្លួនយកទៅអប់រំ ហើយមួយចំនួនទៀតបានភៀសខ្លួនចេញពីស្រុកកំណើតទៅកាន់កន្លែងឆ្ងាយៗដើម្បីគេចឲ្យផុតពីការតាមចាប់ខ្លួន ។ គេហដ្ឋានរបស់ អ៊ឹម ចន ត្រូវខ្មែររំដោះយកធ្វើជាមន្ទីរអប់រំកែប្រែ ។

ចាប់ពីខែមេសា ឆ្នាំ១៩៧៥ មន្ទីរអប់រំកែប្រែបានផ្លាស់ប្តូរប្រព័ន្ធគ្រប់គ្រងរបស់ខ្លួនទៅជាការគ្រប់គ្រងបែបផ្តាច់ការ និងឃោរឃៅបំផុត ។ ភិន គឺជាអ្នកគ្រប់គ្រងមន្ទីរអប់រំកែប្រែតាំងពីឆ្នាំ ១៩៧៣ ដល់ឆ្នាំ១៩៧៦ ។ ចាប់ពីចុងឆ្នាំ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ ភិន ត្រូវអង្គការផ្លាស់ចេញដោយដាក់ឈ្មោះ ថាន់ ឲ្យធ្វើជាអ្នកគ្រប់គ្រងមន្ទីរសន្តិសុខស្រុក៧៧លើជំនួសវិញ ។ ទាំងប្រជាជនថ្មីដែលជម្លៀសមកពីទីក្រុងភ្នំពេញ និងប្រជាជនមូលដ្ឋានដែលធ្វើខុសអង្គការវិន័យសុទ្ធតែត្រូវខ្មែរក្រហមនាំខ្លួនទៅដាក់ឃុំនៅមន្ទីរសន្តិសុខ ស្រុក៧៧លើនេះ ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ មន្ទីរសន្តិសុខស្រុក៧៧លើត្រូវអង្គការរំសាយចោលដោយកែប្រែឲ្យទៅជាកន្លែងចិញ្ចឹមគោក្របីវិញ ។

# ស្រុកស្រីសន្ធរ

## ៤) មន្ទីរសន្តិសុខវត្តជ័យមង្គល

មន្ទីរសន្តិសុខវត្តជ័យមង្គល ស្ថិតនៅក្នុងភូមិព្រែកជ្រើង ឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ ចម្ងាយ១៥គីឡូ ម៉ែត្រពីភូមិព្រែកពោធិ៍ប៉ែកខាងត្បូង ។ សាលារៀននៅក្នុងវត្តជ័យមង្គលដែលជាអតីតរោងចក្រតម្បាញរបស់ខ្មែរក្រហម កាលពីអំឡុងឆ្នាំ ១៩៧៦ និងម៉ាស៊ីនភ្លើងរបស់រោងចក្រតម្បាញ នេះបានក្លាយជាឧបករណ៍សម្លាប់មនុស្សយ៉ាងសាហាវនៅចុងឆ្នាំ១៩៧៧ ។ ប្រជាជនមូលដ្ឋានជាច្រើននាក់ដែលធ្លាប់មានភក្តីភាពចំពោះសមមិត្ត សោភឹម ប្រធានភូមិភាគបូព៌ាបានត្រូវសម្លាប់នៅនឹងវត្តជ័យមង្គលនេះ ។ ប្រជាជនមូលដ្ឋាននៅតាមភូមិនានាបានត្រូវកោះហៅឲ្យមកចូលរួមស្តាប់ការប្រជុំនៅវត្តជ័យមង្គល ។ នៅពេលមកដល់បរិវេណវត្តក៏ត្រូវកងឈ្លបចាប់ដាក់ខ្នោះភ្ជាមនិងបន្ទាំងទុក ១ឬ២ថ្ងៃនៅក្នុងទីវត្តជ័យមង្គលមុននាំទៅសម្លាប់ចោល ។ ការសម្លាប់បានប្រព្រឹត្ត

ទៅតាមវិធីមួយប្លែកពោលគឺយកកឹតម្បាញដែលប្រើចរន្តអគ្គិសនីតពីម៉ាស៊ីនភ្លើង មកភ្ជាប់ទៅនឹងកូនសោខ្នោះដែលដាក់លើអ្នកទោសទាំងអស់ ប្រសិនបើអ្នកទោសណាម្នាក់ហ៊ានលួចយកកូនសោចេញពីកឹតម្បាញនោះមកចាក់ខ្នោះខ្លួនឯងនឹងត្រូវឆក់ស្លាប់ភ្លាមដោយមិនចាំបាច់នាំយកទៅសម្លាប់ ។ សាក្សីនិយាយថា អ្នកទោសខ្លះត្រូវឆក់ស្លាប់និងខ្លះទៀតត្រូវសន្លប់បាត់ស្មារតី ។ សាក្សីបានប្រាប់ថា ប្រធានសន្តិសុខនៅវត្តជ័យមង្គលឈ្មោះ ហែម ។ ហែម បានរត់គេចខ្លួនតាំងពីថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ម្ល៉េះ ។

## ៥) មន្ទីរសន្តិសុខគុកតាដួង វត្តប្រាសាទវត្តី

វត្តតាដួងស្ថិតនៅភូមិតាម៉ឺន ឃុំព្រែកដំបូក ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ចម្ងាយ៧គីឡូម៉ែត្រពីភូមិព្រែកពោធិ៍ប៉ែកខាងត្បូង ។ កាលពីឆ្នាំ១៩៧៦ វត្តតាដួងត្រូវបានប្រើប្រាស់ធ្វើជាមន្ទីរសន្តិសុខសម្រាប់ឃុំឃាំងមន្ត្រីរដ្ឋការសម័យ លន់ នល់ និង ប្រជាជនជម្លៀសមកពីទីរួមខេត្តកំពង់ចាមនិងទីក្រុងភ្នំពេញ ។ មន្ទីរសន្តិសុខនេះជាមន្ទីរសន្តិសុខប្រចាំតំបន់២២ ។ នៅឆ្នាំ ១៩៧៨ បន្ទាប់ពីប្រធានភូមិភាគបូព៌ាត្រូវមជ្ឈិមតាមរកចាប់ខ្លួន កងឈ្លបខ្មែរក្រហមខាងភូមិភាគនិរតីបានចាប់ប្រជាជនមូលដ្ឋានយ៉ាងច្រើនដែលធ្លាប់មានភក្តីភាពចំពោះ សោ ភឹម យកមកដាក់នៅមន្ទីរសន្តិសុខវត្តតាដួងហើយបន្ទាប់មកត្រូវសម្លាប់ចោលទាំងអស់ ។

ពៅ គឺជាប្រធានគ្រប់គ្រងមន្ទីរសន្តិសុខនេះទាំងមូល ។ នៅឆ្នាំ១៩៧៩ ពៅ បានរត់គេចខ្លួនបាត់ ។ អតីតជនរងគ្រោះម្នាក់ដែលនៅមានជីវិតរហូតមកដល់បច្ចុប្បន្នបានឲ្យដឹងថា កន្លែងសម្លាប់គឺនៅជាប់នឹងបរិវេណវត្ត តាដួងតែម្តង ។

## ៦) មន្ទីរសន្តិសុខនៅវិទ្យាល័យស្រីសន្ធរ

មន្ទីរសន្តិសុខតំបន់មួយត្រូវបានបង្កើតឡើងនៅដើមឆ្នាំ១៩៧៣នៅវិទ្យាល័យស្រីសន្ធរ បន្ទាប់ពីស្រុកស្រីសន្ធរក្លាយជាតំបន់រំដោះ ។ ឈ្លើយសឹកជាទាហានរបស់របបសាធារណរដ្ឋខ្មែរជាច្រើនត្រូវខ្មែរក្រហមបញ្ជូនមកឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខនេះ ។ អ្នកទោសទាំងនោះត្រូវកងសន្តិសុខបែងចែកជាប្រភេទធ្ងន់ និងប្រភេទស្រាល ។ អ្នកទោសបុរសត្រូវដាក់ឃុំឃាំងឲ្យនៅដាច់ដោយឡែកពីស្ត្រី ។ អគារមួយដែលមានពីរជាន់ស្ថិតនៅទល់មុខដងទង់ជាតិគឺជាមន្ទីរឃុំឃាំងអ្នកទោស ។

តេក មាស ត្រូវរស់នៅបែកពីប្តីរបស់គាត់ក្នុងមន្ទីរសន្តិសុខនេះដែលមានទីតាំងនៅក្នុងបរិវេណវិទ្យាល័យស្រីសន្ធរ ។ តេក មាស ជាអតីតអ្នកទោសដែលជាប់ចោទពីរឿងធ្លាប់បានបំពាក់កម្រងផ្កាឲ្យសម្តេច និងមានប្តីធ្វើជាតម្រួតយោធាកាលពីជំនាន់សាធារណរដ្ឋខ្មែរ ។ បច្ចុប្បន្ន តេក មាស រស់នៅប្រទេសអូស្ត្រាលី ។ មាស បានប្រាប់ថាគាត់ជាប់គុកចំនួនបីកន្លែង ពីដំបូងជាប់នៅវិទ្យាល័យស្រីសន្ធរ បន្ទាប់មកនៅវត្តទូរី និងចុងក្រោយបង្អស់មកជាប់នៅស្រុកពារាំង ខេត្តព្រៃវែង ។ ក្នុងរយៈពេលជាប់ឃុំឃាំងនៅវិទ្យាល័យស្រីសន្ធរ មាសមានការលំបាកយ៉ាងខ្លាំង ទាំងការហូបចុក ការធ្វើការងារ និងការរស់នៅ ។ បន្ទប់ឃុំឃាំងនីមួយៗមានតែពាងទឹកមួយសម្រាប់ដាក់លាមកអ្នកទោសប៉ុណ្ណោះ ។ មាស បានត្អូញត្អែរថា គាត់កើតរមាស់ពេញខ្លួន ហើយអ្នកទោសជាច្រើនទៀតក៏មានសភាពដូចគាត់ដែរ ។ ដូឡុង វង្សី និងអ្នកមានពូជពង្សវង្សត្រកូលស្តេចម្នាក់ទៀតមិនចាំឈ្មោះក៏ជាប់ទោសនៅក្នុងមន្ទីរសន្តិសុខវិទ្យាល័យស្រីសន្ធរនេះដែរ ។ នៅឆ្នាំ១៩៧៥ អ្នកទោសភាគច្រើនត្រូវកម្មាភិបាលគ្រប់គ្រងមន្ទីរបញ្ជូនទៅកាន់កន្លែងផ្សេងៗគ្នាដូចជា តេក មាស ត្រូវបញ្ជូនទៅកាន់មន្ទីរសន្តិសុខមួយទៀតឈ្មោះមន្ទីរសន្តិសុខ ទូរី ស្ថិតនៅក្នុងស្រុកស្រីសន្ធរ ហើយ ដូឡុង វង្សី និងអ្នកដែលមានពូជពង្សស្តេចត្រូវបញ្ជូនមកភ្នំពេញ ។

នៅចុងឆ្នាំ១៩៧៥ មន្ទីរសន្តិសុខនេះត្រូវបានរំលាយចោលបន្ទាប់ពីសម្លាប់អ្នកទោសធ្ងន់និងដោះលែងអ្នកទោសស្រាល ។ ប្តីរបស់ តេក មាស ត្រូវកងឈ្លបសម្លាប់ពីបទជាប់និន្នាការនយោបាយពីសង្គមចាស់ ។ ទៀង អូន អាយុ៤១ឆ្នាំ ជាជាងម៉ាស៊ីនភ្លើងនៅភូមិព្រែកពោធិ៍ក្រោម ឃុំព្រែកពោធិ៍ បាននិយាយថាការសម្លាប់មនុស្សនៅក្នុងបរិវេណវិទ្យាល័យស្រីសន្ធរបានចាប់ផ្តើមនៅឆ្នាំ១៩៧៤ ហើយបញ្ចប់នៅចុងឆ្នាំ១៩៧៥ ។ បន្ទាប់ពីបានរំលាយមន្ទីរសន្តិសុខនេះ ខ្មែរក្រហមពុំបានយកទីតាំងនេះធ្វើអ្វីផ្សេងទៀតឡើយ ហើយក៏មិនអនុញ្ញាតឲ្យប្រជាជនណាម្នាក់ ចូលទៅក្នុងបរិវេណនោះដែរ ។

ក្រោយថ្ងៃរំដោះឆ្នាំ១៩៧៩ អតីតមន្ទីរសន្តិសុខនេះត្រូវបានរៀបចំនិងបោសសម្អាតឡើងវិញ ហើយបច្ចុប្បន្នគឺជាវិទ្យាល័យដ៏ល្អស្អាតមួយ ។

## ៧) មន្ទីរសន្តិសុខវត្តព្រែកពោធិ៍មង្គល

បរិវេណវត្តព្រៃកពោធិ៍បានត្រូវខ្មែរក្រហមយកធ្វើជាមន្ទីរសន្តិសុខនិងទីតាំងសម្លាប់មនុស្សនៅចន្លោះឆ្នាំ១៩៧៦ និង ១៩៧៨ ។ វត្តព្រៃកពោធិ៍មង្គល ស្ថិតនៅក្នុងភូមិព្រៃកពោធិ៍ក្រោម ឃុំព្រៃកពោធិ៍ ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម ។ បន្ទាប់ពីមន្ទីរសន្តិសុខនៅវិទ្យាល័យស្រីសន្ធរត្រូវបិទទ្វារការឃុំឃាំង និង ការសម្លាប់មនុស្សនៅក្នុងវត្តព្រៃកពោធិ៍មង្គលបានចាប់ផ្តើមឡើង ។ ព្រះវិហារ និងសាលាឆាន់ត្រូវបានយកធ្វើជាមន្ទីរឃុំឃាំងអ្នកទោសរយៈពេលខ្លីដែលភាគច្រើនជាប្រជាជន១៧មេសា អ្នកជាប់និន្នាការពីសង្គមចាស់ និងអ្នកជាប់ខ្សែយួន ចាម ចិន ។ ទៀង អួន បានរាយការណ៍ពីមូលហេតុនៃការចាប់ខ្លួនថាមកពីអ្នកទាំងនេះបំផ្លិចបំផ្លាញសមិទ្ធផលបដិវត្តន៍លើគ្រប់វិស័យ ។ អ្នកទោសទាំងអស់ពុំមានធ្វើការងារអ្វីក្រៅពីជាប់ខ្នោះទាំងយប់ទាំងថ្ងៃ ត្រៀមចាំឈ្លបកោះហៅទៅសួរចម្លើយប៉ុណ្ណោះ ។ នៅពេលសួរចម្លើយម្តងៗអ្នកទោសត្រូវបានបញ្ជាឲ្យដោះសម្លៀកបំពាក់ចេញទាំងអស់មិនថា បុរសឬស្ត្រីទេ ។ គំនរខោអាវរបស់ជនរងគ្រោះមានស្ថិតនៅលើខឿនព្រះវិហារ និងនៅលើសាលាឆាន់ ។ ការសម្លាប់បានប្រព្រឹត្តទៅនៅពេលយប់ចាប់ពីម៉ោង៧រហូតដល់ម៉ោង៨ទៀបភ្លឺ ។ ជួនកាលបន្តរហូតដល់ម៉ោង៧ព្រឹកទៀត ។ នៅឆ្នាំ១៩៧៨ ការសម្លាប់មនុស្សបានកើនឡើងទ្វេដង ។ ឧបករណ៍សំខាន់ក្នុងការសម្លាប់គឺដំបងនិងដែកក្ងោរទេះ ។ រណ្តៅធំៗដែលជីករួចជាស្រេចនៅតាមចន្លោះដើមដូងស្ថិតនៅប៉ែកខាងជើងនិងខាងត្បូងព្រះវិហារ គឺត្រៀមសម្រាប់កប់សាកសពដែលកងឈ្លបសម្លាប់ ។ ទៀង អួន បានអះអាងថា គាត់ជាអ្នកសែងខ្មោចអ្នកទោសយកទៅកប់ ។ គាត់រាប់ឃើញមានរណ្តៅចំនួនពី៣០ ទៅ ៤០ ហើយរណ្តៅនីមួយៗមានផ្ទុកសាកសពពី១០ទៅ១៥នាក់ ។

ក្រោយថ្ងៃរំដោះទី៧ ខែមករា ឆ្នាំ១៩៧៩ គំនរខោអាវទាំងប៉ុន្មានត្រូវបានរើដុះរាយប៉ាយពាសវាលពាសកាល ហើយរណ្តៅទាំងប៉ុន្មាន ក៏ត្រូវបានគាស់កកាយក្នុងបំណងស្វែងរកមាសពេជ្រ ។ ចំណែកវត្ថុតាងនានាដូចជា ដំបងនិងដែកក្ងោរទេះរក្សានៅកន្លែងកើតហេតុដដែល ។ រហូតមកដល់សព្វថ្ងៃ វត្តព្រៃកពោធិ៍មង្គលត្រូវបានប្រជាជនធ្វើថ្មីឡើងវិញ ហើយឧបករណ៍ធ្វើឃាតមនុស្សកាលពីជំនាន់ខ្មែរក្រហមត្រូវបំផ្លាញគ្មានសល់ ចំណែករណ្តៅសាកសពត្រូវប្រជាជនកាយដីលុបវិញយ៉ាងស្អាត ។

## ស្រុកត្បូងឃ្មុំ

### ១) មន្ទីរសន្តិសុខចម្ការស្វាយ

ចម្ការស្វាយ ស្ថិតនៅក្នុងភូមិថ្មី ឃុំវិហារលួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ត្រូវបានសាងសង់ឡើងក្នុងអំឡុងឆ្នាំ១៩៧៦ និងមានទីតាំងស្ថិតនៅប៉ែកខាងជើងឃុំស្វួង ។ នៅក្នុងបរិវេណមន្ទីរសន្តិសុខនេះ ខ្មែរក្រហមបានសង់រោងឃុំឃាំងធ្វើអំពីឈើប្រក់ស្លឹកត្នោត និង ជីករណ្តៅធំៗសម្រាប់កប់សាកសពចំនួន១៥ ជីកអណ្តូងទឹកជ្រៅៗចំនួនពីរនិងសង់រោងសួរចម្លើយមួយទៀត ។ ជនរងគ្រោះទាំងអស់ជាទាហានរបបសាធារណរដ្ឋខ្មែរនិងប្រជាជនថ្មីជម្លៀសពីទីក្រុងបានត្រូវសម្លាប់ដាក់នៅក្នុងរណ្តៅទាំង១៥ នេះបន្ទាប់ពីឃុំឃាំងអស់មួយរយៈមក ។ ពីង សឿន ធ្លាប់បានឃើញខ្មែរក្រហមដឹកជនរងគ្រោះតាមរទេះគោមកកាន់មន្ទីរសន្តិសុខ ។ អ្នកទោសត្រូវកងសន្តិសុខបញ្ជាឲ្យដោះសម្លៀកបំពាក់ចេញ ហើយចងមុខជិតមុននឹងបណ្តើរយកទៅសម្លាប់ដោយប្រើពូថៅវាយកញ្ចឹង-ក ឬចាក់នឹងចំពុះទុងទម្លាក់ក្នុងរណ្តៅតែម្តង ។

### ២) មន្ទីរសន្តិសុខសាលារៀនស្វួង


មន្ទីរសន្តិសុខសាលារៀនស្វួង

សាលាស្វួង ស្ថិតនៅក្នុងភូមិស្វួង ឃុំស្វួង ស្រុកត្បូងឃ្មុំ ខេត្តកំពង់ចាម ។ តាំងពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៧ វិទ្យាល័យស្វួងត្រូវខ្មែរក្រហមប្រើប្រាស់ធ្វើជាមន្ទីរឃុំឃាំងអ្នកទោស ។ ក្រុមស្រាវជ្រាវបានជួបសម្ភាសន៍ជាមួយ ឡយ សុខ ដែលធ្លាប់ជាអ្នកទោសនៅមន្ទីរសន្តិសុខវិទ្យាល័យ ស្វួង ហើយក្រោយមកត្រូវបានដោះលែងវិញ ។

**ផេង ពង្សរ៉ាស៊ី**

# ជួបជាមួយជនរងគ្រោះនៅខេត្តកំពត

ឆ្នាំ១៩៧៥ ពេលដែលខ្មែរក្រហមចូលក្នុងភូមិរបស់គាត់ កុយ សា ទើបតែមានអាយុ១០ឆ្នាំប៉ុណ្ណោះ ។ គាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើការនៅក្នុងកងកុមារ ហើយខ្មែរក្រហមបានតម្រូវឲ្យគាត់ធ្វើការបម្រាញ់យកថ្នាំពីដើមរុក្ខជាតិ ។ ពីរឆ្នាំក្រោយមកប្រមាណជានៅឆ្នាំ១៩៧៧ សា ត្រូវបានប្តូរទៅកាន់កងចល័តយុវជននិងត្រូវតម្រូវឲ្យចាប់ផ្តើមហ្វឹកហាត់ដើម្បីប្រយុទ្ធនៅក្នុងសង្គ្រាមជាមួយប្រទេសវៀតណាម ។

ថ្មីៗនេះ នៅខែមករា ឆ្នាំ២០០៨ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានទៅអង្គុយលេងនៅលើកៅអីខាងក្រោផ្ទះរបស់គាត់នៅពេលដែល សា កំពុងតែអានឈ្មោះប្រជាជនដែលមាននៅក្នុងបញ្ជីមួយ នៅក្នុងបញ្ជីនោះក៏មានឈ្មោះរបស់គាត់ដែរ ។ ទាំងនោះគឺជាឈ្មោះរបស់ប្រជាជនដែលបានធ្វើសេចក្តីថ្លែងការណ៍រៀបរាប់អំពីទុក្ខវេទនារបស់ពួកគាត់កាលពីនៅក្រោមរបបខ្មែរក្រហមពី៣០ឆ្នាំមុនទៅឲ្យរដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ។

នៅទសវត្សរ៍ឆ្នាំ១៩៨០ មន្ត្រីរបស់របបសាធារណរដ្ឋប្រជាមានិតកម្ពុជាធ្វើដំណើរទៅជុំវិញប្រទេសដើម្បីប្រមូលសេចក្តីថ្លែងការណ៍បែបនេះពីជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ។ ជាសរុបក្រុមមន្ត្រីបានប្រមូលញត្តិជាង១២៥០ដែលមានហត្ថលេខាឬស្នាមផ្តិតមេដៃពីប្រជាជនជាង១លាននាក់ ។ ឯកសារទាំងអស់នេះត្រូវបានស្គាល់ថាជា «ញត្តិរេណសិរ្ស» ហើយញត្តិនេះក៏ជាផ្នែកមួយនៃកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយអំណាចរបស់ខ្មែរក្រហម និងធ្វើឲ្យអង្គការសហប្រជាជាតិបដិសេធឈប់ទទួលស្គាល់ខ្មែរក្រហមថាជាអ្នកតំណាងស្របច្បាប់របស់កម្ពុជា ។ ញត្តិទាំងអស់នេះមិនដែលបានបញ្ជូនទៅកាន់អង្គការសហប្រជាជាតិទេ ហើយសព្វថ្ងៃនេះញត្តិទាំងនេះកំពុងរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ញត្តិមកពីឃុំដែល សា បានរៀបរាប់ពីស្ថានភាពទូទៅអំពីឧក្រិដ្ឋកម្មដែលកើតឡើងនៅក្នុងរបបខ្មែរក្រហម ដូចជាការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិនិងសត្វពាហនៈ ការកាប់សម្លាប់អ្នកភូមិ ព្រមទាំងការបំបិទសិទ្ធិសេរីភាពនិយាយស្តី ឬបញ្ចេញមតិយោបល់ ។ ញត្តិនេះបានរៀបរាប់ថាក្រោយឆ្នាំ១៩៧៩ នៅក្នុងភូមិមានចំណីអាហារ និងសម្លៀកបំពាក់គ្រប់គ្រាន់សម្រាប់អ្នកស្រុក ។ ទាំងនេះគឺដោយសារតែការជួយពីសំណាក់ប្រទេសវៀតណាម សាធារណរដ្ឋសង្គមនិយមសូវៀត និងប្រទេសសង្គមនិយមដែលមានចិត្តសប្បុរសផ្សេងទៀត ។ អ្នកភូមិចំនួន៣៣៧នាក់បានចុះហត្ថលេខានិងចុះឈ្មោះរបស់ពួកគាត់នៅក្នុងញត្តិនេះ ។

ញត្តិពីឃុំរបស់ សា និងញត្តិជាង១០០០ផ្សេងទៀតបានផ្តល់នូវព័ត៌មានដ៏សន្ធឹកសន្ធាប់អំពីឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។


អ្នកភូមិក្របីចូលពេង ខេត្តក្រចេះ

ដោយសារតែសកម្មភាពនេះត្រូវបានធ្វើឡើងកាលពី៣០ឆ្នាំមុន ពេលដែលហេតុការណ៍នៅក្នុងរបបប៉ុលពតទើបតែបញ្ចប់ទៅភ្លាមៗ ញត្តិទាំងនេះគឺមានលក្ខណៈស្ទើរតែជា «គណៈកម្មការស្វែងរកការពិត» អំពីសម័យខ្មែរក្រហម ។

ក្រៅពីតម្លៃជាប្រវត្តិសាស្ត្រ ញត្តិរណសិរ្សនៅមិនទាន់បានយកទៅប្រើការជាភស្តុតាងនៅក្នុងដំណើរការកាត់ក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅឡើយ ។ តម្លៃជាលក្ខណៈផ្លូវច្បាប់ និងតម្លៃជាភស្តុតាងរបស់ញត្តិទាំងនេះ នៅមិនទាន់ច្បាស់លាស់នៅឡើយ ។ មនុស្សជាច្រើនយល់ឃើញថា ដោយសារហេតុផលនយោបាយរបស់រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ញត្តិទាំងនេះមិនអាចយកថាត្រឹមត្រូវទាំងស្រុងបានទេ ។ ស្ទើរតែគ្រប់ញត្តិទាំងអស់ប្តឹងអំពីឧក្រិដ្ឋកម្ម ខ្មែរក្រហមនិងលើកសរសើរវៀតណាមដែលបានរំដោះកម្ពុជា ។ ញត្តិជាច្រើនមានប្រើប្រាស់ភាសានយោបាយ ហើយអតីតអ្នកធ្វើញត្តិខ្លះបានសារភាពថាគេបានទទួលការណែនាំពីរដ្ឋាភិបាលដើម្បីបញ្ចូលភាសាខ្លះនៅក្នុងញត្តិ ។ ញត្តិមកពីឃុំរបស់ ស៊ា បានរិះគន់ «បនប៉ុលពត» និង «ចក្រពត្តិនិយមអាមេរិក» ។ ញត្តិនេះត្រូវបានបង្កើតឡើងបន្ទាប់ពីឃុំនេះបានទទួលគំរូលិខិតពីអាជ្ញាធរសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ ដោយសារថាញត្តិនោះគឺជាការរិះគន់លក្ខណៈនយោបាយជាជាងការរៀបរាប់អំពីឧក្រិដ្ឋកម្មខ្មែរក្រហម ដូច្នេះវាសំខាន់ណាស់ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាត្រូវមកជួប និង ពិភាក្សាជាមួយអ្នកដែលនៅរស់ជីវិតដើម្បីបញ្ជាក់ពីការពិតដែលមាននៅក្នុងញត្តិទាំងនោះ ។



សម្រាប់ ស៊ា ដែលពេលនោះនៅជាកុមារម្នាក់ក៏ដោយ ក៏ទុក្ខវេទនាដែលបង្កឡើងដោយខ្មែរក្រហមហាក់ដូចជានៅថ្មីៗសម្រាប់គាត់ដែរ ។ បន្ទាប់ពីត្រូវបានចាត់តាំងឲ្យទៅកងចល័តយុវជន ស៊ា ត្រូវខ្មែរក្រហមបញ្ជូនឲ្យទៅហ្វឹកហាត់ក្បួនយុទ្ធសាស្ត្រ គាត់ព្យាយាមរត់គេច ប៉ុន្តែខ្មែរក្រហមចាប់គាត់បាន និងបានបញ្ជូន គាត់ទៅដាក់គុកអស់រយៈពេល២៨ថ្ងៃ និងដាក់ទណ្ឌកម្មឲ្យធ្វើការជាទម្ងន់ ។ នៅក្នុងគុក ស៊ា ត្រូវបង្ខំឲ្យធ្វើការងារជាច្រើនថ្ងៃដោយឲ្យអាហារតែបន្តិចបន្តួចប៉ុណ្ណោះសម្រាប់បរិភោគ ។ ក្រោយមកគាត់ត្រូវបានចាត់តាំងឲ្យទៅធ្វើសង្គ្រាមជាមួយវៀតណាមនៅកោះសាឡូស រហូតដល់គាត់ត្រូវគ្រាប់កាំភ្លើងនៅដៃខាងស្តាំ ទើបគេបញ្ជូនគាត់ឲ្យត្រឡប់មកភូមិវិញ ។

តាមរយៈការជួបបែបនោះជាមួយជនរងគ្រោះមជ្ឈមណ្ឌលកម្ពុជាបានសន្និដ្ឋានថា ទោះបីជាញត្តិភាគច្រើនមានប្រើប្រាស់ភាសានយោបាយមែនក៏ដោយ ក៏ប្រវត្តិរឿងរបស់ប្រជាជននៅតែអាចយកជាការបាន ។ មកដល់ពេលនេះ មជ្ឈមណ្ឌលឯកសារកម្ពុជាទើបតែសម្ភាសន៍អ្នកធ្វើញត្តិរណសិរ្សបានមួយចំនួនតូចប៉ុណ្ណោះ ប៉ុន្តែរឿងរ៉ាវរបស់ពួកគាត់ភាគច្រើនស្របគ្នាទៅនឹងអ្វីដែលពួកគាត់បានរៀបរាប់កាលពី៣០ឆ្នាំមុន ។ អ្នកធ្វើញត្តិភាគច្រើនបានបញ្ជាក់ថាអ្វីដែលពួកគាត់បានសរសេរនៅក្នុងញត្តិកាលពីមុនមិនត្រឹមតែត្រឹមត្រូវពិតប្រាកដទេ ពួកគាត់ថែមទាំងធ្វើញត្តិទាំងនេះនៅពេលនោះដោយការស្ម័គ្រចិត្តទៀតផង ។ នៅឆ្នាំនេះ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងចាប់ផ្តើមគម្រោងមួយដើម្បីធ្វើឲ្យញត្តិរណសិរ្សនេះមាន

តម្លៃសមទៅ នឹងការប្រឹងប្រែងរបស់អ្នករួចរស់ជីវិតនៅពេលនោះ និងព្រមទាំងធ្វើឲ្យមានសកម្មភាពឡើងវិញនូវគណៈកម្មការស្វែងរកការពិតមិនផ្លូវការមួយដែលបានបង្កើតឡើងកាលពី៣០ឆ្នាំមុន ។ តាមរយៈការធ្វើបទសម្ភាសន៍ជាមួយអ្នកធ្វើញត្តិរណសិរ្សជាង១០០០០នាក់ និងជួយអ្នកទាំងនេះដាក់ពាក្យបណ្តឹងទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មជ្ឈមណ្ឌលឯកសារកម្ពុជាមិនត្រឹមតែផ្តល់ភ័ស្តុតាងដ៏សន្ធឹកសន្ធាប់ទៅកាន់អង្គជំនុំជម្រះវិសាមញ្ញទេ ថែមទាំងភ្ជាប់ទំនាក់ទំនងរវាងអង្គជំនុំជម្រះទៅនឹងអ្នកធ្វើញត្តិដែលញត្តិរបស់ពួកគាត់មិនដែលទទួលបាននូវការយកចិត្តទុកដាក់យូរមកហើយទៀតផង ។

ដោយមានបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជានៅក្បែរគាត់ ស៊ា ដែលឥឡូវនេះមានតំណែងជាមេឃុំ បានអានឈ្មោះនៅក្នុងញត្តិនោះម្តងៗ និងបានប្រាប់ពីអ៊ីស្ថានភាពរបស់អ្នកធ្វើញត្តិដែលមានឈ្មោះនៅក្នុងនោះ ។ អ្នកធ្វើញត្តិខ្លះបានស្លាប់ខ្លះប្តូរទីលំនៅ ប៉ុន្តែនៅមានអ្នកធ្វើញត្តិជាច្រើនទៀតដែលរស់នៅភូមិក្បែរៗនោះ ហើយអ្នកទាំងនេះបានមកជួបជាមួយបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាទៀតផង ។ នៅពេលដែល ស៊ា កំពុងតែចាត់តាំងអនុប្រធានរបស់គាត់ឲ្យរៀបចំកិច្ចប្រជុំមួយជាមួយអ្នកភូមិ ស៊ា បានអានមកដល់ឈ្មោះគាត់ដែលមាននៅក្នុងញត្តិនោះដែរ ហើយគាត់ក៏ផ្ទុះសំណើចជាខ្លាំង ។ សំណើចរបស់ ស៊ា បានបង្ហាញពីតម្លៃនៃការនៃការប្រើប្រាស់ញត្តិរណសិរ្សដើម ជាការចាប់ផ្តើមចំពោះគម្រោងចូលរួមរបស់ជនរងគ្រោះរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកដែលឃើញឈ្មោះខ្លួនឯងនៅលើញត្តិចាស់នោះបានចាប់ផ្តើមនឹកឃើញដល់ការចូលរួមរបស់ពួកគាត់នៅក្នុងកិច្ចការចងក្រងឯកសារអំពីឧក្រិដ្ឋកម្មក្នុងរបបខ្មែរក្រហមកាលពីមុន ។ អ្នកធ្វើញត្តិជាច្រើនដែលបានជួបជុំគ្នានៅពេលនោះ បានទទួលស្គាល់ញត្តិនោះនៅពេលឃើញឈ្មោះរបស់ពួកគាត់ ។ ស៊ា បានចាប់ផ្តើមនឹកឃើញអំពីប្រវត្តិនៃការធ្វើញត្តិនៅពេលនោះ ។

កាលពីឆ្នាំ១៩៧៨ បន្ទាប់ពីត្រូវរបួសនៅក្នុងសង្គ្រាមជាមួយប្រទេសវៀតណាម ស៊ា ត្រូវបានបញ្ជូនត្រឡប់មកកាន់ភូមិរបស់គាត់វិញ ។ គាត់បានចិញ្ចឹមមាន់នៅក្នុងភូមិរបស់គាត់នៅពេលដែលប្រជាជនមួយចំនួនរួមទាំងបងប្អូនជីដូនមួយរបស់គាត់ត្រូវគេចាប់ខ្លួន ។ ប្រជាជនទាំងអស់នេះ ត្រូវបានចោទប្រកាន់ថាមិនប្រឹងប្រែងធ្វើការ ។ បងប្អូនជីដូនមួយរបស់គាត់បាត់ខ្លួនចាប់ពីថ្ងៃនោះមក ។

រឿងរ៉ាវរបស់ ស៊ា ត្រូវបាត់បង់នៅមុនពេលដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាមកដល់ខេត្តកំពត ជាមួយនឹងហត្ថលេខានិងបែបបទព័ត៌មានឲ្យជនរងគ្រោះសម្រាប់ធ្វើពាក្យបណ្តឹងទៅអង្គជំនុំជម្រះវិសាមញ្ញ ។ តាមរយៈការធ្វើបទសម្ភាសន៍ជាមួយ ស៊ា ឡើងវិញម្តងទៀត មជ្ឈមណ្ឌលឯកសារកម្ពុជាបានជួយឲ្យ ស៊ា ដឹងថាបទពិសោធន៍របស់គាត់កាលពីមុនមិនត្រូវបានគេបំភ្លេចចោលនោះទេ ។ តាមរយៈការបញ្ជូនពាក្យបណ្តឹងរបស់ ស៊ា ទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ស៊ា បានធ្វើឡើងសាជាថ្មីម្តងទៀតនូវការចូលរួមជារួមមួយដើម្បីនាំយកមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យមកទទួលខុសត្រូវចំពោះមុខច្បាប់ ។


អ្នកភូមិកំពុងអានទស្សនាវដ្តីស្វែងរកការពិត និងសៀវភៅណែនាំបំភ្លឺអំពីការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម

**អេនឌ្រូ ស្តាញ៉ូមេន, នៀល ប៉ាយ, តែជ្រាអ៊ីក ភ្លាសស្ប៉ាយ**

# ចាន់ វ៉ាយៈ មិនចង់ចងពៀរ ប៉ុន្តែចង់បានយុត្តិធម៌

ចាន់ វ៉ាយ គឺជាស្ត្រីម្នាក់ក្នុងចំណោមប្រជាជនរស់នៅទីក្រុងភ្នំពេញប្រមាណជាង១លាននាក់ ដែលត្រូវជម្លៀសឲ្យចេញពីផ្ទះ ក្នុងពេលដែលខ្មែរក្រហមឡើងកាន់កាប់អំណាចឆ្នាំ១៩៧៥ ។ វ៉ាយ មានសាច់ញាតិបងប្អូនស្លាប់អស់ជាច្រើននាក់នៅក្នុងរបបនេះ ដែលជាទូទៅប្រជាជនហៅថា «គុកឥតជញ្ជាំង» ។


ចាន់ វ៉ាយ

ចាន់ វ៉ាយ អាយុ៦៨ឆ្នាំ មានស្រុកកំណើតនៅភូមិក្រាំងម្កាក់ ឃុំរលួស ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឪពុកឈ្មោះ ចាន់ ស៊ុម អាយុ៧០ឆ្នាំ ស្លាប់នៅក្នុងឆ្នាំ១៩៧៨ ដោយសារមិនមានស្បៀងអាហារគ្រប់គ្រាន់ ។ វ៉ាយ មានបងប្អូនបង្កើតទាំងអស់ ប្រាំបីនាក់ (ប្រុសប្រាំនាក់ និងស្រីបីនាក់) ។ ប្អូនប្រុសទីមួយរបស់ វ៉ាយ បានបែកគ្នានៅក្នុងឆ្នាំ១៩៧៥ ក្រោយមកឮដំណឹងថា ខ្មែរក្រហមយកទៅសម្លាប់នៅម្តុំវត្តព្រែកហូរ(តាខ្មៅ) ដោយសារតែធ្វើឲ្យឆេះរោងដាក់ជី ។ ចំណែកប្អូនប្រុសទីប្រាំមួយឮថា កងឈ្លបខ្មែរក្រហមចាប់យកទៅក្នុងឆ្នាំនោះដែរ ដោយមិនបានដឹងពីមូលហេតុច្បាស់លាស់និងត្រូវបញ្ជូនឲ្យទៅកន្លែងណាឡើយ ។ ចំណែកប្អូនទី៨ ក៏មិនបានដឹងថាត្រូវបានខ្មែរក្រហមជម្លៀសទៅតំបន់ណាដែរ ។ រហូតមកដល់សព្វថ្ងៃ វ៉ាយ នៅតែសង្ឃឹមថាប្អូនប្រុសទីប្រាំមួយនិងប្អូនទីប្រាំបីរបស់គាត់ដែលត្រូវខ្មែរក្រហមចាប់ខ្លួននៅមានជីវិតនៅឡើយ ។ ក្រោយឆ្នាំ១៩៧៩ វ៉ាយ បានព្យាយាមស៊ើបសួរដំណឹងពីមិត្តភក្តិដែលធ្លាប់ស្គាល់គ្នា និងស្វែងរកគ្រូទស្សន៍ទាយគ្រប់ទីកន្លែង ពីព្រោះមានអ្នកស្រុកមួយចំនួនប្រាប់ថា នៅពេលដែលកងទ័ពខ្មែរក្រហមធ្វើការជម្លៀសប្រជាជនឲ្យចេញពីទីក្រុងក្នុងឆ្នាំ១៩៧៥ ធ្លាប់បានជួបមុខប្អូនប្រុសទីប្រាំបីនៅតាមផ្លូវ ។

វ៉ាយ រៀបការនៅអាយុ១៨ឆ្នាំ ជាមួយបុរសម្នាក់ឈ្មោះ អ៊ូ នុត (ស្លាប់នៅក្នុងឆ្នាំ១៩៧៦ ដោយសារខ្មែរក្រហមយកទៅសម្លាប់) ។ វ៉ាយ មានកូនទាំងអស់ប្រាំមួយនាក់ (ប្រុសប្រាំនាក់និងស្រីមួយនាក់) ។ ក្រោយពីរៀបការរួច វ៉ាយ និងក្រុមគ្រួសាររស់នៅក្នុងភូមិកំណើតរបស់ខ្លួនដោយប្រកបរបរជាកសិករធ្វើស្រែចម្ការដើម្បីចិញ្ចឹមជីវិត ។ រហូតមកដល់ឆ្នាំ១៩៧២ ភូមិរបស់វ៉ាយ គឺជាសមរភូមិក្តៅមួយរវាងកងទ័ពរំដោះ (ខ្មែរក្រហម) និងកងទ័ព លន់ នល់ ។ សភាពការណ៍នៅក្នុងភូមិក៏បានប្រែក្លាយទៅជាអសន្តិសុខគ្រប់ទីកន្លែង ។ នៅគ្រប់ផ្ទះដើម្បីការពារសុវត្ថិភាពផ្ទាល់ខ្លួន និងក្រុមគ្រួសារ ប្រជាជនទាំងនោះបានជីករណ្តៅ(លេណដ្ឋាន) នៅក្រោមផ្ទះសម្រាប់លាក់ខ្លួននៅពេលដែលមានការវាយប្រហារកើតឡើងម្តងៗ ។ ចំណែកឯផ្ទះរបស់ វ៉ាយ ក៏មានរណ្តៅនៅពីក្រោមផ្ទះដែរ ។ វ៉ាយ បានប្រាប់ថា «កុំតែបានរណ្តៅដែលប្តីរបស់គាត់ជីកនៅក្រោមផ្ទះកុំអីគាត់ស្លាប់ទៅហើយ» ។ សសរផ្ទះខាងមុខពីរ-បីដើម នឹងខាងក្រោយមួយដើមបានបាក់ខ្ទេចដោយសារគ្រាប់កាំភ្លើងនិងអំបែងគ្រាប់ផ្លោង ។ សភាពការណ៍នៅក្នុងភូមិពីមួយថ្ងៃ-ទៅមួយថ្ងៃកាន់តែធ្ងន់ធ្ងរទៅៗ ហើយអ្នកស្រុក-អ្នកភូមិម្នាក់ៗគិតតែពីពួនសម្ងំនៅក្នុងរណ្តៅរៀងៗខ្លួនមិនអាចចេញទៅណាមកណាបានដូចមុនឡើយ សូម្បីតែទៅធ្វើស្រែចម្ការក៏មិនបានផង ។ ក្រោយមកនៅក្នុងឆ្នាំ១៩៧៤ វ៉ាយ និងក្រុមគ្រួសារក៏បានសម្រេចចិត្តចាកចេញពីភូមិកំណើតរបស់ខ្លួនមកនៅកំពង់ត្រាំ ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលជាបណ្តោះអាសន្ន រួចហើយក៏បន្តមករស់នៅចាក់អង្រែ ដែលមានទីតាំងស្ថិតនៅជាយខាងត្បូងទីក្រុងភ្នំពេញ ។

វ៉ាយ និងក្រុមគ្រួសារមករស់នៅចាក់អង្រែបានមួយឆ្នាំ នៅក្នុងឆ្នាំ១៩៧៥ ក៏មានវត្តមានកងទ័ពរំដោះចាប់ផ្តើមធ្វើការវាយប្រហារមកដល់ទីនោះដែរ ។ នៅក្នុងឆ្នាំ១៩៧៥ ពេលដែលកងទ័ពរំដោះចូលមកដល់ គ្រួសាររបស់ វ៉ាយ និងប្រជាជនទាំងអស់ដែលរស់នៅតំបន់ចាក់អង្រែ ត្រូវបានជម្លៀសឲ្យចេញទៅតាមទិសដៅតែមួយ គឺផ្លូវទៅកាន់ស្រុកកោះធំ ខេត្តកណ្តាល ។ ដោយសារ

តែមានមនុស្សម្នាច្រើនស្អេកស្កះហើយទៅមុខមិនរួចផងនោះ គ្រួសាររបស់ វ៉ាយ ក៏បានឈប់សម្រាកត្រឹមព្រែកប្រា (ហួសច្បារអំពៅបន្តិច) ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដណ្ដើមកាន់កាប់ទីក្រុងភ្នំពេញទាំងមូល វ៉ាយ ក៏វិលត្រឡប់មកស្រុកកំណើតវិញមកតាមផ្លូវ គាត់នឹកស្មានតែស្រុកចប់សង្គ្រាមហើយ ព្រោះឃើញមានអ្នកលើកទង់ជ័យពណ៌ស ប៉ុន្តែនៅពេលដែលធ្វើដំណើរមកតាមទំនប់បឹងទំពុន វ៉ាយ បានឈប់សម្រាកអង្គុយយកកម្លាំងមួយសន្ទុះ ហើយក៏បានប្រទះឃើញប្រជាជនមួយចំនួនត្រូវបានចាប់ចងបណ្ដើរជាជួរៗដែលនៅក្នុងនោះមានម្នាក់ដែល វ៉ាយ ធ្លាប់ស្គាល់ច្បាស់ថាជាតារាភាពយន្តខ្មែរឈ្មោះជា យុទ្ធថន កំពុងស្ថិតនៅក្នុងចំណោមអ្នកទោសដែលកងទ័ពរំដោះកំពុងតែបណ្ដើរយកទៅដែរ ដោយដៃទាំងពីរមានជាប់ចំណងផង ។ នៅពេលនោះ វ៉ាយ មានការភិតភ័យនិងតក់ស្លុតយ៉ាងខ្លាំង ។ វ៉ាយ និងក្រុមគ្រួសារក៏ប្រញាប់បន្តដំណើរទៅមុខទៀតរហូតដល់ស្រុកកំណើត ។ មកដល់ទន្លេបាទីឈប់សម្រាកបានពីរ-បីថ្ងៃ វ៉ាយ ត្រូវបានជម្លៀសបន្តឲ្យទៅកាន់វត្តកកោះ ដែលមានទីតាំងស្ថិតនៅក្នុងខេត្តតាកែវជាប់ព្រំប្រទល់ខេត្តកណ្ដាល ។ បន្ទាប់មកក្រុមគ្រួសាររបស់ វ៉ាយ និងប្រជាជនផ្សេងទៀតដែលជម្លៀសមកជាមួយ វ៉ាយ ត្រូវបានជម្លៀសបន្តទៅទៀតដោយជិះតាមរថយន្តកាមីញ៉ុងទៅកាន់សហករណ៍មួយស្ថិតនៅភាគខាងត្បូងស្រុកមោងឫស្សីខេត្តបាត់ដំបង ។

នៅពេលជម្លៀសទៅដល់ស្រុកមោងឫស្សី គ្រួសារ វ៉ាយ និងប្រជាជនដទៃទៀតត្រូវបានអង្គការចែកអង្ករឲ្យក្នុងម្នាក់បានមួយកំប៉ុង ។ ពេលនោះ វ៉ាយ មិនទាន់បានទៅធ្វើការនៅក្នុងការដ្ឋាននៅឡើយទេ ដោយសារគាត់មានផ្ទៃពោះជិតគ្រប់ខែ ។ មួយខែក្រោយមក វ៉ាយ កើតបានកូនស្រីម្នាក់ដែលជាកូនទីបី ។ ចំណែកឯរបបដែលធ្លាប់តែទទួលបានម្នាក់មួយកំប៉ុងនោះត្រូវបានបន្ថយមកត្រឹមពីរនាក់មួយកំប៉ុងវិញ ម្ល៉ោះហើយទើបធ្វើឲ្យម្នាក់ៗដែលធ្លាប់តែហូបច្រើនត្រូវប្រើគ្រប់មធ្យោបាយទាំងអស់ដើម្បីឲ្យខ្លួនបានហូបឆ្អែត ដូចជាដើររកបេះស្លឹកបាស ឬគាស់មើមដំឡូងជាដើមដើម្បីយកមកលាយគ្នាធ្វើជាអាហារ ។ វ៉ាយ ត្រូវបានអង្គការចាត់តាំងឲ្យទៅធ្វើការនៅក្នុងកងធ្វើអង្ករ ហើយមិនអាចយកកូនដែលទើបនឹងកើតនោះទៅជាមួយទេ ម្យ៉ាងទៀតការហូបចុកមិនបានគ្រប់គ្រាន់ធ្វើឲ្យ វ៉ាយ គ្មានទឹកដោះដើម្បីបំបៅកូនឡើយ ។ ជាអកុសលកូនទីបីរបស់ វ៉ាយ បានស្លាប់នៅពេលនោះបន្ទាប់ពីកើតបានមួយខែ ។

វ៉ាយ នៅចាំថា នៅពេលដែលទៅដល់សហករណ៍ដំបូង ផៅ៉ល និងយ៉ាំង ដែលជាអ្នកក្ដោបក្ដាប់សហករណ៍ព្រៃទទឹងទាំងមូលតែងតែហៅប្រជាជនឲ្យទៅប្រជុំដែលមានខ្លឹមសារ ប្រជាជនត្រូវតែជម្រុះចោលឲ្យអស់និងប្រគល់ទ្រព្យសម្បត្តិទាំងប៉ុន្មានដែលមានដូចជានាឡិកាដៃ និងគ្រឿងអលង្ការមកឲ្យអង្គការថ្នាក់លើ ។ នៅរៀងរាល់ពេលប្រជុំម្ដងៗ ខ្មែរក្រហមមួយក្រុមទៀតចុះទៅឆែកឆេរផ្ទះដោយយក ចាន ឆ្នាំង ស្លាបព្រា កែវ និងមាញ៉ូជាដើម ពីផ្ទះនីមួយៗរបស់ប្រជាជននៅតាមសហករណ៍ដែលអង្គការបានសង់ទុកឲ្យ ។ ចំណែកឯនៅកន្លែងប្រជុំវិញ ប្រជាជនទាំងអស់ត្រូវអង្គុយជាបីជួរ ពីមួយជួរទៅមួយជួរត្រូវទុកចន្លោះពីរ-បីម៉ែត្រ ដើម្បីងាយស្រួលក្នុងការត្រួតពិនិត្យ ។ ប្រជាជនខ្លះសំណាងល្អ ព្រោះខ្មែរក្រហមឆែកឆេរមិនឃើញ អ្នកខ្លះទៀតលួចយំនៅពេលដែលខ្មែរក្រហមឆែកឃើញ នឹងដកហូតយកមាសទាំងនោះទៅ ។ រីឯកូនរបស់ វ៉ាយ វិញបានយកមាសមួយចំនួនបៀមទុកនៅក្នុងមាត់ដើម្បីកុំឲ្យកងឈ្លបខ្មែរក្រហមឆែករកឃើញ ។ ពេលនោះកូនរបស់ វ៉ាយ ស្ទើរតែទ្រាំពុំបានដោយសារមានមាសនៅក្នុងមាត់ធ្វើឲ្យចង្អោតចេញមក ក្នុងខណៈពេលដែលកងឈ្លបខ្មែរក្រហមកំពុងធ្វើការឆែកឆេរលើខ្លួនរបស់ប្រជាជន ។ ដើម្បីកូនៗដែលនៅរស់ វ៉ាយ បានព្យាយាមយករបស់របរដែលបានលាក់ទុកយកទៅដូរដូចជាដូងទុំ ចេក ជាពិសេស អង្ករសម្រាប់លីង ហើយបុកឲ្យកូនៗរបស់គាត់ ។ មានថ្ងៃមួយ វ៉ាយ បានយកមាសមួយតម្លឹងទៅដូរបានអង្ករមួយកាម៉ែល (ជាឧបករណ៍ម្យ៉ាងសម្រាប់ដាក់បាយរបស់ទ័ព) ដូងទុំមួយ និងថ្នាំពេទ្យខ្លះ ។ ពេលដែល វ៉ាយ កំពុងតែបុកអង្ករដែលទើបនឹងដូរបាន ស្រាប់តែមានឈ្លបដើរមក វ៉ាយ ក៏ដាក់អង្រែចុះយ៉ាងរហ័ស ហើយអង្គុយនៅក្បែរត្បាល់បុកនោះ ធ្វើហាក់ដូចជាមិនបានអ្វីសោះ ។ ឈ្លបទាំងនោះបែរជាឡើងទៅលើផ្ទះឆែកឆេរ រើកកាយអីវ៉ាន់ខ្ទេចខ្ទីអស់ដើម្បីរកមើលក្រែងលោ វ៉ាយ លួចលាក់ទុករបស់របរ ។ វ៉ាយ មាន

ការភិតភ័យយ៉ាងខ្លាំង ព្រោះនៅជុំវិញត្បាល់បុកនោះមានអង្ករខ្លះដែលខ្ទាតចេញពីត្បាល់ ប៉ុន្តែត្បាល់ដែលមានអង្ករនៅខាងក្នុងត្រូវបានយកក្រមាមកគ្របពីលើ ទើបធ្វើឲ្យឈ្លបមិនបានចាប់អារម្មណ៍ផែកនេះ ។

នៅក្នុងឆ្នាំ១៩៧៧ ជីវភាពរបស់ វ៉ាយ បានធូរស្រាលជាងមុនបន្តិច ដោយសារតែការខិតខំប្រឹងប្រែងធ្វើការងារបានល្អ ទើប វ៉ាយ ត្រូវបានផ្លាស់ឲ្យទៅធ្វើការនៅឃ្លាំងផ្ទុកអីវ៉ាន់ និងធ្វើជាចុងភៅ ។ ទាំងការងារនិងការហូបចុកគឺមានភាពធូរស្រាលនិងប្រសើរជាងមុនខ្លះព្រោះតែ វ៉ាយ អាចលួចយករបស់របរខ្លះមានដូចជា អង្ករ អំបិល ស្ករជាដើម ជាពិសេសនៅពេលដែលធ្វើការបែកបបរម្តងៗ បបរដែលនៅសល់បាតឆ្នាំងទាំងអស់គឺបានមកលើគាត់ ។ ដូច្នេះហើយគាត់អាចហូបខ្លួនឯងផងនិងរំលែកទុកមួយចំណែកសម្រាប់កូនៗរបស់គាត់ផង ។ មិនតែប៉ុណ្ណោះ វ៉ាយ នៅអាចជួយដល់ប្រជាជនផ្សេងទៀតបានម្តងម្កាលដែរ ជាពិសេសអ្នកស្រុកស្វាយរៀងដែលត្រូវបានជម្លៀសទៅសហករណ៍ជាមួយគ្នា ។

ដោយសារតែបានធ្វើការនៅក្នុងឃ្លាំងផ្ទុកអីវ៉ាន់ និងរោងចុងភៅដែលភាគច្រើនបុគ្គលិកទាំងអស់នោះគឺជាប្រពន្ធ កូន បងប្អូន និងជាសាច់ញាតិរបស់កម្មាភិបាលខ្មែរក្រហម វ៉ាយ បានឮដោយចៃដន្យថា កងឈ្លបខ្មែរក្រហមនឹងមានគម្រោងយកប្រជាជនទៅសម្លាប់ចោលដោយនិយាយថា *«ស៊ីស្វាយរួចចាំយើងស៊ីអម្ពិល»* ។ ស្វាយគឺសំដៅទៅលើប្រជាជនដែលជម្លៀសមកពីខេត្តស្វាយរៀង រីឯអម្ពិលគឺសំដៅទៅលើប្រជាជនដែលជម្លៀសពេលបែកថ្ងៃទី ១៧ មេសា ឆ្នាំ១៩៧៥ ។ ដោយសារការស្រឡាញ់រាប់អាននិងទង្វើល្អរបស់ វ៉ាយ ជាមួយប្រជាជននៅក្នុងសហករណ៍ជាមួយគ្នា អ្នកទាំងនោះបានមកបបួល វ៉ាយ ឲ្យរត់ឆ្លងទៅខាងទឹកដីរបស់ថៃមុននឹងខ្មែរក្រហមសម្លាប់ ។ ប៉ុន្តែ វ៉ាយ បានបដិសេធមិនព្រមទៅជាមួយអ្នកទាំងនោះទេ ដោយសារតែខ្លាចកងឈ្លបខ្មែរក្រហមចាប់បានយកទៅសម្លាប់ចោល និងម្យ៉ាងទៀតសមាជិកនៅក្នុងក្រុមគ្រួសារមិនទាន់មកជុំគ្នា ។ ចំណែកប្រជាជនដែលលួចរត់នោះអ្នកខ្លះក៏បានទៅដល់ទិសដៅរបស់ខ្លួន អ្នកខ្លះត្រូវបានចាប់យកមកសម្លាប់ចោល និងអ្នកខ្លះទៀតស្លាប់នៅពាក់កណ្តាលផ្លូវដោយសារខ្វះអាហារនិងជាន់មីន ។

វ៉ាយ បានប្រាប់ថា «មុនបែកឆ្នាំ១៩៧៩ នៅគ្រប់សហករណ៍ខ្មែរក្រហមមានគម្រោងចង់សម្លាប់ប្រជាជនទាំងអស់ ដោយមានកម្មវិធីហូបនំបញ្ចុករួមគ្នា» ។ មុនចាប់ផ្តើមកម្មវិធីនេះ ប្រជាជនត្រូវបានបញ្ជាឲ្យជីករណ្តៅធំៗជាច្រើន បន្ទាប់មកកងឈ្លបខ្មែរក្រហមដើរដាក់មីនពទ្ធ័ជុំវិញរណ្តៅទាំងនោះ ក្នុងគោលបំណងដើម្បីធ្វើឲ្យគ្រាប់មីនទាំងនោះផ្ទុះឡើងនៅពេលដែលប្រជាជនកំពុងតែអង្គុយហូបនំបញ្ចុក ។ ប្រជាជននៅក្នុងសហករណ៍មួយចំនួនបានស្លាប់ដោយសារការផ្ទុះគ្រាប់មីន ដែលកងឈ្លបខ្មែរក្រហមបានបំផ្ទុះនៅពេលដែលប្រជាជនកំពុងតែអង្គុយហូបនំបញ្ចុកនិងមើលខ្សែភាពយន្តនៅមាត់រណ្តៅ ។ ចំណែកឯសហករណ៍ព្រៃទទឹងដែល វ៉ាយ រស់នៅទើបតែជីករណ្តៅបានពាក់កណ្តាល ក៏មានអន្តរាគមន៍របស់កងទ័ពវៀតណាមទៅជួយទាន់ពេលវេលានោះ ធ្វើឲ្យបងប្អូនឪពុកម្តាយ កូនចៅ ដែលធ្វើការនៅកន្លែងផ្សេងៗគ្នាបានមកជួបជុំគ្នាវិញ ។ នៅឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជានិងកងទ័ពវៀតណាមបានវាយប្រហារយ៉ាងខ្លាំង ធ្វើឲ្យកងទ័ពខ្មែរក្រហមដែលកំពុងចុះខ្សោយត្រូវដកថយយ៉ាងតក្កហល ។ ឆ្លៀតឱកាសនោះខ្មែរក្រហមបាន



អ្នកភូមិស្នួលវត្ត ខេត្តក្រចេះ

*កៀរប្រជាជន និង រ៉ាយ ទៅជាមួយដែរ ។ ប៉ុន្តែ រ៉ាយ បាន ព្យាយាមគេចពីក្នុងហ្វូង ព្រោះតែកូនៗរបស់ រ៉ាយ ដែលធ្វើការ នៅកន្លែងផ្សេងមិនទាន់មកជួបជុំគ្នា ។*

*ប្រជាជនដែលជម្លៀសទៅសហករណ៍ព្រៃទទឹង នៅក្នុងស្រុក មោងឫស្សី ខេត្តបាត់ដំបងជាមួយ រ៉ាយ បានបាត់បង់សមាជិក អស់ជាច្រើន ហើយក្នុងគ្រួសារនីមួយៗពេលចេញទៅប្រាំនាក់ ត្រឡប់មកវិញតែពីរនាក់ ខ្លះទៀតទៅបួននាក់ត្រឡប់មកវិញតែ ម្នាក់ឯងក៏មានដែរ ។ គ្រួសាររបស់ រ៉ាយ ក៏បាត់បង់អស់សមាជិក ប្រាំពីរនាក់ (ប្អូនប្រុសបង្កើតបីនាក់ កូនស្រីពីរនាក់ ប្តីម្នាក់និង ឪពុកម្នាក់) ដែលធ្វើឲ្យគាត់មានកំហឹងចង់សងសឹកយ៉ាងខ្លាំងទៅលើ កងឈ្លបរបស់ខ្មែរក្រហមវិញ ។ ក្រោយមក រ៉ាយ យល់ថាមិនចង់ ចងពៀរទៀតទេ ព្រោះខ្មែរក្រហមធ្វើខុសហើយ កុំឲ្យខុសដូចពួកនេះ ទៀត ។ បើទោះបីជាសម្លាប់ខ្មែរក្រហមវិញ ក៏ប្តី កូន និងប្អូនៗ របស់គាត់មិនអាចរស់មកវិញបានដែរ ។ ដូច្នេះហើយ រ៉ាយ បាន បន្ថែមថា ធ្វើយ៉ាងម៉េចធ្វើទៅឲ្យតែស្របទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ របស់ប្រទេសខ្មែរ ។* **គង់ សុគឿន**

# ទំនាក់ទំនងសហរដ្ឋអាមេរិកនិងកម្ពុជាៈ ទំនាក់ទំនងទ្វេភាគី និង បំណុល

*ទន្ទឹមនឹងភាពរីកចម្រើន ភាពទន់ខ្សោយក្នុងការអនុវត្តច្បាប់ អំពើពុករលួយដែលមិនអាចទប់ស្កាត់បាននិងភាពទន់ខ្សោយនៅ តាមស្ថាប័ននានានៅតែជាបញ្ហាចម្បងក្នុងដំណើរការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា និងការលូតលាស់ផ្នែកសេដ្ឋកិច្ច ។ នៅខណៈពេលគណបក្សប្រឆាំងដើរតួនាទីក្នុងការងារនយោបាយប្រទេស គណបក្សកាន់អំណាចគ្រប់គ្រងស្ទើរគ្រប់ស្ថាប័នក្នុង រដ្ឋាភិបាល ។ មេដឹកនាំកម្ពុជានៅតែបន្តប្រើប្រាស់ភាពទន់ខ្សោយរបស់ខ្លួន និងប្រព័ន្ធច្បាប់ដែលងាយនឹងរងឥទ្ធិពលដើម្បីស្វែងរកផ្លូវ ច្បាប់ប្រឆាំងទៅនឹងក្រុមអ្នករិះគន់ និងបក្សប្រឆាំង ។ ជម្លោះដីធ្លី និងការបណ្តេញប្រជាជនចេញទាំងបង្ខំ តែងតែធ្វើឡើងដោយ អំពើហិង្សា ហើយនេះនៅតែជាបញ្ហាដែលគួរឲ្យកត់សម្គាល់ ។ សុខុមាលភាពរបស់ប្រជាជនកម្ពុជា និងប្រព័ន្ធអប់រំត្រូវបានបំផ្លាញ យ៉ាងធំធេងក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម(ពីឆ្នាំ១៩៧៥ - ១៩៧៩) កេរមរតកនេះនៅតែបន្តរារាំងការអភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកម្ពុជារហូតមកដល់សព្វថ្ងៃ ។*

*ក្នុងការខិតខំប្រឹងដោះស្រាយជាមួយកេរមរតករបស់ខ្មែរក្រហមបន្សល់ទុក សហរដ្ឋអាមេរិកគាំទ្រយ៉ាងខ្លាំងក្លាដើម្បីនាំយក យុត្តិធម៌ និងមេដឹកនាំដែលទទួលខុសត្រូវចំពោះអំពើដ៏ឃោរឃៅក្រោមរបបនោះមកទទួលខុសត្រូវចំពោះមុខច្បាប់ យើងក៏ពេញចិត្ត ចំពោះការវិវត្តរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ឬតុលាការកូនកាត់ បានបង្កើតឡើងក្នុងឆ្នាំ២០០៤ ដើម្បីនាំយកអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មក្រោមសម័យខ្មែរក្រហមដែលមានប្រជាជន ជិតពីរលាននាក់ត្រូវបានសម្លាប់ ។ ការស៊ើបអង្កេតជំហានដំបូងកំពុងតែចាប់ផ្តើមហើយ និងអតីតមេដឹកនាំខ្មែរក្រហមប្រាំនាក់ត្រូវ បានចាប់ខ្លួនដោយចោទប្រកាន់ពីបទឧក្រិដ្ឋសង្គ្រាម និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ។ សហរដ្ឋអាមេរិកមិនបានផ្តល់ជំនួយដោយ ផ្ទាល់ទៅឲ្យអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាទេ ដោយហេតុថា ត្រូវឆ្លងកាត់ការពិភាក្សានៅក្នុងសភា និងកិច្ចការងាររដ្ឋបាល ដែលផ្តោតទៅលើគុណភាព ជាពិសេសសាលាក្តីអសមត្ថភាពក្នុងការធានាឲ្យមាន «យុត្តិធម៌កម្រិតអន្តរជាតិ» ។ ទោះបីជាយ៉ាង នេះក្តី ដោយគិតដល់ការវិវត្តរបស់តុលាការនាពេលកន្លងមក ក្រសួងបានពិនិត្យឡើងវិញ និងធ្វើសហប្រតិបត្តិការជាមួយសាលាក្តី ដែលរួមបញ្ចូលការធានាថា តើសាលាក្តីនេះមានយុត្តិធម៌កម្រិតអន្តរជាតិហើយឬនៅ? ដើម្បីធ្វើការសម្រេចចិត្តចំពោះការ ផ្តល់ជំនួយនៅពេលខាងមុខ ។*

***ក្រសួងការបរទេសសហរដ្ឋអាមេរិក***

# ជនរងគ្រោះស្វែងរកចម្លើយពីការកាត់ទោសមេដឹកនាំខ្មែរក្រហមនាពេលខាងមុខនេះ ចំពោះភាពភ័យខ្លាចដក់ជាប់ក្នុងចិត្តប្រជាជនកម្ពុជាកាលពី៣០ឆ្នាំមុន

បីទសវត្សរ៍បន្ទាប់ពីរបបខ្មែរក្រហមដ៏ឃោរឃៅ បានបំភ័យ ជុំ មុី និងប្រជាជនកម្ពុជារាប់លាននាក់ ។ ភាពភ័យខ្លាចនិងការបាត់បង់យ៉ាងធ្ងន់ធ្ងរនៅតែដក់ជាប់ក្នុងចិត្តរបស់គាត់មកដល់សព្វថ្ងៃ ។

មុី រំឭកអំពីដំណើរដែលខ្មែរក្រហមចូលមកដល់ទីក្រុងនៅខែមេសា ឆ្នាំ១៩៧៥ មានមនុស្សតែម្នាក់ក្នុងចំណោមមនុស្ស ១០នាក់ស្គាល់ថា បានរួចជីវិតពីគុកទួលស្លែង ដែលនៅទីនោះមានប្រជាជន១៤០០០នាក់បានស្លាប់ ។

ក្នុងគោលបំណងបំបាត់សាសនា ចំណេះដឹង ទ្រព្យសម្បត្តិឯកជន និងរូបិយប័ណ្ណ អ្នកសកម្មប្រយុទ្ធកម្មុយនីស្តបានបញ្ជាឲ្យប្រជាជនធ្វើដំណើរទៅកាន់ជនបទ ។ កូនប្រុសរបស់ មុី ដែលនៅក្មេងបានស្លាប់ក្នុងពេលធ្វើដំណើរដោយសារខ្វះខាតការព្យាបាល ។

បន្ទាប់មក ខ្មែរក្រហមបានបាញ់សម្លាប់ប្រពន្ធនិងកូនប្រុសដ៏ទៃទៀតរបស់ មុី ដែលអ្នកទាំងនេះក៏ស្ថិតនៅក្នុងចំណោមប្រជាជន ១.៧លាននាក់ដែលបានស្លាប់ក្នុងអំឡុងពេល៤ឆ្នាំដែរ ។ ហើយវាសនារបស់កូនស្រីពីរនាក់ទៀតរបស់គាត់ក៏នៅមិនទាន់មានដំណឹង ។

សព្វថ្ងៃនេះ មុី មានអាយុ៧៩ឆ្នាំ រស់នៅទីក្រុងភ្នំពេញ




ប៉ុន្តែ មុី មិនបានប្រាប់ពីអាសយដ្ឋានច្បាស់លាស់ទេ ព្រោះ មុី ព្រួយបារម្ភថាខ្មែរក្រហមដែលនៅសេសសល់ប្រហែលជានឹងមករកគាត់ ។ ម្យ៉ាងវិញទៀតគាត់គិតដល់អំណាចរបស់មេដឹកនាំខ្មែរក្រហមដែលនៅរស់ តាមការពិតសព្វថ្ងៃនេះមេដឹកនាំទាំងនេះមានវ័យចំណាស់ ហើយនឹងត្រូវយកទៅកាត់ទោសនៅពេលឆាប់ៗខាងមុខ ។

ប៉ុល ពត បានស្លាប់នៅឆ្នាំ១៩៩៨ ប៉ុន្តែអតីតមេដឹកនាំប្រាំនាក់ផ្សេងទៀតនៃរបបខ្មែរក្រហមនឹងយកទៅកាត់ទោសនៅតុលាការអន្តរជាតិដែលមានគម្រោងជាច្រើនឆ្នាំរបស់មន្ត្រីកម្ពុជានិងអង្គការសហប្រជាជាតិ ។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម នួន ជា មានអាយុ ៨២ឆ្នាំ ថ្ងៃនេះនឹងបង្ហាញខ្លួនជាលើកទីមួយនៅអង្គជំនុំជម្រះ ។ ចុងចោទអាចត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត ។

មុី ក៏ដូចជាជនរងគ្រោះផ្សេងទៀតបានព្យាយាមបំភ្លេចអំពើឃោរឃៅនៃរបបខ្មែរក្រហម ប៉ុន្តែមិនបានសម្រេចសោះ ។ មុី ផ្តល់ចម្លើយឲ្យអង្គជំនុំជម្រះថា នេះគឺជាចម្លើយមិនមែនជាគំនុំ ។ មុី និយាយថា «ខ្ញុំគ្រាន់តែចង់ឲ្យមេដឹកនាំខ្មែរក្រហមក្រោកឈរឡើង ហើយនិយាយពីការពិតតែប៉ុណ្ណោះ ប្រសិនបើមេដឹកនាំខ្មែរក្រហមធ្វើដូច្នោះ ពួកគេអាចមានសេរីភាព» ។ ប៉ុន្តែពេលដែលកម្ពុជាចាប់ផ្តើមការសន្ទនាជាលក្ខណៈជាតិអំពីខ្មែរក្រហម ឃើញថាវាពិបាកណាស់ក្នុងការស្វែងរកការពិត ។

របបខ្មែរក្រហមមិនបានលុបបំបាត់ទាំងស្រុងទេនៅពេលដែលកងទ័ពវៀតណាមចូលបោសសម្អាតនៅឆ្នាំ១៩៧៩ ។ ប៉ុល ពត និងបក្ខពួករបស់គាត់ដកថយទៅរស់នៅក្នុងព្រៃ ២០ឆ្នាំក្រោយនៅតែមិនអាចពង្រឹងអំណាចឡើងវិញ ។

ទាក់ទងនឹងការលើកលែងទោសនិងការខ្វះចន្លោះ រដ្ឋាភិបាលកម្ពុជាបានទាញយកកម្លាំងទ័ពដែលនៅសេសសល់របស់ខ្មែរក្រហមបញ្ចូលទៅក្នុងជួរប៉ូលិសនិងទាហាន ។ ការរៀបចំនេះបានបញ្ចប់ជម្លោះ ប៉ុន្តែធ្វើឲ្យជនរងគ្រោះមិនមានទំនុកចិត្តលើអាជ្ញាធរកម្ពុជា ។ ប៉ុន្មានឆ្នាំមកនេះ ទូទាំងប្រទេសមានសន្តិភាពមិនពិតប្រាកដដោយមានការកាត់ទោសមិនត្រឹមត្រូវ ។ ឧក្រិដ្ឋកម្មក្លាយទៅជាការហាមឃាត់មិនឲ្យរំឭក ហើយនៅតាមសាលារៀន មិនបានបញ្ចូលរឿងរ៉ាវនេះនៅក្នុងកម្មវិធីសិក្សាទេ ។ ប្រជាជនកម្ពុជាជាច្រើនយល់ដឹងពីបទពិសោធន៍អំពីខ្មែរក្រហមតាមរយៈក្រុម-គ្រួសារខ្លួនតែប៉ុណ្ណោះ និងមិនមានការយល់ដឹងទូលំទូលាយពីអំពើសាហាវឃោរឃៅនិងអ្នកដែលត្រូវទទួលខុសត្រូវទេ ។

សេង ធារី នាយិកាមជ្ឈមណ្ឌលអភិវឌ្ឍសង្គមនិងជាជនរងគ្រោះនៃរបបខ្មែរក្រហមនិយាយថា «វាមានការច្របូកច្របល់

ជាច្រើន តែយើងគួរតែផ្តោះទៅកាន់ភាពមិនច្បាស់លាស់ និងសម័យខ្មៅងងឹតនេះ មុនពេលយើងទទួលបានការបកស្រាយបញ្ហាក់» ។ យើងកំពុងតែនៅក្នុងការសន្ទនាដែលជាផ្នែកមួយនៃដំណើរការ ។ ប៉ៃលិន គឺជាខេត្តមួយនៅជិតព្រំដែនថៃដែលជាលំនៅរបស់មេដឹកនាំខ្មែរក្រហមបួននាក់ក្នុងចំណោមមេដឹកនាំប្រាំនាក់ ហើយសព្វថ្ងៃនេះ មេដឹកនាំទាំងនេះនៅជាប់ឃុំឃាំង ប្រជាជនដែលដឹងពីការពិតក៏ដឹងអំពីរឿងរ៉ាវនេះដែរ ។

ទាក់ទងនឹងការលើកលែងទោសនៅឆ្នាំ១៩៩៦ រដ្ឋាភិបាលកម្ពុជាផ្តល់សេរីភាពឲ្យខ្មែរក្រហមនៅទូទាំងប្រទេស និងអតីតខ្មែរក្រហមរាប់រយនាក់រស់នៅក្នុងប្រទេសកម្ពុជា ។

គង់ ដួង មន្ត្រីព័ត៌មានដែលជាអ្នកទីមួយនិយាយអំពីខ្មែរក្រហមនៅតាមវិទ្យុថា «អតីតខ្មែរក្រហមដែលរស់នៅទីនេះដឹងអំពីរឿងរ៉ាវជាច្រើន ប៉ុន្តែគេមិនព្រមនិយាយអ្វីទាំងអស់» ។ ពួកគេភាគច្រើនព្រួយបារម្ភថា ការនិយាយប្រាប់ពីរឿងរ៉ាវនេះអាចធ្វើឲ្យព្រះរាជអាជ្ញាបង្កើតសំណុំរឿងបាន ។ ទោះបីជាយុត្តាធិការរបស់តុលាការមានកំណត់ចំពោះមេដឹកនាំខ្ពស់ខ្មែរក្រហមក៏ដោយ ប៉ុន្តែមេដឹកនាំទីពីរ ទីបីនិងមេដឹកនាំបន្តបន្ទាប់បារម្ភថា ដំណើរការរបស់ អង្គជំនុំជម្រះអាចកាន់តែវែងឆ្ងាយទៅទៀត ។

អតីតមេដឹកនាំខ្មែរក្រហមតែងតែមកញ៉ាំអាហារពេលព្រឹកជាមួយគ្នារាល់ព្រឹកនៅភោជនីយដ្ឋានហង្សមាស មេដឹកនាំទាំងនេះអង្គុយបរិភោគគុយទាវនិងផឹកកាហ្វេទឹកកក ។ គេចង់និយាយអំពីការឃោសនាទម្លាក់គ្រាប់បែកជាសម្ងាត់របស់អាមេរិកនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ ។ ភេរវកម្មទម្លាក់គ្រាប់បែកជារៀងរាល់ថ្ងៃរបស់អាមេរិកធ្វើឲ្យកសិករនៅជនបទរាប់ពាន់នាក់បែរមកជួយគាំទ្រខ្មែរក្រហម កំហុសនោះបានសម្លាប់និងធ្វើឲ្យប្រជាជនកម្ពុជាពិការរហូតមកដល់សព្វថ្ងៃនេះ ។

ប៉ុន្តែ ពេលដែលមេដឹកនាំខ្មែរក្រហមទាំងនេះនិយាយដល់ឆ្នាំ១៩៧៥-១៩៧៩ គេក៏ប្រញាប់ប្រញាល់ដើរចេញពីតុ ។ អ្នកដែលបាននិយាយអំពីអតីតកាលត្រូវបានគេតាមដាន ។ ថុង ថន គឺជាអ្នកថតវីដេអូឲ្យខ្មែរក្រហម គាត់ធ្វើដំណើរជុំវិញប្រទេសដើម្បីថតរឿងឃោសនា ។ បច្ចុប្បន្នគាត់ជាជីទប់ទីមួយនៅអូតាវ៉ ដែលជាភូមិតូចមួយនៅជិតក្រុងប៉ៃលិន ។

នៅឯផ្ទះខ្មែរបុរាណរបស់ ថន ដែលមានសណ្ឋានជារោងដោល គាត់អង្គុយនៅក្រោមម្លប់ដើមឫស្សីហើយរៀបរាប់ពីសម័យខ្មែរក្រហមប្រៀបដូចជារបបដ៏ល្អមួយ ។

នៅអំឡុងពេលដែលប្រជាជនរាប់រយនាក់ក្នុងចំណោមប្រជាជនកម្ពុជារាប់ពាន់នាក់កំពុងតែស្លាប់ដោយអត់អាហារ ថនបែរជានិយាយថា ប្រជាជនមានចំណីអាហារគ្រប់គ្រាន់ ។ គាត់មិនឃើញនរណាម្នាក់ដែលមិនសប្បាយចិត្ត ឬត្រូវបង្ខំឲ្យធ្វើពលកម្មឡើយ ។ គាត់សារភាពថា គាត់ក៏មិនដឹងពីការពិតដែរ ។

គាត់និយាយថា «ប្រសិនខ្ញុំត្រូវបានចាត់តាំងឲ្យទៅខាងត្បូង ខ្ញុំត្រូវតែទៅត្បូង ប្រសិនបើខ្ញុំបដិសេធ ខ្ញុំប្រាកដជាទទួលទណ្ឌកម្មដ៏ធ្ងន់ធ្ងរ» ។ គាត់និយាយទៀតថា «គាត់គឺជាក្រុមថតវីដេអូទីពីររបស់ខ្មែរក្រហម ហើយប៉ុលពតបានសម្លាប់ក្រុមទីមួយនេះ» ។

គាត់បន្ថែមទៀតថា «ក្រុមថតវីដេអូទីមួយទទួលការហ្វឹកហាត់ពីបរទេស ដូច្នេះមេដឹកនាំខ្មែរក្រហមមិនទុកចិត្តលើគេទេ» ។ មេដឹកនាំដែលនៅរស់មិនខ្លាចសេចក្តីស្លាប់ ហើយគេក៏មិនទទួលយកការទទួលខុសត្រូវដែរ ។ ពួកគេតែងតែទិតៀនពីឥទ្ធិពលរបស់បរទេស ។ ពេលបរិភោគអាហារនៅក្រៅផ្ទះនៅប៉ៃលិនដោយមានបាយចំហុយនិងគោដុត ឡាច លីណា អតីតឈ្លបខ្មែរក្រហមបង្ហាញពីទស្សនៈរបស់គាត់ចំពោះប្រវត្តិសាស្ត្រថា គឺជាគំនិតរបស់មនុស្សជាច្រើន ។ លីណា អាយុ៤១ឆ្នាំនិយាយថា «ទាហានខ្មែរក្រហមមិនមានការរៀនសូត្រ» ។ នេះគឺធ្វើឲ្យមនុស្សខាងក្រៅដូចជាសេអ៊ីអា និងកាហ្សេបេ ងាយស្រួលនឹងជះឥទ្ធិពលចំពោះអ្វីដែលកើតឡើង» ។ បន្ទាប់មក គាត់ហាក់ដូចមានមានភាពលាក់លៀមហើយបន្ទឹឡើងថា «ចិនដឹងពីរឿងនេះច្រើន» ។ ពាក្យសម្តីនេះមិនបានគាំទ្រពីភាពពិត ប៉ុន្តែពាក្យសម្តីនេះបង្ហាញពីមូលហេតុដ៏ល្អដែលខ្មែរក្រហមនិងអ្នកក្រោមឱវាទនឹងត្រូវយកមកកាត់ទោសខណៈពេលដែលអង្គជំនុំជម្រះចាប់ផ្តើម ។

ការរំពឹងទុករបស់ប្រជាជាជនកម្ពុជាអំពីអង្គជំនុំជម្រះគឺមានភាពខុសគ្នា ។ ប្រជាជនខ្លះចង់បានការជួសជុលដោយហិរញ្ញវត្ថុ ។ បុរសម្នាក់នៅមណ្ឌលគិរី ចង់ឲ្យអង្គជំនុំជម្រះសងដំរីពីរក្បាលដែលខ្មែរក្រហមបានយកពីគាត់ ។ ប្រជាជនផ្សេងទៀតចង់ឲ្យអង្គជំនុំជម្រះមានការរីកចម្រើនហើយធ្វើការចោទប្រកាន់មេដឹកនាំខ្មែរ

ក្រហមផ្សេងទៀត ។ ឯប្រជាជនខ្លះទៀត ចង់ឲ្យមេដឹកនាំបរទេសដែលបានផ្គត់ផ្គង់កាំភ្លើងឲ្យខ្មែរក្រហមទទួលខុសត្រូវដែរ ។

យោងទៅតាមការស្ទាបស្ទង់ដោយមិនមានលក្ខណៈវិទ្យាសាស្ត្ររបស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅឆ្នាំ២០០២ ៧៣ភាគរយនៃអ្នកឆ្លើយតបនិយាយថា គេចង់សិក្សាអំពីការពិតនៃខ្មែរក្រហម ។ ដុ ម៉ី នៅធ្វើការជាជាងជួសជុលម៉ាស៊ីននៅភ្នំពេញខណៈពេលដែលខ្មែរក្រហមជម្លៀសប្រជាជនឲ្យចេញពីទីក្រុងនៅឆ្នាំ១៩៧៥ ។ ម៉ី ផ្តល់ព័ត៌មានអំពីការបង្ខំឲ្យដើរជាក្បួននិងមរណភាពរបស់កូនប្រុសដែលនៅក្មេងរបស់គាត់បណ្តាលមកពីជំងឺរាក ។

របបនេះមានគោលដៅសំដៅទៅលើបញ្ញវន្ត គឺលុបបំបាត់ថ្នាក់រៀនដែលខ្មែរក្រហមជឿថាគឺជាសង្គមពុករលួយ ។ ម៉ី មិនបានទទួលការរៀនសូត្រជ្រៅជ្រះបានត្រឡប់មកទីក្រុងវិញ ហើយត្រូវបានទាហានជ្រើសតាំងឲ្យជួសជុលម៉ាស៊ីនដេរដែលប្រើប្រាស់ដើម្បីដេរឯកសណ្ឋាន ។

នៅឆ្នាំ១៩៧៨ ទាហានប្រាប់គាត់ថា គាត់នឹងត្រូវបញ្ជូនទៅប្រទេសវៀតណាមដើម្បីជួសជុលម៉ាស៊ីនដេរនៅទីនោះ ។ ប៉ុន្តែគេបែរជាបញ្ជូនគាត់មកដាក់គុកទៅវិញ ។ ទួលស្លែងពីដំបូង គឺជាវិទ្យាល័យដែលមាន៤អាគារ ប៉ុន្តែវិទ្យាល័យនេះបែរជាក្លាយទៅជាកន្លែងដែលអ្នកទោសរួមទាំង ម៉ី ដែលទទួលទារុណកម្មនៅទីនោះផង ។

នៅខណៈដែល ម៉ី ទស្សនាសារមន្ទីរនៃបនប្រល័យពូជសាសន៍ដែលជាអតីតគុក ម៉ី រៀបរាប់អំពីការទទួលទារុណកម្មរបស់គាត់រយៈពេល១២ថ្ងៃនៅទីនោះ គាត់ត្រូវបានបញ្ជូនទៅកាន់បន្ទប់ផ្សេងៗគ្នា ។ ដំបូង អ្នកសួរចម្លើយប្រើខ្សែភ្លើងឆក់សៀតផ្ការបស់គាត់ ។ គាត់បង្ហាញពីភាពភ័យខ្លាចពេលដែលអ្នកសួរចម្លើយម្នាក់បានទាញកន្ត្រាក់ក្រចកជើងគាត់ ។ ម៉ី និយាយថា «សំណួរតែមួយគត់ដែលគេសួរគាត់នោះគឺ តើអ្នកធ្លាប់មានទាក់ទងជាមួយសេអ៊ីអា និងកាហ្សេបេប៊ូទេ?» ដោយទទួលការឈឺចាប់ខ្លាំងពេក នៅទីបញ្ចប់ ម៉ី ក៏និយាយពាក្យកុហកដែលខ្មែរក្រហមចង់ស្តាប់ថា គាត់គឺជារនុកក្នុង ។ ម៉ី និយាយទៀតថា «ខ្ញុំធ្វើខុសចំពោះប្រជាជនផ្សេងទៀត ខ្ញុំពិតជាមិនចង់ធ្វើដូច្នោះទេ ខ្ញុំគ្រាន់តែចង់ឲ្យគេបញ្ឈប់ទារុណកម្មប៉ុណ្ណោះ» ។ គាត់បានរៀបចំរត់គេចពីអ្នកចាប់គាត់នៅពេលដែលវៀតណាមកំពុងចូលរំដោះភ្នំពេញ ។ បន្ទាប់មក កូនស្រីពីរនាក់របស់គាត់បានបាត់ខ្លួនតាំងពីនាងត្រូវបានបញ្ជូនទៅឲ្យទាហាន ប៉ុល ពត ។ ម៉ី ជួបជុំប្រពន្ធនិងកូនគាត់ម្តងទៀតបន្ទាប់ពីគាត់បានរត់គេចពីគុក ប៉ុន្តែខណៈពេលដែលគ្រួសារគាត់ព្យាយាមស្វែងរកកន្លែងសុវត្ថិភាពនៅក្នុងភាពវឹកវរនៃការបែកបាក់របបកម្ពុជាប្រជាធិបតេយ្យ ទាហានត្រាច់ចរមួយក្រុមរបស់ខ្មែរក្រហមបានរកឃើញក្រុមគ្រួសាររបស់គាត់ ។ ម៉ី ឮសំឡេងគ្រាប់កាំភ្លើងដែលបានសម្លាប់ប្រពន្ធនិងកូនគាត់ ។ របបនេះបានដួលរលំមុនពេលដែលខ្មែរក្រហមអាចសម្លាប់គាត់ ។

ហ៊ីសាម មូស្សា អ្នកគាំពារសិទ្ធិមនុស្សដែលថ្មីៗនេះបានរៀបចំវេទិការពិភាក្សារាប់រយសម្រាប់ជនរងគ្រោះនៅទូទាំងប្រទេស និយាយថា «ប្រជាជនខ្លះចង់បំភ្លេចអំពើគួរឲ្យស្អប់ខ្ពើមនេះ ប៉ុន្តែគេគ្រាន់តែមិនរំពឹកពីរឿងនេះ និងបន្តជីវិតទៅមុខទៀត» ។ គាត់បន្ថែមទៀតថា «ប្រសិនបើអ្នកបាត់បង់សមាជិកគ្រួសារ នេះជារឿងដែលមិនអាចបំភ្លេចបានរបស់មនុស្ស ។ ប៉ុន្តែបើអ្នកនិយាយជាមួយជនរងគ្រោះបានមួយម៉ោងគាត់ចាប់ផ្តើមយំ ។ ជនរងគ្រោះហាក់ដូចជាបានបំភ្លេចរឿងរ៉ាវនេះប៉ុន្តែគេមិនបានបំភ្លេចទេ» ។ **អានី លីនស្តី**

## ការចូលរួមរបស់ជនរគ្រោះ

នៅអំឡុងឆ្នាំ២០០៨មជ្ឈមណ្ឌលឯកសារកម្ពុជាមានគោលបំណងចង់ឲ្យជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិច ១០,០០០នាក់ ចូលរួមបំពេញពាក្យបណ្តឹង (ជាឧក្រិដ្ឋកម្ម ឬជាដើមបណ្តឹងរដ្ឋប្បវេណី) មុនពេលចូលទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញពីសកម្មភាពនេះថាជាការជួយដល់ប្រជាជនសាមញ្ញកម្ពុជាឲ្យចូលរួមក្នុងដំណើរការនាំយកមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទៅកាត់ទោសនៅមុខច្បាប់និងដំណើរការម្តងទៀតនូវ «គណៈកម្មការស្វែងរកការពិត» ជាលក្ខណៈមិនសូវផ្លូវការដែលគណៈកម្មការនេះបានចាប់ផ្តើមតាំងពីអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៨០ម្ល៉េះ ដោយការចុះហត្ថលេខាលើញត្តិរណសិរ្ស ។

សម្រាប់ព័ត៌មានលម្អិតសុំទំនាក់ទំនង លោក ជី ទេវិទ្ធ តាមរយៈលេខទូរស័ព្ទ ០២៣ ២១១ ៨៧៥ ។

# កាលប្បវត្តិសំខាន់ៗរបស់តុលាការខ្មែរក្រហម

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៤ សភាសហរដ្ឋអាមេរិក បានទទួលស្គាល់ច្បាប់យុត្តិធម៌ស្តីពីអំពើប្រល័យពូជសាសន៍របស់ប្រជាជនកម្ពុជាដែលសេចក្តីថ្លែងការណ៍បង្ហាញថា «គោលការណ៍របស់សហរដ្ឋអាមេរិកដើម្បីគាំទ្រក្នុងការនាំយកសមាជិកខ្មែរក្រហមមកកាត់ទោសចំពោះបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជានៅអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩» ។

នៅថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៧ មជ្ឈមណ្ឌលឯកសារកម្ពុជាដែលត្រូវបានបង្កើតឡើងជាផ្លូវការក្នុងបេសកកម្មយុត្តិធម៌អំពើប្រល័យពូជសាសន៍កម្ពុជារយៈពេលពីរឆ្នាំក្រោមការជួយឧបត្ថម្ភរបស់កម្មវិធីប្រល័យពូជសាសន៍កម្ពុជារបស់សាកលវិទ្យាល័យយែល ។ (ការិយាល័យស៊ើបអង្កេតអំពើប្រល័យពូជសាសន៍កម្ពុជា អឹអេភី ឬ ស៊ីជីអាយ, ការិយាយកិច្ចការអាស៊ី-ប៉ាស៊ីហ្វិក, ក្រសួងការបរទេសអាមេរិក និងឯកសារដែលបានរក្សាទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជា) ។

នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ១៩៩៦ រាជរដ្ឋាភិបាលកម្ពុជាបានលើកលែងទោសឲ្យ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីក្រសួងការបរទេសនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ការលើកលែងទោសនេះគិតតាំងពីពេលដែល អៀង សារី ត្រូវបានផ្តន្ទាទោសនៅក្នុងឆ្នាំ១៩៧៩ សូមបញ្ជាក់ថា អៀង សារី ត្រូវបានតុលាការប្រជាជនកាត់ទោសប្រហារជីវិតនិងរឹបអូសទ្រព្យសម្បត្តិផ្ទាល់ខ្លួនទាំងអស់ ។

នៅថ្ងៃទី១១ ខែមេសា ឆ្នាំ១៩៩៧ គណៈកម្មាធិការអាមេរិកស្តីអំពីសិទ្ធិមនុស្សបានអនុម័តសម្រេចក្នុងមាត្រា៤៩ ឆ្នាំ១៩៩៧ ។ សេចក្តីសម្រេចនោះ បានស្នើសុំអគ្គលេខាធិការតាមរយៈតំណាងរបស់លោក ដើម្បីពិនិត្យទៅលើសំណើសុំការជួយឧបត្ថម្ភក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាពីអតីតកាលរបស់ប្រជាជនកម្ពុជានិងច្បាប់អន្តរជាតិ ។

នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៩៧ សម្តេចព្រះនរោត្តមសីហនុបានមានព្រះបន្ទូលថា ព្រះអង្គត្រូវបានវិច្ឆ័យទោសជាមួយមេដឹកនាំខ្មែរក្រហមដើម្បីឆ្លើយបំភ្លឺទៅពួកអ្នករិះគន់ព្រះអង្គដែលបានអះអាងថា ព្រះអង្គត្រូវទទួលខុសត្រូវមួយផ្នែកចំពោះអំពើប្រល័យពូជសាសន៍ដែលបានកើតឡើងក្នុងរវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ ។

នៅថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៧ អតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ ខៀវ សំផន បានប្រកាសថា សុន សេន និង ប្រពន្ធរបស់គាត់ឈ្មោះ យុន យ៉ាត ត្រូវបានចាប់ខ្លួនពីបទចារកម្មនិងសកម្មភាពក្បត់ប្រឆាំងនឹងចលនាខ្មែរក្រហម ។ ខ្មែរក្រហមបានចោទប្រកាន់អ្នកទាំងពីរថា ជាចារកិច្ចរបស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២និងរដ្ឋាភិបាលរបស់វៀតណាម ។

នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៩៧ សុន សេន និងភរិយាឈ្មោះ យុន យ៉ាត និងសាច់ញាតិ៨នាក់ទៀតត្រូវបានសម្លាប់យ៉ាងរន្ធាល ។

នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ សម្តេចក្រុមព្រះនរោត្តមរណឫទ្ធិនាយករដ្ឋមន្ត្រីទី១ និងសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីទី២បានស្នើសុំជំនួយពីអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិ «ក្នុងការនាំអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោសចំពោះអំពើប្រល័យពូជសាសន៍និងបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ» ក្នុងអំឡុងពេលនៃរបបខ្មែរក្រហម ។ សំណើសុំជំនួយមានអត្ថន័យទាំងស្រុងដូចខាងក្រោមៈ

### ជម្រាបជូនលោកអគ្គលេខាធិការៈ

តាងនាមឲ្យប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជា យើងខ្ញុំសរសេរជូនលោកដើម្បីស្នើសុំជំនួយពីអង្គការសហប្រជាជាតិនិងសហគមន៍អន្តរជាតិក្នុងការនាំមេដឹកនាំដែលខុសត្រូវខ្ពស់បំផុតមកកាត់ទោសពីបទប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងអំឡុងពេលនៃការកាន់អំណាចរបស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។

នៅខែមេសា ឆ្នាំ១៩៩៧ សេចក្តីសម្រេចចំពោះកម្ពុជា

របស់បេសកកម្មអង្គការសហប្រជាជាតិស្តីអំពីសិទ្ធិមនុស្សបានស្នើថា «លោកអគ្គលេខាធិការតាមរយៈតំណាងពិសេសរបស់លោកក្នុងកិច្ចប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសិទ្ធិមនុស្ស ដើម្បីពិនិត្យរាល់សំណើរបស់កម្ពុជាចំពោះជំនួយក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាដ៏ធ្ងន់ធ្ងរពីអតីតកាលរបស់ប្រជាជនកម្ពុជានិងច្បាប់អន្តរជាតិក្នុងន័យនាំមកនូវការផ្សះផ្សាជាតិ លទ្ធិប្រជាធិបតេយ្យពេញលេញនិងការបកស្រាយពីបញ្ហានៃការទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ» ។

ប្រទេសកម្ពុជាពុំមានធនធាននិងអ្នកជំនាញដើម្បីរៀបចំដំណើរការដ៏សំខាន់នេះបានត្រឹមត្រូវតាមនីតិវិធីទេ ។ ដូច្នេះយើងជឿថា ដំណើរតាមនីតិវិធីគឺជាការចាំបាច់ត្រូវការជំនួយពីអង្គការសហប្រជាជាតិ ។ យើងដឹងថា ជាការខិតខំប្រឹងប្រែងស្រដៀងគ្នានឹងអំពើប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងប្រទេសរ៉្វាន់ដានិងអតីតយូហ្គោស្លាវី ហើយដែលថា ជំនួយប្រហាក់ប្រហែលគ្នានេះត្រូវបានផ្តល់មកឲ្យកម្ពុជា ។

សូមលោកអគ្គលេខាធិការទទួលនូវការគោរពរាប់អានដ៏ខ្ពស់អំពីយើងខ្ញុំ ។

សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** នាយករដ្ឋមន្ត្រីទី១

សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី២

## ក្រុមប្រឹក្សាសន្តិសុខ:

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ មហាសន្និបាតរបស់អង្គការសហប្រជាជាតិបានអនុម័តសម្រេចលេខ៥២,១៣៥ ដែលបង្គាប់ឲ្យអគ្គលេខាធិការត្រួតពិនិត្យសំណើរបស់អាជ្ញាធរកម្ពុជាចំពោះជំនួយក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាពីអតីតកាលរបស់ប្រជាជនកម្ពុជានិងច្បាប់ ។ ខាងក្រោមនេះជាផ្នែកខ្លះនៃសេចក្តីសម្រេចៈ

ក្នុងឆន្ទៈថា ប្រវត្តិសាស្ត្រដ៏ខ្មៅងងឹតរបស់ប្រទេសកម្ពុជាតម្រូវឲ្យមានការដាក់សម្ពាធដើម្បីធានាឲ្យបាននូវសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា ដើម្បីកុំឲ្យរបបនយោបាយនិងការអនុវត្តនៃអតីតកាលវិលត្រឡប់មកម្តងទៀតដូចច្បាប់ដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនៅទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១ ។

តាមការអធិប្បាយព្រមព្រៀងរបស់តំណាងពិសេសថ្លែងថា អំពើហិង្សារំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតនៅក្នុងប្រទេសកម្ពុជាក្នុងប្រវត្តិសាស្ត្រថ្មីៗនេះ គឺបង្កឡើងដោយខ្មែរក្រហមនិងថា បទឧក្រិដ្ឋរបស់មេដឹកនាំទាំងនោះ ដែលរាប់បញ្ចូលទាំងការសម្លាប់អ្នកទោស ហើយដែលបានបន្តមកដល់បច្ចុប្បន្ននិងតាមកត់សម្គាល់ដោយការព្រួយបារម្ភថា គ្មានមេដឹកនាំណាម្នាក់ត្រូវបាននាំមកកាត់ទោសចំពោះបទឧក្រិដ្ឋទាំងនោះឡើយ ។

លោកអគ្គលេខាធិការស្នើសុំឲ្យពិនិត្យលើសំណើរបស់អាជ្ញាធរកម្ពុជាសម្រាប់ជំនួយក្នុងការឆ្លើយតបទៅនឹងអំពើហិង្សាដ៏ធ្ងន់ធ្ងររបស់ប្រជាជនកម្ពុជានិងច្បាប់អន្តរជាតិដែលរួមទាំងលទ្ធភាពនៃការកំណត់ពេលដោយអគ្គលេខាធិការរបស់ក្រុមអ្នកជំនាញមួយក្រុមដើម្បីវាយតម្លៃលើភ័ស្តុតាងដែលមាននិងដាក់សម្ពាធបន្ថែមដើម្បីជាមធ្យោបាយក្នុងការនាំមកនូវការផ្សះផ្សាជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ និងដោះស្រាយបញ្ហាទទួលខុសត្រូវរបស់បុគ្គលម្នាក់ៗ ។

នៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ប៉ុល ពត បានស្លាប់ដោយសារជំងឺគាំងបេះដូងនៅក្នុងជន្មាយុ៧៣ឆ្នាំ នៅស្រុកអន្លង់វែងក្បែរព្រំដែនថៃ ជាកន្លែងដែល ប៉ុល ពត ត្រូវបានឃុំឃាំងបន្ទាប់ពីត្រូវកាត់ទោសនៅថ្ងៃទី២៥ ខែកក្កដា ឆ្នាំ១៩៩៧ ។

នៅថ្ងៃទី១៣ ខែកក្កដា ឆ្នាំ១៩៩៨ អនុលោមតាមមហាសន្និបាតសម្រេចលេខ៥២,១៣៥ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៧ មហាសន្និបាតបានតែងតាំងក្រុមអ្នកជំនាញការបីរូបមកកម្ពុជាដើម្បីវាយតម្លៃលើភ័ស្តុតាងដែលមាននិងដើម្បីពិនិត្យជម្រើសក្នុងការនាំយកមេដឹកនាំខ្មែរក្រហមទៅកាត់ទោសនៅចំពោះមុខយុត្តាធិការជាតិនិងអន្តរជាតិ ។

នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៨ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ បានបង្កើតក្រុមអ្នកជំនាញមួយក្រុមដោយមានលោក នីនៀន ស្ទីហ្វិន មកពីប្រទេសអូស្ត្រាលី ជាប្រធាន, ចៅក្រម រ៉ាសូមម័រ ឡាឡាស មកពីកោះម៉ូរីសឺស និងសាស្ត្រាចារ្យស្ទីវិន រ៉ាន់ន័រ មកពីសហរដ្ឋអាមេរិក ដើម្បីដំណើរការលទ្ធភាពនៃការនាំខ្លួនមេដឹកនាំមកកាត់ទោស ។

នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសពីការចុះចូលជាមួយរដ្ឋាភិបាលរបស់មេដឹកនាំជាន់ខ្ពស់ពីរូបគឺ នួន ជា និង ខៀវ សំផន ។

***(នៅមានត)***

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

# កុលសម្ព័ន្ធស្ទៀងក្រោមរបបខ្មែរក្រហម

កុលសម្ព័ន្ធស្ទៀងជាក្រុមដែលស្ថិតក្នុងអម្បូរខ្មែរមនដូចជនជាតិ ក្ួយ រដែ និងសំរែ ។ កុលសម្ព័ន្ធនេះមាន ទំនៀមទម្លាប់ ប្រពៃណី ជំនឿ និងភាសារបស់ខ្លួនខុសប្លែកពីជនជាតិដទៃ ។ ភាគច្រើននៃ កុលសម្ព័ន្ធស្ទៀងច្រើនរស់នៅក្នុងតំបន់ខ្ពង់រាប ក្នុងស្រុកមេមត់ ខេត្តកំពង់ចាមនិងស្រុកស្នួល ខេត្តក្រចេះ នាតំបន់ខ្ពង់រាបព្រំដែន វៀតណាម ជាហេតុធ្វើឲ្យខ្មែរក្រហមពុំមានការទុកចិត្តលើអ្នកទាំង នេះដោយចោទថាជាភ្នាក់ងារវៀតណាមហើយត្រូវចាប់សម្លាប់និង ជម្លៀសជនជាតិនេះឲ្យទៅរស់នៅតំបន់ផ្សេងៗ ។

ដោយឡែក កុលសម្ព័ន្ធស្ទៀងរស់នៅឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម មានភាសានិយាយខុសគ្នា ពីស្ទៀងនៅស្រុកស្នួល ខេត្តក្រចេះនិងនៅខេត្តឡុកនិញប្រទេសវៀតណាម ។ បើតាម ការ រៀបរាប់របស់ព្រឹទ្ធាចារ្យជនជាតិស្ទៀងបានឲ្យដឹងថា ស្ទៀងនៅ ឃុំជាំតាម៉ៅ ក្នុងស្រុកមេមត់ ហៅថា «ស្ទៀងខាន» មានន័យថា «មិនដូច» ។ ឯជនជាតិស្ទៀងនៅឃុំតាលូង ស្រុកមេមត់ និងជនជាតិ ស្ទៀងនៅស្រុកស្នួល ខេត្តក្រចេះ មានដើមកំណើតនៅឡុកនិញ ប្រទេសវៀតណាមគឺមានភាសានិងប្រពៃណីទំនៀមទម្លាប់ដូចគ្នា ។

បើតាមការរៀបរាប់របស់លោកតា ចយ សាលី និង ចាន់ ជីម ជនជាតិស្ទៀង រស់នៅឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តកំពង់ចាម មានដើមកំណើតមកពីស្រុកត្បូងឃ្មុំ គឺជាជនជាតិស្ទៀងរស់នៅ មិនបំណុះគេ បានភៀសខ្លួនពីការតាមសម្លាប់របស់រាជការស្តេច រាមាដែលត្រូវចោទថាបានឃុបឃិតជាមួយចៅហ្វាយស្រុកត្បូងឃ្មុំ ឈ្មោះ អរ ជូន សម្លាប់ម៉ឺនឯក ទុំ តាំងពីជំនាន់រឿងទុំទាវ ។ ចាស់ទុំ ជនជាតិស្ទៀងនៅឃុំនេះបានហាមប្រាមកូនចៅមិនឲ្យរំឭកឬ និយាយពីរឿងទុំទាវរហូតដល់របបកម្ពុជាប្រជាធិបតេយ្យ ទើបការ ហាមប្រាមនេះបានសាបរលាបតាមពេលវេលានិងកាលៈទេសៈ ។ បើអ្នកណាហ៊ានល្មើស គឺត្រូវស្តីបន្ទោសនិងធ្វើទារុណកម្ម ។ ប៉ុន្តែ ជនជាតិស្ទៀងបានលាក់ប្រវត្តិដើម ដោយប្រឌិតរឿងផ្សេងប្រាប់ កូនចៅស្ទៀងជំនាន់ក្រោយថា ពួកខ្លួនមានដើមកំណើតពីភូមិកន្ទួត ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ហើយមានមុខរបរដាំកប្បាសលក់ ។ ប្រជាជនទទួលកម្រៃបន្តិចបន្តួចពីការលក់កប្បាស ប៉ុន្តែដោយសារ កប្បាសមានទម្ងន់ស្រាល អ្នកភូមិបានបែកគំនិតខូចនាំគ្នាលួចដាក់ ដុំថ្មក្នុងការុងកប្បាសយកទៅថ្លឹងលក់ឲ្យរាជការស្តេច ។ ក្រោយមក រាជការដឹងក៏យកដុំថ្មនោះទៅឲ្យអ្នកភូមិរក្សាទុកជាភស្តុតាង ហើយបានព្រមានថា បើធ្វើឲ្យបាត់ដុំថ្មនោះរាជការនឹងកាត់



ជនជាតិស្ទៀងនៅភូមិជាំតាម៉ៅ

ទោស ។ ដោយសារមូលហេតុនេះទើប អ្នកភូមិដែលជាប់ពិរុទ្ធបាននាំគ្នារត់មក តាំងទីលំនៅក្នុងភូមិកន្ទួតដោយរក្សាដុំថ្ម នោះទុកជាភស្តុតាងរហូតដល់របបកម្ពុជា ប្រជាធិបតេយ្យទើបដុំថ្មនោះបាត់ ។ ប៉ុន្តែ មានជនជាតិស្ទៀងជាច្រើនដឹងប្រវត្តិត្រឹម តែរាជការតាមចាប់បណ្តាលមកពីការ យកដុំថ្មដាក់ក្នុងកប្បាសប៉ុណ្ណោះ ទោះបីជា យ៉ាងណាក៏ជនជាតិស្ទៀងមិនបានដឹងអំពី ប្រវត្តិរបស់ជនជាតិស្ទៀងដែលរត់មកពី ត្បូងឃ្មុំឡើយ ។ ជនជាតិស្ទៀងមានការ

ឆ្ងល់ជាខ្លាំងដែរថា ហេតុអ្វីទើបដូនតានិងឪពុកម្ដាយរបស់គាត់មិនឲ្យរំពុករឿងទំនាវនៅក្នុងភូមិស្រុករបស់គាត់ ។

## ការរស់នៅនិងការរៀបអាពាហ៍ពិពាហ៍

ការរស់នៅរបស់ជនជាតិស្ទៀងនៅឃុំជាំតាម៉ៅនាសម័យមុនមានជីវភាពប្រហាក់ប្រហែលជនជាតិព្នង ។ ជនជាតិស្ទៀងចូលចិត្តធ្វើចម្ការ និងបរបាញ់សត្វដើម្បីចិញ្ចឹមជីវិត ។ ផ្ទះរបស់ជនជាតិស្ទៀងសង់ខ្ពស់ផុតពីដី ដោយធ្វើរោងដោលនៅពីមុខនិងចំហៀងផ្ទះ ។ ស្ទៀងប្រុស វិណ្ឌកន្ទុប ហើយស្ទៀងស្រីស្លៀកសំពត់ចោមពុងលើជង្គង់ មិនចូល ចិត្តចោះត្រចៀកនិងបួងសក់ឡើយ ។ ជនជាតិស្ទៀងមានជំនឿលើព្រលឹងតាមបែបព្រហ្មញ្ញ សាសនា គឺធ្វើការបន់ស្រន់ សែនព្រេនអង្វរសុំសេចក្ដីសុខដល់ ក្រុមគ្រួសារ និងមានជំនឿយ៉ាងខ្លាំងថា ជំងឺផ្សេងៗបណ្ដាលមកពីការខឹងសម្បានៃអារក្សអ្នកតា ។ នៅពេលមានអ្នកណាម្នាក់ឈឺ គេតែងតែបន់ស្រន់អារក្សអ្នកតាដោយថ្វាយស្រា មាន់ ជ្រូក គោ ព្រមទាំងមានភ្លេងនិងចង្រៀងអង្វរតាមចង្វាក់ភ្លេងអារក្សដើម្បីសុំឲ្យអារក្សអ្នកតាឈប់ខឹងសម្បានិងឲ្យអ្នកជំងឺបានជាសះស្បើយឡើងវិញ ។ នៅពេលមានជម្លោះនៅក្នុងកុលសម្ព័ន្ធ អ្នកភូមិប្រកាន់យកការស្បថជាធំ ព្រោះជនជាតិស្ទៀងយល់ថាការស្បថស្បែអាចបញ្ឈាក់អំពីទឹកចិត្តមនុស្សនិងអាចដោះស្រាយបញ្ហាបានលឿន ។

## ការផ្លាស់ប្ដូរ

ក្នុងឆ្នាំ១៩៦៨-៦៩ មានកងទ័ពអាមេរិកាំងមួយចំនួនបានចូលបោះទីតាំងនៅក្នុងឃុំជាំតាម៉ៅ ដើម្បីចាំស្ទាក់កងទ័ពវៀតកុងដែលចូលមកជ្រកកោនក្នុងទឹកដីកម្ពុជា ។ ប៉ុន្តែប៉ុន្មានខែក្រោយមកកងទ័ពអាមេរិកទាំងនោះបានដកទៅវិញដោយមិនដឹងមូលហេតុ ។

ក្រោយរដ្ឋប្រហារឆ្នាំ១៩៧០ មានមនុស្សប្លែកមុខជាច្រើនបានចូលមកធ្វើការជួញដូរក្រោមរូបភាពឃោសនាបញ្ចុះបញ្ចូលអ្នកភូមិអំពីវណ្ណៈសក្ដិភូមិជិះជាន់កេងប្រវ័ញ្ចលើវណ្ណៈកម្មករកសិករ និង ឲ្យអ្នកភូមិកសាងសង្គមស្អាតស្អំបរិសុទ្ធមួយដែលមានតែវណ្ណៈមួយស្មើភាពគ្នានៅក្នុងឃុំជាំតាម៉ៅទាំងមូល ។ ប៉ុន្មានខែក្រោយមកកងទ័ពខ្មែរក្រហមបានបង្ខំឲ្យអ្នកភូមិឡើងរថយន្តទៅធ្វើបាតុកម្មនៅស្រុកមេមត់និងព្រៃទទឹង ដើម្បីទាមទារឲ្យសម្ដេចសីហនុត្រឡប់មកកាន់អំណាចវិញ ។ ប្រសិនបើអ្នកណាមិនទៅ នឹងត្រូវគំរាមសម្លាប់ចោល ។ ដោយសារមានការភ័យខ្លាចនិងមានការជឿជាក់កូនចៅអ្នកភូមិជាច្រើនបានលួចឡើងឡានទៅចូលរួមធ្វើបាតុកម្ម ប៉ុន្តែជាលទ្ធផល អ្នកភូមិមួយចំនួនបានស្លាប់និងរងរបួសជាទម្ងន់ដោយសារការបង្ក្រាបរបស់ទាហាន លន់ នល់ ។ ក្រោយពីព្រឹត្តិការណ៍បាតុកម្ម ឃុំនេះកាន់តែមានមនុស្សប្លែកមុខជាច្រើន ដូចជា ពេជ សួន ជាដើមដែលតាំងខ្លួនជាអ្នករំដោះប្រទេសជាតិ រំដោះវណ្ណៈនិងរំដោះប្រជាជនឲ្យរួចផុតពីនឹមចក្រពត្តិនិងមូលធននិយម បន្ទាប់មកបានបង្ខំប្រជាជនក្នុងឃុំឲ្យផ្ដល់ស្បៀងឲ្យក្រុមរបស់ខ្លួនជាប្រចាំ ។ ក្នុងចំណោមអ្នកទាំងនោះ មានឈ្មោះ តាម៉ៅ និងតាឡាច ជាអ្នកបញ្ចុះបញ្ចូលប្រជាជនឲ្យចូលរួមសកម្មភាពរបស់ខ្លួន ។ ក្រោយឆ្នាំ១៩៧៥ តាម៉ៅ បានក្លាយជាប្រធានមន្ទីរពេទ្យស្រុកមេមត់ ហើយបច្ចុប្បន្នគាត់នៅរស់រានមានជីវិតនៅឡើយ ។

ចុងឆ្នាំ១៩៧១ ខ្មែរក្រហមបានជ្រើសរើស ឆ្លួញ, តាឡាវ, មុត, ជាប្រធាន និងជាសមាជិកឃុំ ដើម្បីប្រមូលស្បៀងនិងដឹកនាំប្រជាជនឲ្យធ្វើតាមឱវាទរបស់ខ្លួន ។ ប៉ុន្មានខែបន្ទាប់មក មានកងទ័ពយៀកកុងបានដើរចេញចូលក្នុងឃុំនេះ ប៉ុន្តែទាហានទាំងនោះពុំបានធ្វើទុក្ខបុកម្នេញអ្នកភូមិឡើយ ។ ក្នុងពេលជាមួយគ្នាក៏មានទាហាន លន់ នល់ ចេញចូលក្នុងឃុំនេះដែរដើម្បីតាមរកចាប់ខ្មែរក្រហមនិងវៀតកុង ។ អ្នកភូមិមានការលំបាកយ៉ាងខ្លាំងក្នុងការប្រឈមមុខដោះស្រាយជាមួយទាហានទាំងសងខាង ពីព្រោះនៅពេលថ្ងៃ ទាហាន លន់ នល់ ចូលមកសម្ភតអ្នកភូមិដើម្បីរកខ្មែរក្រហម ហើយនៅពេលយប់ក្រុមខ្មែរក្រហមបង្ខំឲ្យអ្នកភូមិផ្ដល់ស្បៀងអាហារនិងជួយសែងកងទ័ពរបួស ។ បន្ទាប់ពីស៊ើបដឹងថានៅឃុំជាំតាម៉ៅ មានកងទ័ពយៀកកុងនិងលាក់ខ្មែរក្រហមនៅទីនោះ សម្ព័ន្ធមិត្តរបស់ លន់ នល់ បានធ្វើការបាញ់ផ្លោងនិងទម្លាក់គ្រាប់បែកយ៉ាងខ្លាំងទៅលើឃុំនេះ បណ្ដាលឲ្យបាត់បង់ជីវិតមនុស្សនិងខូចខាតទ្រព្យសម្បត្តិអស់ជាច្រើន ។

នៅឆ្នាំ១៩៧២ ខ្មែរក្រហមបានចាប់ផ្ដើមបង្ខំកូនចៅរបស់អ្នកភូមិឲ្យចូលបម្រើក្នុងជួរទ័ពរំដោះ ហើយការគ្រប់គ្រងក្នុងឃុំបានចាប់ផ្ដើមផ្លាស់ប្ដូរជាបណ្ដើរៗ ដោយតម្រូវឲ្យប្រជាជនទាំងអស់ធ្វើស្រែប្រវាស់ដៃនិងក្រុមសាមគ្គី ។ ចំណែកភោគផលដែលទទួលបានគឺត្រូវបែងចែកទៅតាមកម្លាំងពលកម្ម និងចំនួនសមាជិក

ដែលមាននៅក្នុងគ្រួសារ ។ ចំណែកយុវជនពេញវ័យត្រូវចេញទៅសមរភូមិមុខ ដើម្បីវាយប្រយុទ្ធរំដោះទឹកដីពីវណ្ណៈសក្តិភូមិនាយទុន ។

ឆ្នាំ១៩៧៣ ខ្មែរក្រហមតម្រូវឲ្យអ្នកភូមិទាំងអស់ប្រមូលទ្រព្យសម្បត្តិដីស្រែ គោ ក្របី សម្ភារៈប្រើប្រាស់ដាក់រួមនិងហូបបាយរួមនៅសហករណ៍ ។ ចំណែកឯប្រពៃណី ទំនៀមទម្លាប់ និងភាសារបស់អ្នកភូមិត្រូវហាមប្រាមមិនឲ្យអនុវត្តឬនិយាយទេ ។

## ជនជាតិស្មៀងក្រោមរបបខ្មែរក្រហម

ក្រោយពីខ្មែរក្រហមកាន់កាប់ប្រទេសបានទាំងស្រុងក្នុងឆ្នាំ១៩៧៥ គណៈឃុំចាស់ៗជាជនជាតិស្មៀងត្រូវផ្លាស់ចេញដោយដាក់ជំនួសគណៈឃុំដែលជាជនជាតិខ្មែរមកពីកន្លែងផ្សេងរួមមាន តាកុក, តាប្រង់ ,តាង៉ែន, តាឆួត, តាឡាចនិងស៊ឹង ។ ប្រជាជនមួយចំនួនត្រូវអង្គការចោទថា បានធ្វើវិទ្ធង្សនាបដិវត្តន៍ហើយត្រូវចាប់ខ្លួនទៅដាក់នៅមន្ទីរសន្តិសុខដូនពុំពល ។ លើសពីនេះទៀតភាសាដើមកំណើតរបស់អ្នកភូមិត្រូវហាមឃាត់មិនឲ្យនិយាយ ។

ក្នុងឆ្នាំនោះដែរ ប្រជាជន១៧មេសារាប់ពាន់នាក់ត្រូវបានជម្លៀសឲ្យទៅនៅឃុំជាំតាម៉ៅ ។ ភាគច្រើននៃអ្នកទាំងនោះគឺជាជនជាតិខ្មែររស់នៅទីក្រុងដោយមិនចេះដាំដំណាំនិងធ្វើស្រែចម្ការឡើយ ។ អ្នកទាំងនេះត្រូវចាត់ចូលជាប្រជាជនបញ្ញើក្អែក ឬប្រជាជនប្រភេទទី៣ និងត្រូវទទួលការរិះគន់ និងគាបសង្កត់យ៉ាងខ្លាំងពីអង្គការនិងប្រជាជនមូលដ្ឋាន ។ អង្គការមិនអនុញ្ញាតឲ្យប្រជាជន១៧មេសារស់នៅលាយលំជាមួយជនជាតិស្មៀងដែលជាប្រជាជនមូលដ្ឋានឡើយ ។ អ្នកទាំងនេះស្ថិតនៅក្រោមការឃ្លាំមើលរបស់ប្រជាជនមូលដ្ឋាននិងអង្គការយ៉ាងហ្មត់ចត់ទាំងការហូបចុកនិងធ្វើពលកម្ម ។ ការមករស់នៅលើទឹកដីនៃតំបន់ខ្ពង់រាបដែលជាតំបន់ព្រៃនិងសម្បូរដោយសត្វល្អិត រួមផ្សំការខ្វះថ្នាំសង្កូវអាហារ សម្ភារការពារខ្លួននិងបង្ខំឲ្យធ្វើពលកម្មហួសកម្លាំង បានធ្វើឲ្យប្រជាជនទាំងនោះកើតជំងឺគ្រុនចាញ់និងបាត់បង់ជីវិតស្ទើរតែគ្មានសល់ ។ ក្រៅពីនោះ ជនជាតិស្មៀងត្រូវអង្គការចាប់ទៅមន្ទីរសន្តិសុខដូនពុំពលពីបទចូលដៃជើងជាមួយវៀតណាម ។ ស៊ឹង ជាប្រធានមន្ទីរសន្តិសុខ ។ ពៅ ដួ ដែលជាអតីតកងទ័ពខ្មែរក្រហមបច្ចុប្បន្នជាប្រធានឃុំតាម៉ៅបានអះអាងថា គាត់ជាសាក្សីឃើញផ្ទាល់ភ្នែកចំពោះការសម្លាប់ប្រជាជន១៧មេសាបីនាក់នៅក្នុងអង្គមីទ្ទិងមួយដែលគ្រាន់តែអ្នកទាំងបីនោះបានមកលេងឪពុកម្តាយនៅឯភូមិប៉ុណ្ណោះ ។ អង្គការបែរជាចោទថារត់ចូលប្រទេសវៀតណាមទៅវិញ ។

ទោះបីអង្គការបានចាត់ទុកខ្លួនឯងជាអ្នករំដោះប្រទេសពីវណ្ណៈសក្តិភូមិមូលធនដែលជាសត្រូវខាងក្នុងក៏ដោយក៏អង្គការនៅតែមានការភ័យខ្លាចជានិច្ចចំពោះសត្រូវខាងក្រៅដែលមានប្រទេសវៀតណាមជាឧទាហរណ៍ ។ អង្គការនៅតែជ្រើសរើសយុវជនមូលដ្ឋាន ក្មេងយកទៅធ្វើទ័ពដើម្បីការពារនៅតាមបណ្តោយព្រំដែនខ្មែរវៀតណាម ។ កូនចៅជនជាតិស្មៀងជាច្រើននាក់ដែលមានអាយុទើបតែជាង១០ឆ្នាំ ត្រូវបង្ខំឲ្យចូលធ្វើកងទ័ពនៅសមរភូមិមុខ ។ ក្រោយឆ្នាំ១៩៧៩ មានតែប៉ុន្មាននាក់ប៉ុណ្ណោះដែលមានវាសនាវិលត្រលប់មកភូមិកំណើតវិញ ។ ពៅ ដួ បានរៀបរាប់ទាំងឈឺចាប់ថា គាត់ចូលបម្រើទ័ពខ្មែរក្រហមដើម្បីរំដោះជាតិរំដោះវណ្ណៈឲ្យរួចផុតពីនឹមចក្រពត្តិសក្តិភូមិមូលធន ។ គាត់ស្ទើរតែបាត់បង់ជីវិតពីរបីដងនៅសមរភូមិ ប៉ុន្តែដល់ទីបំផុតអង្គការបែរជាចោទថា «ក្បាលយួនខ្លួនខ្មែរ» ហើយបានបញ្ជាឲ្យឈ្លបក្មេងៗដែលមានអាយុ៨-៩ឆ្នាំ មកពីភូមិភាគនិរតីវាយនិងដៀលត្មះគាត់ដូចសត្វធាតុ ។ គាត់និងមិត្តរួមអាវុធរបស់គាត់ស្ទើរទ្រាំមិនបានគិតគ្នាសម្លាប់កូនឈ្លបនោះចោលហើយនាំគ្នារត់ ប៉ុន្តែចិត្តមួយគិតទាន់ថា ក្រុមគាត់ពុំអាចរត់រួចផុតពីទឹកដីខ្មែរទេ ពីព្រោះជាទឹកដីដែលកាន់កាប់ដោយខ្មែរក្រហមទីណាក៏មានខ្មែរក្រហមដែរ ។ ចុងឆ្នាំ១៩៧៨ សភាពការណ៍កាន់តែដុនដាប ក្រុមរបស់គាត់បានបន្ទំជាមួយប្រជាជនជម្លៀសទៅរស់នៅខេត្តកំពង់ធំ ។ ក្រោយឆ្នាំ១៩៧៩ គាត់បានត្រឡប់មកភូមិកំណើតវិញ ហើយរស់នៅក្នុងឃុំតាម៉ៅនេះ ។

ចាន់ ជីន បានរៀបរាប់ពីជីវិតកងទ័ពថា ក្នុងឆ្នាំ១៩៧៥ គាត់ដែលមានអាយុ១៥ឆ្នាំ ត្រូវកម្មាភិបាលឃុំឈ្មោះ ឡាច បង្ខំឲ្យទៅសមរភូមិមុខ ។ ម្តាយរបស់គាត់បានយំអង្វរ តាឡាច កុំឲ្យបញ្ជូនគាត់ទៅសមរភូមិមុខ ។ ទោះបីមានការអង្វរករយ៉ាងណា ក៏ តាឡាច ពុំព្រមធ្វើតាមសំណើរបស់គាត់ដែរ ។ ជីន និងកូនអ្នកភូមិជាច្រើនត្រូវបញ្ជូនទៅធ្វើទ័ពនៅព្រំដែនទន្លេចាមក្នុងតំបន់២១ ចាប់ពី

ចាន់មូលព្រែកស្វាយហូតដល់កោះជ្រៃទល់ព្រំដែនខេត្តឡុកនិញនៃប្រទេសវៀតណាម ។ ទៅដល់ភ្លាមគាត់និងយុទ្ធជនក្មេងត្រូវទទួលការបែងចែកទៅតាមតួនាទី អ្នកខ្លះនៅទ័ពថ្មើរជើង អ្នកខ្លះទៀតនៅផ្នែករត់សំបុត្រនិរសារក្នុងសមរភូមិមុខ បន្ទាប់មកទើបឲ្យទៅហ្វឹកហ្វឺននយោបាយបំពាក់បំប៉នសតិអារម្មណ៍អំពីប្រវត្តិ «យួនដាំតែអុង» និងការបាត់បង់ទឹកដីកម្ពុជាក្រោម ។ ក្នុងពេលនោះគាត់ព្រមទាំងយុទ្ធជនក្មេងៗទាំងអស់មានកំហឹងនិងឈឺចាប់យ៉ាងខ្លាំងចំពោះការឈ្លានពានរបស់វៀតណាម ។ គាត់មានចិត្តអន្ទះសាចង់ចូលរួមក្នុងសមរភូមិប្រយុទ្ធភ្លាមដោយមិនខ្លាចស្លាប់ ។ រយៈពេលនៃការចូលបម្រើក្នុងជួរទ័ព គាត់បានឡើងប្រយុទ្ធនៅសមរភូមិពីរដងចាប់បានវៀតណាម២នាក់ ។ គាត់ចង់វាយធ្វើបាបវៀតណាមទាំងពីរនាក់នោះជាខ្លាំង ប៉ុន្តែត្រូវប្រធានហាមឃាត់មិនឲ្យធ្វើបាបទាំងពីរនាក់នោះទេ ពីព្រោះខ្លាចមានបញ្ហានយោបាយក៏បញ្ជូនមកទីក្រុងភ្នំពេញ ។ ឆ្នាំ១៩៧៧ ប្រធានកងពលឈ្មោះ ដែន និងប្រធានវរៈសេនា០២ ត្រូវអង្គការចាប់ខ្លួនពីបទ«ក្បាលយួនខ្លួនខ្មែរ» ។ ចាន់ ជីន ត្រូវផ្លាស់មកកង យ៧៨ ក្រោមការដឹកនាំរបស់ឈ្មោះ ចាន់ ប្រធាន» និងចេន អនុវរៈនោយ-៧៨ ។ គាត់ពុំមានសង្ស័យថាគោលនយោបាយខ្មែរក្រហមដែលបំពាក់បំប៉នសតិអារម្មណ៍យុទ្ធជនឲ្យប្រយុទ្ធប្រឆាំងជាមួយវៀតណាមនោះ អាចយកជ័យជម្នះបានឡើយ ពីព្រោះទ័ពវៀតណាមប្រៀបដូចជា «កម្លាំងយក្ស» និងកម្លាំងហនុមាន ចំណែកឯខាងខ្មែរមានតែការសង្ស័យនិងការកាប់សម្លាប់គ្នាទៅវិញទៅមក ពុំមានសាមគ្គីគ្នាសោះ ។ នៅខែ១០ ឆ្នាំ១៩៧៨ អ្នកទាំងពីរក៏មានវាសនាដូចអ្នកមុនដែរ ។ គាត់ត្រូវអង្គការចាប់ខ្លួនពីបទបរាជ័យដូនៗនៅក្នុងសមរភូមិ ។ ចំណែក ចាន់ ជីន និងទាហានទាំងអស់ត្រូវអង្គការដកកាំភ្លើង ហើយឲ្យទៅលត់ដំស្ទូងស្រែនៅកោះកែ ក្នុងខេត្តស្ទឹងត្រែង ។ ក្នុងពេលនោះដែរគាត់បានជួបឪពុកម្តាយឡើងវិញ ។ អ្នកភូមិទាំងអស់នៅក្នុងឃុំត្រូវខ្មែរក្រហមជម្លៀសឲ្យនៅស្រុកសំបូរខេត្តក្រចេះ ។ កន្លះខែក្រោយមក គាត់ឮដំណឹងថា ម្តាយរបស់គាត់ស្លាប់ដោយជំងឺនៅក្នុងមន្ទីរពេទ្យស្រុក ទើបធ្វើឲ្យគាត់ស្តុតស្មារតីនិងអស់សង្ឃឹមជាខ្លាំងចំពោះគោលនយោបាយរបស់អង្គការ ។ បន្ទាប់មក គាត់ត្រូវផ្លាស់ទៅនៅជាំជ្រៃស្រុកចម្ការលើ ។ ឆ្នាំ១៩៧៩ ចាន់ ជីន ត្រឡប់មកស្រុកកំណើតដោយបន្សល់ទុកនូវការឈឺចាប់យ៉ាងខ្លាំងចំពោះការបាត់បង់ម្តាយជាទីស្រឡាញ់ ។

ញ៉ែម ឆាន ជាជនជាតិស្មៀងរស់នៅភូមិថ្មល់កែង ឃុំជាំតាម៉ៅ ត្រូវបង្ខំឲ្យចូលបដិវត្តន៍ ក្នុងអាយុ១៥ឆ្នាំដែរ ។ គាត់ត្រូវអង្គការហាមឃាត់មិនឲ្យនិយាយភាសាស្មៀង បើមិនដូច្នេះទេគាត់នឹងទទួលទោស ។ វិន័យនេះធ្វើឲ្យគាត់មានការភិតភ័យ និងខ្លាចអង្គការយ៉ាងខ្លាំង សូម្បីតែមើលមុខអង្គការក៏មិនហ៊ានដែរ ។ ញ៉ែម ឆាន និងកុមារ៦នាក់ទៀត ត្រូវបញ្ជូនទៅធ្វើនិរសារនៅសមរភូមិមុខក្នុងវរៈ១០១ដែលមានឈ្មោះ ដែន ប្រធានកងពល និង ឈ្មោះ អ៊ឹម ជាប្រធានវរៈ ។ ញ៉ែម ឆាន និយាយថាគាត់ភ័យខ្លាំងណាស់នៅពេលដែលប្រធានបញ្ជាឲ្យគាត់យកសំបុត្រកាត់ខ្សែត្រៀមដែលកំពុងប្រយុទ្ធគ្នា ។ គ្រាប់កាំភ្លើងបានហើរកាត់ពីមុខពីក្រោយនៅពេលគាត់កំពុងរត់សំដៅទៅខ្សែត្រៀមមួយទៀត ។ គាត់មិនអាចឈប់គេចវេះឬរេរានៅតាមផ្លូវបានឡើយទោះបីមានឧបសគ្គយ៉ាងណាក៏ដោយ បើមិនដូច្នេះទេគាត់នឹងខុសវិន័យនិរសារ ហើយច្បាស់ជាត្រូវប្រធានចាប់បាញ់ចោលមិនខាន ។ ឆាន់ មិន អាចបំភ្លេចរបបខ្មែរក្រហមឡើយ ។ គាត់និយាយថា «ខ្មែរក្រហមច្រើនតែនិយាយពាក្យបាញ់និងកាប់ចាក់នៅក្នុងអង្គភាពរបស់ខ្ញុំ» ។ ឧទាហរណ៍ជាក់ស្តែងនៅក្នុងកងវរៈរបស់គាត់មានទ័ពម្នាក់ឈ្មោះ សារិន ត្រូវចាប់បាញ់ចោលដោយគ្រាន់តែសួររកបាយ


ជនជាតិស្មៀងនៅភូមិក្តុល

ហូបប៉ុណ្ណោះ ។ ចំណែកឪពុកមាររបស់គាត់ឈ្មោះ ប៉ិច វណ្ណា ជាប្រធានគក្នុងកងពលលេខ១០៤ ត្រូវចាប់បាញ់សម្លាប់ដោយសារខ្សែត្រៀមរបស់គាត់ប្រយុទ្ធចាញ់កងទ័ពវៀតណាម ។

ចុងឆ្នាំ១៩៧៧ កម្មាភិបាលឃុំដូចជា តាភូម, តាឡាច, ណារ៉ែន, តាកុក តាប្រង់ និង នារីសារី រួមទាំងប្រជាជននៅក្នុងភូមិមួយចំនួនទៀត ត្រូវកម្មាភិបាលមកពីនិរតីចាប់សម្លាប់នៅចម្ការក្រូចស្រុកស្អួលពីបទរួមគំនិតក្បត់ជាមួយ សោភឹម ប្រធានភូមិភាគបូព៌ា ។

ឆ្នាំ១៩៧៨ ប្រជាជនទាំងអស់នៅឃុំតាម៉ៅត្រូវជម្លៀសទៅខេត្តក្រចេះនិងខេត្តកំពង់ធំ ដើម្បីបញ្ចៀសឲ្យផុតពីការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាម ។ នៅពេលប្រជាជនក្នុងឃុំជាំតាម៉ៅក៏ដូចជាប្រជាជនដែលរស់នៅតាមបណ្ដោយព្រំដែនវៀតណាមដែរ ត្រូវបានជម្លៀសនិងក្លាយជាជនសង្ស័យចូលដៃដើងជាមួយវៀតណាមទើបបណ្ដាលឲ្យវៀតណាមវាយចូលក្នុងទឹកដីខ្មែរបាន ។ កម្មាភិបាលភូមិឃុំជាច្រើននាក់ត្រូវចាប់បញ្ចូលក្នុងឡានយកទៅសម្លាប់នៅចម្ការក្រូចស្ថិតក្នុងស្រុកស្អួល ខេត្តក្រចេះ ។ ចំណែកឯប្រជាជនត្រូវបង្ខំឲ្យធ្វើការហួសកម្លាំងនិងមិនឲ្យចំណីអាហារហូបគ្រប់គ្រាន់បានធ្វើឲ្យប្រជាជនរាប់ម៉ឺននាក់បាត់បង់ជីវិត ។ ក្រោយឆ្នាំ១៩៧៩ ជនជាតិស្មៀង បានវិលត្រលប់មករស់នៅក្នុងឃុំនេះវិញ ក្រៅពីនោះត្រូវបាត់បង់ជីវិតនៅក្នុងខេត្តក្រចេះនិងកំពង់ធំ ។ ឯភាសាទំនៀមទម្លាប់ប្រពៃរបស់អ្នកភូមិស្ទើរតែបាត់បង់ទាំងស្រុង ។ នេះជាមូលហេតុបណ្ដាលឲ្យក្មេងៗជាតិស្មៀងជំនាន់ក្រោយពុំបានដឹងពីប្រវត្តិកំណើតប្រពៃណីនិងភាសារបស់ជនជាតិខ្លួនច្បាស់លាស់ ។ បច្ចុប្បន្នក្មេងៗទាំងនោះពុំព្រមរៀននិងនិយាយភាសាស្មៀង សូម្បីតែនៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ។ ជនជាតិស្មៀងក្មេងៗមិនចង់ឲ្យជនជាតិខ្មែរដឹងថាខ្លួនជាជនជាតិភាគតិចស្មៀងទេពីព្រោះក្មេងៗទាំងនោះមានការអៀនខ្មាសនិងភ័យខ្លាចមានការរើសអើងចំពោះខ្លួន ។ **អែម សុឃីម**

## *លិខិតពីមិត្តអ្នកអាន*

### *សូមគោរពលោកនាយកមជ្ឈមណ្ឌលឯកសារស្វែងរកការពិតពីចម្ងាយ!*

*ខ្ញុំបាទមានកិត្តិយសសូមប្រកាសជូនដំណឹងអំពីការស្រាវជ្រាវរកជនរងគ្រោះ!*

*នៅសម័យខ្មែរក្រហម ខ្ញុំរស់នៅភូមិតាឥន្ទ (បច្ចុប្បន្នហៅភូមិត្រពាំងវែងខាងលិច) ឃុំត្រពាំងរាំង ស្រុកជុំគិរី ខេត្តកំពត ។ កាលនោះខ្ញុំនៅកុមារតូចនៅឡើយ ។ ថ្ងៃមួយខ្ញុំបានជួបបុរសម្នាក់មាឌក្រអាញសាច់ដុំធំៗ សម្បុរស្រអែម គាត់ឈ្មោះ ឡុង អាន ជាអ្នកប្រដាល់កាលពីសង្គមចាស់ ។ ពេលខ្ញុំបានជួបនិងឃើញគាត់ អ្នកស្រុកខ្ញុំបានសុំឲ្យគាត់សាកបញ្ចេញក្បាច់ប្រដាល់មើល គាត់ក៏បានធ្វើឲ្យមើលដូចជាក្បាច់ចាប់ទាត់ធាក់យ៉ាងស្ទាត់ជំនាញគួរឲ្យចង់មើលនិងស្ងើចសរសើរពីវិជ្ជារបស់គាត់ ។ គាត់ជាប្រជាជនថ្មីមិនដឹងគាត់ជម្លៀសមកពីភូមិឃុំស្រុកខេត្តណាទេ មកនៅភូមិតារាជដែលជាប់នឹងភូមិរបស់ខ្ញុំ ។ ក្រោយមកខ្ញុំបានសាកសួររកឈ្មោះគាត់ អ្នកភូមិបានប្រាប់ខ្ញុំថា គាត់ត្រូវគេយកទៅសម្លាប់បាត់ហើយ តែខ្ញុំមិនបានសួរថាតើគេយកគាត់ទៅសម្លាប់នៅកន្លែងណាទេ ។ រហូតមកដល់ពេលនេះ ខ្ញុំនៅតែនឹកឃើញគាត់និងសែនស្រណោះអំពីជីវិតរបស់គាត់ក៏ដូចបងប្អូនពូមីងខ្ញុំនិងជនរួមជាតិដែលទទួលរងគ្រោះត្រូវឈ្លបសម្លាប់ដូចសត្វធាតុ ។*

*ព័ត៌មានដែលខ្ញុំបានដឹងខាងលើចាត់ទុកជាការជូនដំណឹងដល់បងប្អូន សាច់ញាតិ ឪពុកម្ដាយរបស់គាត់បានជ្រាបនឹងដឹងព្រួងៗតែប៉ុណ្ណោះ ។ ប្រសិនបើបងប្អូនមិនទាន់បានដំណឹងនេះ ហើយចង់ដឹងព័ត៌មានលម្អិតសូមអញ្ជើញទៅជួបអ្នកភូមិខាងលើប្រហែលនឹងបានដំណឹងបន្ថែមទៀតជាពុំខាន ។*

*សូមអរគុណក្នុងការចុះផ្សាយនូវដំណឹងនេះទុកជាប្រយោជន៍ដល់គ្រួសារទៅតាមផ្លូវធម៌ ឬជាប្រវត្តិសាស្ត្រផងដែរ ។*

**គុងវ៉ា**

00160754

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

C22/I/10

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 05 / Feb / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)**

# សេចក្តីជូនដំណឹង

អង្គបុរេជំនុំជម្រះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា “**អវតក**” បានទទួលសារណារបស់មេធាវីការពារក្តីជនត្រូវចោទ **អៀង សារី** នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៨ ដើម្បីគាំទ្របណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ សារណានេះបានផ្សព្វផ្សាយនៅក្នុងគេហទំព័ររបស់ អ.វ.ត.ក រួចហើយ។ អនុលោមតាមវិធាន ៣៣ នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា អង្គបុរេជំនុំជម្រះសូមជូនដំណឹងដល់អង្គការនានា និងសាធារណជនដើម្បីធ្វើសារណាជាលាយលក្ខណ៍អក្សរ ដែលពាក់ព័ន្ធនឹងបញ្ហាណាមួយក្នុងករណីខាងលើមិនឲ្យលើស ១៥ ទំព័រ រួមទាំងសេចក្តីសង្ខេប។ សារណានេះត្រូវដាក់មកការិយាល័យក្រឡាបញ្ជីអង្គបុរេជំនុំជម្រះ ឬតាមអាសយដ្ឋានអេឡិចត្រូនិច ptc@eccc.gov.kh ក្នុងរយៈពេល១៥ថ្ងៃ គិតពីថ្ងៃជូនដំណឹងនេះតទៅ។ អ្នកដាក់សារណាទាំងអស់ ត្រូវផ្តល់ព័ត៌មានលម្អិតរបស់ខ្លួន ដូចជា ឈ្មោះ អាសយដ្ឋាន លេខទូរស័ព្ទ និងអាសយដ្ឋានអេឡិចត្រូនិច។

អង្គបុរេជំនុំជម្រះ សូមស្នើអង្គការ និង សាធារណជន ដាក់សារណារបស់ខ្លួនមកជាពីរភាសា គឺភាសាខ្មែរ និង ភាសាផ្លូវការមួយទៀតរបស់ អ.វ.ត.ក (អង់គ្លេស ឬ បារាំង) បើអាចធ្វើបាន ។

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 05 / 02 / 2008
ម៉ោង (Time/Heure): 8h40 AM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kosal

ភ្នំពេញ , ថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០០៨

ប្រធានអង្គបុរេជំនុំជម្រះ

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE
E.C.C.C. * C.E.T.C.

ប្រាក់ គីមសាន

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# ក្រមសីលធម៌ចៅក្រម

**បុព្វកថា**

ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**បានឃើញ**កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និង រាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់ក្តីក្រោមច្បាប់កម្ពុជាចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តិឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣។

បានឃើញច្បាប់ និង ខ្លឹមសារវិសោធនកម្មច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានប្រកាសឱ្យប្រើជាផ្លូវការកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

**បានឃើញ**ក្រមសីលធម៌ចៅក្រមកម្ពុជា ដែលបានអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកាលពីថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០០៧។

**បានឃើញ**គោលការណ៍ជាមូលដ្ឋាន របស់អង្គការសហប្រជាជាតិ ស្តីពីឯករាជ្យភាពរបស់តុលាការ ឆ្នាំ ១៩៨៥។

**ដោយពិចារណាលើ**លក្ខណៈពិសេសនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង តម្រូវការក្នុងការអនុម័តនូវក្រមសីលធម៌ ដែលចៅក្រមជាតិ និង អន្តរជាតិត្រូវអនុវត្តតាម និង ដោយបញ្ចូលនូវនិយាមជាតិ និង អន្តរជាតិ។

**បានព្រមព្រៀងគ្នា**ដូចខាងក្រោម៖

**មាត្រា ១**

**គោលការណ៍ឯករាជ្យភាពរបស់តុលាការ**

១. ចៅក្រមត្រូវរក្សានូវឯករាជ្យភាពក្នុងការបំពេញភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួនក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា អ.វ.ត.ក) ហើយត្រូវប្រតិបត្តិតាមសិទ្ធិអំណាច និង ឯករាជ្យភាពក្នុងការបំពេញមុខនាទីរបស់ខ្លួន។

1

២. ចៅក្រមមិនត្រូវធ្វើសកម្មភាពណាមួយ ដែលនឹងអាចជ្រៀតជ្រែកចូលក្នុងការបំពេញភារកិច្ចរបស់ខ្លួន ឬ ធ្វើអោយប៉ះពាល់លើឯករាជ្យភាពរបស់ខ្លួន។

**មាត្រា ២**

**គោលការណ៍អនាគតិ**

១. ចៅក្រមត្រូវមានភាពមិនលំអៀង និង ត្រូវធានាពីការសំដែងអោយឃើញអ្វីមួយមិនលំអៀងក្នុងការបំពេញភារកិច្ចរបស់ខ្លួន។

២. ចៅក្រមត្រូវចៀសវាងនូវរាល់ជម្លោះផលប្រយោជន៍ ឬ ស្ថិតក្នុងស្ថានភាពណាមួយដែលគេអាចយល់ឃើញថាមានជម្លោះផលប្រយោជន៍កើតឡើង។

**មាត្រា ៣**

**គោលការណ៍សុចរិតភាព**

១. ចៅក្រមត្រូវប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរ និង ដោយសេចក្តីសុចរិតទៀងត្រង់ ស្របតាមមុខនាទីរបស់ខ្លួន ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីសាធារណជនលើតុលាការ។

២. ចៅក្រមមិនត្រូវទទួលយកទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី នូវអំណោយ អត្ថប្រយោជន៍ បុព្វសិទ្ធិ ឬ រង្វាន់ ដែលគេអាចយល់បានថាកំពុងតែមានចេតនាជះឥទ្ធិពល លើការបំពេញមុខនាទីរបស់ខ្លួន។

**មាត្រា ៤**

**គោលការណ៍ភាពសម្ងាត់**

ចៅក្រមត្រូវគោរពនូវសារសំខាន់នៃការរក្សាភាពសម្ងាត់ ចំពោះពត៏មានដែលទទួលបានក្នុងការបំពេញមុខនាទីរបស់ខ្លួន និង ភាពសម្ងាត់នៃការពិភាក្សាសម្រេច។

**មាត្រា ៥**

**គោលការណ៍វីរយភាព**

១. ចៅក្រមត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួន ដោយវីរយភាព និង ប្រើសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន ដើម្បីបំពេញភារកិច្ចទាំងនោះ។

២. ចៅក្រមត្រូវចាត់វិធានការសមស្របដើម្បីរក្សា និង លើកកម្ពស់ចំណេះដឹង ជំនាញ និង សមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់សម្រាប់បំពេញភារកិច្ចរបស់ខ្លួនលើវិស័យតុលាការ។

៣. ចៅក្រមត្រូវបំពេញគ្រប់តួនាទីភារកិច្ចតុលាការឱ្យបានត្រឹមត្រូវ និង ឆាប់រហ័ស។

៤. ចៅក្រមត្រូវចេញសេចក្ដីសម្រេចរបស់ខ្លួន ដោយគ្មានការពន្យាពេល ដែលមិនសមរម្យ។

## មាត្រា ៦

### អាកប្បកិរិយាក្នុងដំណើរការក្ដី

១. នៅក្នុងកិច្ចដឹកនាំដំណើរការក្ដី ចៅក្រមត្រូវរក្សានូវសណ្ដាប់ធ្នាប់ របៀបរៀបរយ រៀបចំ អាកប្បកិរិយាគួរជាទីគោរព រក្សាភាពអត់ធ្មត់ និង ការគួរសមចំពោះអ្នកចូលរួមទាំងអស់ ក៏ដូចជា សាធារណជនដែលមានវត្តមាន ហើយត្រូវតម្រូវឱ្យអ្នកទាំងនោះអនុវត្តដូចគ្នាដែរ។

២. ចៅក្រមត្រូវយកចិត្តទុកដាក់ ក្នុងការគ្រប់គ្រងលើឥរិយាបទក្នុងការសួរសំណួរលើសាក្សី ឬ ជនរងគ្រោះ និង ផ្ដល់ការយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិរបស់អ្នកចូលរួម ក្នុងដំណើរការនីតិវិធី នូវភាពស្មើគ្នា ក្នុងការការពារ និង អត្ថប្រយោជន៍តាមផ្លូវច្បាប់។

៣. ចៅក្រមត្រូវចៀសវាងនូវអាកប្បកិរិយា ឬ ការអត្ថាធិប្បាយណាមួយ ដែលមានភាពរើស អើងពូជសាសន៍ ភេទ ឬ បន្ទាបបន្ថោក និង តាមមធ្យោបាយដែលអាចធ្វើទៅបាន ចៅក្រមត្រូវធ្វើយ៉ាង ណាឲ្យអ្នកចូលរួមក្នុងដំណើរការក្ដី ចៀសវាងពីការផ្ដល់នូវយោបល់ ឬ ប្រព្រឹត្តិអំពើបែបនោះ។

## មាត្រា ៧

### គោលការណ៍សម្ដែងមតិជាសាធារណៈ និងសហគមន៍

១. ចៅក្រមត្រូវអនុវត្តសិទ្ធិក្នុងការបញ្ចេញមតិ និង សហគមន៍ណាដែលសមស្របជាមួយនឹង មុខនាទីនៃការិយាល័យរបស់ខ្លួន ហើយដែលមិនជះឥទ្ធិពល ឬ ទំនងជាអាចជះឥទ្ធិពលដល់ ឯករាជ្យភាព និង ភាពមិនលំអៀងរបស់តុលាការ។

២. ទោះបីចៅក្រមអាចចូលរួមដោយសេរីក្នុងការពិភាក្សាវែកញែក ជាសាធារណៈលើបញ្ហាទាំង ឡាយទាក់ទងនឹងបញ្ហាច្បាប់ តុលាការ ឬ រដ្ឋបាលតុលាការ ចៅក្រមមិនត្រូវអត្ថាធិប្បាយណាមួយទាក់ ទងនឹងសំណុំរឿងដែលកំពុងចាត់ការ ហើយចៅក្រមត្រូវចៀសវាងការបញ្ចេញទស្សនៈទាំងឡាយណា ដែលអាចធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះ និង សុចរិតភាពរបស់អ.វ.ត.ក។

3

**មាត្រា ៨**

**គោលការណ៍សកម្មភាពក្រៅកិច្ចការតុលាការ**

១. ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពក្រៅកិច្ចការតុលាការណាមួយ ដែលមានវិសមភាពទៅនឹងមុខងារតុលាការរបស់ខ្លួន ឬ ដំណើរការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និង ទាន់ពេលវេលារបស់អ.វ.ត.ក ឬ ដែលអាចជះឥទ្ធិពល ឬ ទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និង ភាពមិនលំអៀងរបស់ខ្លួន។

២. ចៅក្រមមិនត្រូវកាន់តួនាទីនយោបាយឡើយ។

**មាត្រា ៩**

**ការអនុវត្តក្រម**

១. គោលការណ៍ទាំងឡាយដែលមានចែងក្នុងក្រមនេះ ត្រូវចាត់ទុកជាសេចក្តីណែនាំស្តីពីបទដ្ឋានសីលធម៌ជាសារវ័ន្ត ដែលចៅក្រមត្រូវប្រកាន់ខ្ជាប់ក្នុងការបំពេញតួនាទី និង ភារកិច្ចរបស់ខ្លួន។

២. មិនមានអ្វីមួយដែលមាននៅក្នុងខ្លឹមសារនៃក្រមនេះ មានបំណងសំដៅកំណត់ ឬ ដាក់កំហិតតាមមធ្យោបាយណាមួយ ទៅលើឯករាជ្យភាពរបស់ចៅក្រមឡើយ ។

**អនុម័តដោយកិច្ចប្រជុំពេញអង្គចៅក្រមនៃ អ.វ.ត.ក នៅថ្ងៃទី៣១ ខែមករា ឆ្នាំ ២០០៨**

4

00162549

CM/36

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គបុរេជំនុំជម្រះ**
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

**សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-ករសចស (អបជ០១)**

**អង្គបុរេជំនុំជម្រះ**

**ចំពោះមុខ:** ចៅក្រម ប្រាក់ គឹមសាន, ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម ន៉ី ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

**កាលបរិច្ឆេទ:** ១២ កុម្ភៈ ២០០៨

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 12 / FEB / 2008
ម៉ោង (Time/Heure): 16:00'
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNVICHET

---

# សេចក្ដីជូនដំណឹងស្ដីពីការដាក់សារណាអំពីការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន និងការអញ្ជើញអ្នកដែលមិនមែនជាភាគី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 12 / FEB / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: NUP SOTHUNVICHET

---

**សហព្រះរាជអាជ្ញា**
ជា លាង
Robert PETIT

**ជនត្រូវចោទ**
នួន ជា

**មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី**
លោក ហុង គឹមសួន
លោក ឡោ ជុនធី
លោក នី ចាន់ឌី

**មេធាវីការពារក្ដី**
សុន អរុណ
Michiel PESTMAN
Victor KOPPE

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00162550

C11/36

១- កាលពីថ្ងៃទី៧-៨ ខែកុម្ភៈ ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានបើកសវនាការមួយលើបណ្តឹងឧទ្ធរណ៍របស់សហមេធាវីនៃជនត្រូវចោទ នួន ជា ដែលបានប្តឹងជំទាស់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត។

២- នៅថ្ងៃសវនាការ សហចៅក្រមស៊ើបអង្កេតបានពិនិត្យមើលលើពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួន ហើយជាលទ្ធផលភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងបួននេះក៏បានចូលរួមក្នុងសវនាការក្នុង សំណុំរឿងលេខ ០០២/១៩-០៩-០៧-អវតក/កសចស។ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះ បានទទួលបានសេចក្តីជូនដំណឹងអំពីការតែងតាំងមេធាវីសម្រាប់ភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ និងអំពីគោលបំណងរបស់ពួកគាត់ក្នុងការបង្ហាញខ្លួននៅចំពោះមុខអង្គសវនាការ (កាលពីដំបូងគ្រោងធ្វើឡើង នៅថ្ងៃទី៤ ខែកុម្ភៈ)។ មុនថ្ងៃសវនាការ មានការចេញសេចក្តីជូនដំណឹងអំពីវត្តមានរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីរបស់ពួកគាត់ក្នុងសវនាការ និងជូនដំណឹងផងដែរអំពីពេលវេលាកំណត់សម្រាប់ការ ដាក់សារណានៃភាគីដើមបណ្តឹងរដ្ឋប្បវេណី។

៣- នៅក្នុងសវនាការ សហមេធាវីបានជំទាស់ថា ការអនុញ្ញាតឲ្យភាគីដើមបណ្តឹងរដ្ឋប្បវេណីចូលរួមក្នុងកិច្ចដំណើរការនីតិវិធីនេះ វានឹងរំលោភលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៃជនត្រូវចោទ។ តាមសម្តីរបស់សហមេធាវី ការបញ្ចេញទស្សនៈ និងកង្វល់របស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីត្រូវតែធ្វើឡើងតាមមធ្យោបាយណាមួយដែលមិនខូចប្រយោជន៍ដល់ជនត្រូវចោទ។ មានការលើកឡើងថា ភាគីដើមបណ្តឹងរដ្ឋប្បវេណីមិនបានដាក់សារណាជាលាយលក្ខណ៍អក្សរ និងមិនបានជម្រាបដល់ភាគីដទៃទៀត ឬដល់អង្គបុរេជំនុំជម្រះឱ្យបានជ្រាបជាមុននូវការចាប់អារម្មណ៍របស់ខ្លួនឡើយ។ លើសពីនេះទៅទៀត សហ-មេធាវីជំទាស់ថា វិធាន២៣ នៃវិធានផ្ទៃក្នុងមិនបានចែងអំពីការចូលរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីដែលពាក់ព័ន្ធនឹងបណ្តឹងឧទ្ធរណ៍លើដីកាឃុំខ្លួនទេ។ ពួកគាត់ចង្អុល យោងទៅសាលក្រមនៃអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (“ICC”) ចុះថ្ងៃទី១៣ ខែកុម្ភៈ ២០០៧ (លេខ ០១/០៤-០១/០៦ (OA7) ក្នុងករណីរបស់ព្រះរាជអាជ្ញា តទល់នឹង *Thomas Lubanga Dyilo*។

៤-ដោយឈរលើមូលដ្ឋាននៃសារណារបស់ភាគី និងគោលបំណងជាឯកច្ឆន្ទក្នុងការបន្តដំណើរការសវនាការទៅមុខទៀត អង្គបុរេជំនុំជម្រះបានសម្រេចរក្សាទុកនូវសិទ្ធិនៃមេធាវីការពារក្តី និងចេញនូវសេចក្តីសម្រេច មួយលើបញ្ហាដើមបណ្តឹងរដ្ឋប្បវេណីនៅមុនការចេញសេចក្តីសម្រេចរបស់ខ្លួនចំពោះបណ្តឹង

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទៈ (៨៥៥)-២៣-២១៩-៨១៤ ទូរសារៈ (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រៈ www.eccc.gov.kh

00162551

C11/36

ឧទ្ធរណ៍លើការ ឃុំខ្លួនបណ្តោះអាសន្ន។ សវនាការបានបន្តធ្វើទៅទៀត ដោយផ្អែកលើមូលដ្ឋានមួយគឺសារណារបស់ភាគី និង/ឬ របស់មេធាវីពួកគាត់អាចទទួលយកបាន ឬបដិសេធ នៅមុនការសម្រេចអំពីបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន។ ចំណុចនេះវាអាស្រ័យទៅលើលទ្ធផលនៃការសម្រេចរបស់អង្គបុរេជំនុំជម្រះ លើបញ្ហានៃគោលការណ៍។

៥- បញ្ហានេះបានលេចឡើងក្នុងបណ្តឹងឧទ្ធរណ៍របស់ នួន ជា ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ វាអាចជះឥទ្ធិពលដល់ជំហរ ឬការខូតខាតផលប្រយោជន៍របស់ជនត្រូវចោទក្នុងបណ្តឹងឧទ្ធរណ៍ក្រោយៗ ទៀត ដែលពាក់ព័ន្ធនឹងការឃុំខ្លួនបណ្តោះអាសន្ន ដែលកំពុងមាននៅចំពោះមុខអង្គបុរេជំនុំជម្រះ។ ដូច្នេះ អង្គបុរេជំនុំជម្រះសូមភ្ជាប់រឿងនេះទៅនឹងបណ្តឹងឧទ្ធរណ៍ផ្សេងៗទៀតដែលកំពុងរង់ចាំ និងសូមអញ្ជើញ សហមេធាវីរបស់ជនត្រូវចោទដទៃទៀតដាក់សារណា។

៦- បន្ថែមលើនេះ ដោយបានពិចារណាលើលក្ខណៈជាមូលដ្ឋាននៃបញ្ហានេះ អង្គបុរេជំនុំជម្រះយល់ឃើញថាការដាក់សារណាពីសំណាក់សាធារណៈជន (*amici curiae*) គឺពិតជាមានសារសំខាន់។ អង្គបុរេជំនុំជម្រះសូមស្វាគមន៍សារណាដែលមានលក្ខណៈជាក់លាក់ពីសាធារណៈជន ពោលគឺផ្តោតសំខាន់ទៅលើបញ្ហានៃតុល្យភាពគ្នារវាងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌នៃជនត្រូវចោទ និងសិទ្ធិរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងបរិបទវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា។

<u>អាស្រ័យហេតុនេះ អង្គបុរេជំនុំជម្រះសូមធ្វើការបង្គាប់ដូចខាងក្រោម:</u>

១. សហមេធាវីក្នុងសំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០១), ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០២), ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៣) និង ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ០៤) អាចដាក់សារណាជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធទៅនឹងបញ្ហាដូចដែលបានលើកឡើងខាងលើឱ្យបាន មុនម៉ោង ១៥:៣០ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨។
២. សហព្រះរាជអាជ្ញាអាចដាក់សារណាជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធទៅនឹងបញ្ហាដូចដែលបានលើកឡើងខាងលើឱ្យបានមុនម៉ោង ១៥:៣០ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨។
៣. ភាគីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿ ០០២/១៩-០៩-២០០៧-អវតក/កសចស អាចដាក់សារណាជាលាយលក្ខណ៍អក្សរដែលពាក់ព័ន្ធទៅនឹងបញ្ហាដូចដែលបានលើកឡើងខាងលើឱ្យបានមុនម៉ោង ១៥:៣០ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨។

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៩-៨១៤ ទូរសារ: (៨៥៥)-២៣-២១៩-៨៤១ គេហទំព័រ: www.eccc.gov.kh

00162552

C11/36

៤. យើងនឹងទទួលសារណារបស់សាធារណៈជនរហូតដល់ម៉ោង ១៥:៣០ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៨។

៥. ភាគីទាំងឡាយអាចឆ្លើយតបទៅនឹងសារណារបស់ភាគីដទៃទៀត ឬតបនឹងសារណារបស់សាធារណៈជនណាមួយក៏បាននៅមុនម៉ោង ១៥:៣០ នាថ្ងៃទី០៦ ខែមិនា ឆ្នាំ២០០៨។

៦. សារណាមិនត្រូវឱ្យលើសពី ១០ ទំព័រជាភាសាអង់គ្លេស និងបារាំង និងមិនត្រូវលើស ១៥ ទំព័រជាភាសាខ្មែរ។

៧. បើអាចមានលទ្ធភាពធ្វើបាន ភាគីទាំងអស់ និងសាធារណៈជនផង ត្រូវដាក់សារណារបស់ខ្លួនជាភាសាខ្មែរ អង់គ្លេស និងបារាំង។

ភ្នំពេញ ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ២០០៨

ប្រធានអង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER CHAMBRE PRELIMINAIRE E.C.C.C. * C.E.T.C.

ប្រាក់ គឹមសាន

ផ្លូវជាតិលេខ ៤ សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ ក្រុងភ្នំពេញ កម្ពុជា ប្រអប់សំបុត្រ ៧១
ទូរស័ព្ទ: (៨៥៥)-២៣-២១៨-៩១៤ ទូរសារ: (៨៥៥)-២៣-២១៨-៩៤១ គេហទំព័រ: www.eccc.gov.kh

# គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា

## សេចក្តីប្រកាសព័ត៌មាន

### ក្រុមជនរងគ្រោះលើកដំបូងចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការ នួន ជា

*នៅក្នុងសវនាការជំនុំជម្រះដោយអង្គបុរេជំនុំជម្រះលើករណីបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ នួន ជា មានក្រុមជនរងគ្រោះដោយសាររបបខ្មែរក្រហម ដែលគាំទ្រដោយសមាជិកគណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជាអាចចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាលើកដំបូង ។ នេះគឺជាសញ្ញាដ៏សំខាន់មួយសម្រាប់ជនរងគ្រោះទាំងអស់ និងក៏ជាជំហានវិវត្តជាប្រវត្តិសាស្ត្រនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិផងដែរ ។*

*វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចែងធានាអំពីការចូលរួមរបស់ជនរងគ្រោះដោយអនុញ្ញាតឲ្យគេចូលរួមជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី ។ តាមរយៈយន្តការច្បាប់នេះ ជនរងគ្រោះអាចចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនីតិវិធី និងអាចទាមទារសំណងចំពោះព្យសនកម្មដែលគេបានទទួលរងគ្រោះ ។ ក្នុងរយៈពេលប៉ុន្មានខែកន្លងមក សមាជិកគណៈកម្មាធិការប្រព្រឹត្តិកម្មមួយចំនួនដូចជាៈ សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC) មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) និងវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ (KID) បានជួយជនរងគ្រោះដោយសាររបបខ្មែរក្រហមជាច្រើននាក់ក្នុងការដាក់ពាក្យបណ្តឹងទៅកាន់អង្គជំនុំជម្រះវិសាមញ្ញ ។ ជនរងគ្រោះភាគច្រើនក្នុងចំណោមជនរងគ្រោះដែលបានដាក់ពាក្យបណ្តឹងទាំងនេះបានបង្ហាញពីចំណាប់អារម្មណ៍ចង់ចូលរួមដោយផ្ទាល់ជាភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី ។*

*ដើម្បីសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងនេះ អង្គការ-សមាគមសមាជិកទាំងនេះបានព្រមព្រៀងគ្នាបង្កើតនូវយន្តការសម្របសម្រួលមួយនៅក្នុងលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រព្រឹត្តិកម្ម ។ ជាងនេះទៅទៀត ដោយសារមានការជួយគាំទ្រផ្នែកហិរញ្ញវត្ថុពីសេវកម្មអភិវឌ្ឍន៍អាឡឺម៉ង់(DED)គណៈកម្មាធិការប្រព្រឹត្តិកម្មអាចជួយផ្តល់តំណាងផ្លូវច្បាប់ដ៏មានកម្រិតទៅដល់ភាគីដើមបណ្តឹងរដ្ឋប្បវេណីដែលបានទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញផងដែរ គឺតាមរយៈអង្គការជំនួយផ្នែកច្បាប់ជាសមាជិកចំនួនពីរគឺអង្គការក្រុមអ្នកច្បាប់ការពារសិទ្ធិកម្ពុជា (CDP) និងអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជា (LAC) ។ ដូច្នេះ តាមរយៈការរួមកម្លាំងគ្នានេះ អង្គការសង្គមស៊ីវិលទាំងនេះអាចចូលរួមចំណែកជួយដល់ការចូលរួមរបស់ជនរងគ្រោះឲ្យកាន់តែសកម្មថែមទៀត ។*

*នៅអំឡុងពាក់កណ្តាលខែមករា ឆ្នាំ២០០៨ កន្លងមក ការិយាល័យសហចៅក្រមស៊ើបអង្កេតបានសម្រេចទទួលស្គាល់ជាវិជ្ជមាននូវពាក្យសុំតាំងខ្លួនជាភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤ ដែលបានដាក់ជូនដោយសមាគមអាដហុកនិងមជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គមសម្រាប់ចូលរួមនៅក្នុងរឿងក្តី នួន ជា ។ ក្រុមមេធាវីខ្មែរការពារភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤ក្រុម ដែលមកពីអង្គការ CDP និង LAC ត្រូវបានតែងតាំងភ្លាមៗក្រោយពីការជូនដំណឹងនេះ ដោយមានការពិភាក្សាពិគ្រោះយោបល់ជាមួយអង្គភាពជនរងគ្រោះរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាផងដែរក្នុងនោះរួមមានៈ លោកមេធាវី ហុង គឹមសួន លោកមេធាវី យង់ ផានិត លោកមេធាវី ឡោ ជុនធី និងលោកមេធាវី នី ចាន់ឌី ។*

*ទោះបីជាការជូនដំណឹងនេះធ្វើឡើងក្នុងរយៈពេលដ៏ខ្លី ក៏វិធានការដ៏មានប្រសិទ្ធភាពរបស់សមាជិកគណៈកម្មាធិការប្រព្រឹត្តិកម្មអាចឲ្យជនរងគ្រោះដោយសារអំពើដ៏សាហាវយង់ឃ្នងចូលរួមនៅក្នុងដំណើរការនីតិវិធីជាមួយនឹងមេធាវីតំណាងដ៏មានគុណភាពផងដែរ ។ ដូចនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម មានសុទិដ្ឋិនិយមផងដែរថា នឹងមានជនរងគ្រោះជាច្រើនផ្សេងទៀតនឹងដាក់ពាក្យបណ្តឹងប្តឹងតាំងខ្លួនភាគីដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ ។ ជនរងគ្រោះដែលចាប់អារម្មណ៍ក៏អាចទៅរកអង្គការសមាគមដែលមានឈ្មោះខាងលើនេះ ដើម្បីអាចទទួលបានព័ត៌មានបន្ថែមទៀតទាក់ទិននឹងបញ្ហានេះផងដែរ ។ ភ្នំពេញ ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ ២០០៨*

*សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងៈ លោក ធន សារាយ ប្រធានសម្របសម្រួល CHRAC/ប្រធានសមាគមអាដហុក លេខៈ ០១៦ ៨៨០ ៥០៩ ◆ លោក សុក សំអឿន នាយកប្រតិបត្តិ CDP លេខៈ ០១២ ៩០១ ១៩៩ ◆ លោកស្រី ពីង យក់ហៀប នាយិកា ប្រតិបត្តិ LAC លេខៈ ០១២ ៨២៣ ៧៤៥*

# ជនរងគ្រោះនៅតែចាំរង់ចាំចម្លើយពីអង្គជំនុំជម្រះវិសាមញ្ញៈ ចម្លើយនឹងត្រូវផ្តល់ជូន

## ការចូលរួមរបស់ជនរងគ្រោះ និងសកម្មភាពរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដែលត្រូវគេស្គាល់ជាទូទៅថាជាសាលាជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម បានផ្តល់ឱកាសឲ្យជនរងគ្រោះអាចចូលរួមនៅក្នុងសវនាការមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបនោះ ។ យោងទៅតាមសេចក្តីណែនាំអនុវត្តមួយរបស់អង្គជំនុំជម្រះវិសាមញ្ញ អ្នករួចរស់ជីវិតពីរបបខ្មែរក្រហមអាចចូលរួមនៅក្នុងសវនាការតាមវិធីបីយ៉ាងៈ ១) ដោយស្ម័គ្រចិត្តធ្វើជាសាក្សី តាមរយៈការផ្តល់សក្ខីភាពអំពីឧក្រិដ្ឋកម្មដែលទទួលរង ឬដែលបានមើលឃើញនៅពេលនោះ ២) ដោយដាក់ពាក្យបណ្តឹង តាមរយៈការផ្តល់ព័ត៌មានទៅឲ្យសហព្រះរាជអាជ្ញា និង៣) ដោយដាក់ពាក្យបណ្តឹងសុំធ្វើជាដើមបណ្តឹងរដ្ឋប្បវេណី តាមរយៈការដាក់ពាក្យបណ្តឹងសុំធ្វើជាភាគីមួយចូលរួមនៅក្នុងសវនាការ និងសុំទាមទារសំណងផ្លូវចិត្ត និងសមូហភាព ។ អង្គជំនុំជម្រះវិសាមញ្ញបានបង្កើតនូវទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះសម្រាប់ឲ្យអ្នករួចរស់ជីវិតពីរបបខ្មែរក្រហមទាំងឡាយដែលចាប់អារម្មណ៍ចង់ចូលរួមដើម្បីបំពេញនិងដាក់ជូនទៅកាន់អង្គភាពជនរងគ្រោះ ។

ចាប់តាំងពីខែតុលា ឆ្នាំ២០០៧មក មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតគម្រោងចូលរួមរបស់ជនរងគ្រោះ ដើម្បីជួយផ្តល់ជាព័ត៌មានដល់អ្នករួចរស់ជីវិតទាំងនោះអំពីសិទ្ធិក្នុងការចូលរួមរបស់ពួកគាត់ ហើយក្នុងករណីដែលពួកគាត់មានបំណងចង់ចូលរួមគម្រោងនេះនឹងផ្តល់ទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ និងជួយពួកគាត់ក្នុងការបំពេញទម្រង់នេះ ។ បើទោះបីជាសកម្មភាពរបស់គម្រោងនេះនឹងចាប់ផ្តើមជាផ្លូវការនៅខែមីនា ឆ្នាំ២០០៨ក៏ដោយ ក៏មជ្ឈមណ្ឌលឯកសារកម្ពុជាកន្លងមកបានជួបជាមួយអ្នករួចរស់ជីវិតពីរបបខ្មែរក្រហមរាប់រយនាក់មកហើយដែរ ។ គិតត្រឹមថ្ងៃទី៥ ខែកុម្ភៈឆ្នាំ២០០៨ មជ្ឈមណ្ឌលឯកសារកម្ពុជាបានបញ្ជូនទៅកាន់អង្គភាពជនរងគ្រោះនូវទម្រង់បែបបទព័ត៌មានរបស់ជនរងគ្រោះចំនួន៥១៧ទម្រង់ដែលត្រូវបានបំពេញដោយអ្នករួចរស់ជីវិតពីរបបខ្មែរក្រហម ។ ជាពិសេស នៅខែតុលា ឆ្នាំ២០០៧ មជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានទម្រង់បែបបទជនរងគ្រោះជាច្រើនបំពេញដោយអ្នករួចរស់ជីវិតដែលបានចូលរួមនៅក្នុងសន្និសីទមួយស្តីអំពីការចូលរួមរបស់ជនគ្រោះ ។ ជនជាតិចាមមូស្លីមចំនួន២៨០នាក់មកពីទូទាំងប្រទេសកម្ពុជាបានចូលរួមនៅក្នុងសន្និសីទនោះ ។ បន្ទាប់ពីទទួលបានព័ត៌មានអំពីសិទ្ធិក្នុងការចូលរួមរបស់ពួកគាត់មក អ្នកចូលរួមសន្និសីទចំនួន២០០នាក់នោះ បានជ្រើសរើសបំពេញទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ដែលក្នុងនោះភាគច្រើនបានជ្រើសយកជម្រើសដាក់ពាក្យបណ្តឹងដើម្បីផ្តល់ជាព័ត៌មានដល់អង្គជំនុំជម្រះវិសាមញ្ញអំពីឧក្រិដ្ឋកម្មដែលពួកគាត់ទទួលរងគ្រោះ ឬបានឃើញកាលពីគាត់នៅក្រោមរបបខ្មែរក្រហម ។

## ការខកខានមិនបានឆ្លើយតបទៅអ្នកដាក់ពាក្យបណ្តឹងឲ្យបានទាន់ពេលវេលា និងភាពមិនសូវពេញចិត្ត

បើយោងទៅតាមវិធាន និងសេចក្តីណែនាំអនុវត្តមួយរបស់អង្គជំនុំជម្រះវិសាមញ្ញ សហព្រះរាជអាជ្ញាត្រូវតែឆ្លើយតបទៅកាន់អ្នករួចរស់ជីវិត ឬជនរងគ្រោះគ្រប់ៗរូបដែលបានដាក់ពាក្យបណ្តឹងនៅក្នុងរយៈពេល៦០ថ្ងៃគិតចាប់ពីថ្ងៃចុះបញ្ជីជាមួយអង្គជំនុំជម្រះវិសាមញ្ញ ។ នៅក្នុងលិខិតឆ្លើយតបទៅកាន់អ្នកដាក់ពាក្យបណ្តឹងទាំងនោះ សហព្រះរាជអាជ្ញាត្រូវតែបញ្ជាក់ពីសេចក្តីសម្រេចចិត្តថាតើព្រមទទួលយក ឬបដិសេធពាក្យបណ្តឹងរបស់ពួកគាត់ ។ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៨ ប្រមាណជា៤ខែបន្ទាប់ពីថ្ងៃរៀបចំសន្និសីទមក ស៊ូ ហ្វារីណា ដែលត្រូវជាអ្នកដឹកនាំគម្រោងប្រវត្តិសាស្ត្រផ្ទាល់មាត់ជនជាតិចាមមូស្លីមនៅមជ្ឈមណ្ឌលឯកសារកម្ពុជា

បានទាក់ទងទៅកាន់ប្រជាជនមួយចំនួនដែលបានចូលរួមនៅក្នុងសន្និសីទស្តីអំពីការចូលរួមរបស់ជនរងគ្រោះដើម្បីឲ្យដឹងថាតើអង្គភាពជនរងគ្រោះ ឬសហព្រះរាជអាជ្ញាបានជូនដំណឹងដល់ពួកគាត់អំពីស្ថានភាពនៃពាក្យបណ្តឹងរបស់ពួកគាត់ឬនៅ ។ ហ្វារីណា ទទួលព័ត៌មានថា ក្នុងចំណោមហាកឹមនិងទូនចំនួន៧រូបដែលបានទាក់ទងមិនមាននរណាម្នាក់ទទួលបានចម្លើយពីអង្គជំនុំជម្រះវិសាមញ្ញឡើយ ។ ក្នុងឋានៈជាអ្នកដឹកនាំសាសនានៅតាមខេត្ត ពួកគាត់ភាគច្រើនបានអះអាងថា នៅក្នុងខេត្តរបស់ពួកគាត់មិនមាននរណាម្នាក់ទទួលបានចម្លើយពីអង្គជំនុំជម្រះវិសាមញ្ញនៅឡើយទេ ។

ការខកខានរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការឆ្លើយតបទៅនឹងពាក្យបណ្តឹងទាំងនោះបានបង្កឲ្យមានការព្រួយបារម្ភជាខ្លាំង ។ ប្រសិនបើអ្នកដាក់ពាក្យបណ្តឹងទាំងនោះមិនទទួលបានការឆ្លើយតបទៅតាមរយៈពេលដែលបានសន្យា ពួកគេអាចបាត់បង់ចំណាប់អារម្មណ៍នៅក្នុងការចូលរួម ឬមិនសូវពេញចិត្តចំពោះដំណើរការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។ អ្នកដឹកនាំសាសនាម្នាក់មកពីខេត្តស្ទឹងត្រែងបានប្រាប់ ហ្វារីណា ថាគាត់ «មានអារម្មណ៍មិនសូវពេញចិត្តដោយសារតែមិនទាន់បានទទួលដំណឹងអ្វីសោះ» និងបានបញ្ជាក់ទៀតថាគាត់ «បានរង់ចាំអស់រយៈពេលយូរមកហើយ» ។ ជាងនេះទៅទៀត ប្រសិនបើពួកគាត់មិនទទួលបានចម្លើយ អ្នកដាក់ពាក្យបណ្តឹងដែលរស់នៅតាមទីជនបទដាច់ស្រយាលប្រហែលជាអាចដល់ទៅមានការសង្ស័យអំពីអត្ថិភាពរបស់អង្គជំនុំជម្រះវិសាមញ្ញនេះទៀតផង ។ជាក់ស្តែង ជំនួយការរបស់អ្នកដឹកនាំសាសនាអ៊ិស្លាមម្នាក់នៅក្នុងខេត្តសៀមរាបបានបញ្ជាក់ថា «ខ្ញុំចង់ដឹងថា តើពេលណាទើបសវនាការជំនុំជម្រះចាប់ដំណើរការ ។ ប្រសិនបើមានការឆ្លើយតបទៅនឹងពាក្យបណ្តឹងរបស់ពួកយើង យើងប្រហែលជាបានដឹងខ្លះៗអំពីស្ថានភាពពិតប្រាកដនៃដំណើរការជំនុំជម្រះ» ។ បន្ថែមលើនេះទៀត អ្នកដាក់ពាក្យបណ្តឹងអាចធ្វើការសន្និដ្ឋានថាអង្គជំនុំជម្រះមិនបានឲ្យតម្លៃចំពោះការចូលរួមចំណែកផ្តល់រឿងរ៉ាវរបស់ពួកគាត់ ។

## កិច្ចប្រឹងប្រែងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងការឆ្លើយតបទៅនឹងពាក្យបណ្តឹង និង ការសហការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

ជាការពិត អង្គភាពជនរងគ្រោះ សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេត ប្រឈមមុខនឹងកិច្ចការយ៉ាងធ្ងន់ធ្ងរក្នុងការពិនិត្យមើល និងឆ្លើយតបទៅនឹងពាក្យបណ្តឹងចំនួនជាង៩០០ ដែលត្រូវបានដាក់ជូនដោយអ្នករួចរស់ជីវិតនិងជនរងគ្រោះ ។ បើពិនិត្យមើលអំពីការដែលថា អង្គភាពជនរងគ្រោះទើបតែត្រូវបានបង្កើតឡើងនៅក្នុងរយៈពេលប៉ុន្មានខែនេះ ការលំបាកទាំងនេះមិនមែនជារឿងគួរឲ្យភ្ញាក់ផ្អើលនោះទេ ។ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០៨ អង្គជំនុំជម្រះវិសាមញ្ញបានចេញសេចក្តីជូនដំណឹងមួយដោយបានបញ្ជាក់ថា អង្គជំនុំជម្រះវិសាមញ្ញបាននិង «កំពុងចាប់ផ្តើមឆ្លើយតបទៅនឹងពាក្យបណ្តឹងរាប់រយ...» ។ សេចក្តីជូនដំណឹងនោះបានសម្តែងនូវការពេញចិត្តចំពោះអង្គការក្រៅរដ្ឋាភិបាលដូចជាមជ្ឈមណ្ឌលឯកសារកម្ពុជា និងអង្គការផ្សេងទៀតដែលបាន «ដើរតួនាទីសំខាន់ក្នុងការធានាឲ្យមានការចូលរួមរបស់ជនរងគ្រោះ» ។ សេចក្តីជូនដំណឹងបានបញ្ជាក់ថា ពាក្យបណ្តឹងទាំងអស់ «ត្រូវបានថតបញ្ចូលទៅក្នុងកុំព្យូទ័រពិនិត្យមើលនិងវិភាគ» ។ បើទោះបីជាសេចក្តីជូនដំណឹងនេះមិនបានបញ្ជាក់ថា ពេលណាដែល


អ្នកភូមិកំពុងតម្រង់ជួរចូលស្តាប់សវនាការ នួន ជា

អ្នកដាក់ពាក្យបណ្តឹងអាចទទួលបានការឆ្លើយតបមែន តែសេចក្តីជូនដំណឹងនេះបានបញ្ជាក់ថា អង្គជំនុំជម្រះ «នៅពេលនេះកំពុងរៀបចំផ្តល់យោបល់ដល់អ្នកដាក់ពាក្យបណ្តឹងអំពីស្ថានភាពរបស់ពាក្យបណ្តឹងនិងរបៀបដែលអង្គជំនុំជម្រះវិសាមញ្ញនឹងប្រើប្រាស់ពាក្យបណ្តឹងទាំងនោះ...» ។

ដោយទទួលស្គាល់អំពីការលំបាកផ្សេងៗដែលកំពុងប្រឈមមុខដោយអង្គជំនុំជម្រះវិសាមញ្ញ មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្ម័គ្រចិត្តផ្តល់ជំនួយដល់អង្គភាពជនរងគ្រោះនៅក្នុងកិច្ចការពិនិត្យមើល និងឆ្លើយតបទៅនឹងពាក្យបណ្តឹងទាំងនោះ ។ នៅក្នុងកិច្ចប្រជុំមួយជាមួយអនុប្រធានអង្គភាពជនរងគ្រោះ ហ្កាប្រៀលឡា ហ្កូនហ្សាឡេ រ៉ូឌ្រីហ្កេ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និង អ៊ែន ហាញឌុល ទីប្រឹក្សាផ្នែកច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងអំពីរបៀបដែលមជ្ឈមណ្ឌលឯក-សារកម្ពុជាអាចផ្តល់ទៅឲ្យអង្គភាពជនរងគ្រោះដែលរួមមានៈ ១) ផ្តល់អ្នកធ្វើការងារស្ម័គ្រចិត្ត ២) ផ្តល់ព័ត៌មានទៅដល់អ្នករួចរស់ជីវិតនៅក្រៅប្រទេសអំពីការចូលរួមនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ៣) ការបកប្រែឯកសារ ៤) ផ្តល់ជំនួយក្នុងការចែកចាយទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ និងសៀវភៅណែនាំដែលនឹងរួចរាល់ក្នុងពេលឆាប់ៗនេះអំពីការចូលរួមរបស់ជនរងគ្រោះទៅឲ្យអ្នករួចរស់ជីវិត ។ ជាងនេះទៅទៀត ដោយមើលឃើញអំពីការលំបាកក្នុងការទាក់ទងអ្នកនៅតាមទីជនបទដាច់ស្រយាល មជ្ឈមណ្ឌលឯកសារកម្ពុជាបានស្ម័គ្រចិត្តជួយអង្គភាពជនរងគ្រោះក្នុងការទាក់ទងជាមួយអ្នកដាក់ពាក្យបណ្តឹង ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញត្រូវការព័ត៌មានបន្ថែម និង នៅក្នុងការបញ្ជូនការឆ្លើយតបទៅកាន់អ្នករួចរស់ជីវិតដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាធ្លាប់ជួយបំពេញទម្រង់បែបបទព័ត៌មានអំពីជនរងគ្រោះ ។



## សេចក្តីសន្និដ្ឋាន

បើទោះបីជាមានការពន្យារពេលក្តី នៅពេលនេះអង្គជំនុំជម្រះវិសាមញ្ញកំពុងស្ថិតនៅក្នុងដំណាក់កាលចាប់ផ្តើមទំនាក់ទំនងអ្នករួចរស់ជីវិត និងជូនដំណឹងអំពីស្ថានភាពនៃពាក្យបណ្តឹងរបស់ពួកគាត់ ។ គិតត្រឹមថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៨ គេគិតថា សហព្រះរាជអាជ្ញានឹងចាប់ផ្តើមឆ្លើយតបទៅនឹងពាក្យបណ្តឹងដែលបានដាក់មុនដំបូងគេប្រមាណជានៅក្នុងសប្តាហ៍ដែលនឹងចាប់ផ្តើមនៅថ្ងៃទី១៨ ខែកុម្ភៈ ។ បើទោះបីជាការពន្យារពេលក្នុងការឆ្លើយតបនេះប្រហែលជាបានធ្វើឲ្យអ្នកដាក់ពាក្យបណ្តឹងជាច្រើនមិនសូវពេញចិត្ត យើងសង្ឃឹមថា អ្នកជាច្រើនទៀតនឹងនៅតែចាប់អារម្មណ៍ចូលរួមនៅក្នុងដំណើរការជំនុំជម្រះក្តី ។ ដោយសារតែអង្គភាពជនរងគ្រោះទើបតែត្រូវបានបង្កើតឡើងក្នុងពេលថ្មីៗនេះ ការយឺតយ៉ាវក្នុងការឆ្លើយតបនេះគឺពិតជាអាចយល់បាន ។ នៅពេលដែលប្រធានអង្គភាពជនរងគ្រោះចាប់ផ្តើមការងារ លទ្ធភាពរបស់អង្គភាពនេះនឹងត្រូវពង្រីកយ៉ាងខ្លាំងដោយសារអង្គភាពនេះអាចនឹងលៃលកជ្រើសរើសបុគ្គលិកបន្ថែម ។ ក្នុងករណីដែលមានបុគ្គលិកគ្រប់គ្រាន់ និងមាននីតិវិធីដែលមានប្រសិទ្ធភាពអង្គភាពនេះគួរតែអាចដោះស្រាយនិងឆ្លើយតបទៅនឹងពាក្យបណ្តឹងបានទាន់ពេលវេលាដើម្បីបង្កើនទំនុកចិត្តរបស់អ្នករួចរស់ជីវិតនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ។

**ស្វ ហ្សារីណា និង សារ៉ា ថមម៉ាស់**

# ការកែប្រែរចនាសម្ព័ន្ធតុលាការកូនកាត់ៈ កំណែទម្រង់ គតិយុត្តិផ្នែកព្រហ្មទណ្ឌជាតិ និងការផ្តល់អំណាចក្នុងតំបន់

***(តពីលេខមុន)***

## ***៤) សេចក្តីសម្រេចផ្ទុយគ្នាដែលអាចកើតមាននៅក្នុងតុលាការកូនកាត់និងការបំបែកជាបំណែកតូចៗនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ***

*ផលវិបាកធ្ងន់ធ្ងរដែលអាចកើតមានមួយផ្សេងទៀតក្នុងការងាររបស់តុលាការកូនកាត់គឺ «ការបំបែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលក្នុងនោះវិធានសំខាន់ៗខុសៗគ្នាលេចឡើងនៅក្នុងតំបន់ផ្សេងៗគ្នា ។» ជាមួយនឹងតុលាការកូនកាត់ឯករាជ្យ ដែលវិនិច្ឆ័យនូវបញ្ហាផ្នែកច្បាប់ ប៉ុន្តែគ្មានឋានានុក្រមនីតិវិធីពិនិត្យឡើងវិញ គោលការណ៍ប្រកាន់យកអ្វីដែលបានសម្រេចរួចហើយជាគោលនយោបាយនៃភាពចម្លងគ្នាពីតុលាការមួយទៅតុលាការមួយវិបត្តិអាចលេចឡើងយ៉ាងច្បាស់ពីភាពខុសគ្នាច្រើននៅក្នុងខ្លឹមសារនៃច្បាប់អន្តរជាតិ ។ ក្នុងខណៈដែលបំណែកគ្រោះថ្នាក់ដ៏មានសក្តានុពលនៅក្នុងមណ្ឌលតុលាការឧទ្ធរណ៍របស់សហរដ្ឋអាមេរិក ក្នុងបញ្ហាសំខាន់ៗផ្នែកច្បាប់ត្រូវបានដោះស្រាយតាមរយៈដីកាសុំពិនិត្យឡើងវិញរបស់តុលាការកំពូលរបស់សហរដ្ឋអាមេរិកដែលនេះជាការលើកកម្ពស់នូវស្ថានភាពដូចគ្នា «ប្រព័ន្ធច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលលេចឡើងគ្មានទាំងការត្រួតពិនិត្យឡើងវិញរបស់តុលាការជាន់ខ្ពស់ និងគ្មានទាំងតម្រូវការឲ្យគោរពតាមអ្វីដែលបានសម្រេចរួច» ។ ចូណាថានចារណេ បានពន្យល់អំពីគ្រោះថ្នាក់ថាៈ «ភាពខុសប្លែកគ្នានៅក្នុងច្បាប់អន្តរជាតិទូទៅ... អាចនឹងបន្ថយនូវភាពដូចគ្នានិងសកលភាព*



*ប្រជាជនកំពុងតម្រង់ជួរចូលបន្ទប់សវនាការ នួន ជា*

របស់ច្បាប់អន្តរជាតិបាន ។ លទ្ធផលពិតៗ អាចថា «វេទិកាដោះស្រាយវិវាទអន្តរជាតិដែលកាន់តែមានច្រើនឡើងអាចនឹងបង្កការលំបាកជាពិសេសណាមួយនៅក្នុងប្រព័ន្ធច្បាប់អន្តរជាតិ ។» ភាពខុសគ្នានៅក្នុងវិធានជាច្រើននៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ។ អាចនឹងនាំមកនូវភាពអន្តរាយដោយសំអាងលើហេតុផលមួយចំនួនៈ

ទីមួយ ឧក្រិដ្ឋកម្មអន្តរជាតិដែលអាចគិតថាមានលក្ខណៈសាកលតាមធម្មជាតិត្រូវបាត់បង់លក្ខណៈសាកលនិងការថ្កោលទោសជាអន្តរជាតិដោយហេតុថា មានការផ្លាស់ប្តូរទៅតាមតំបន់ ។

ទីពីរ ភាពចន្លោះប្រហោងអាចនឹងកើតមានដែលធ្វើឲ្យជនល្មើសបទឧក្រិដ្ឋជាអន្តរជាតិអាចគេចផុតពីការផ្តន្ទាទោសដោយផ្អែកលើការប្រែប្រួលតាមតំបន់ និងផ្អែកលើនិយមន័យនៃពាក្យឧក្រិដ្ឋកម្ម ។

ទីបី ចៅក្រមមួយចំនួននៅក្នុងតំបន់អាចកែប្រែទ្រង់ទ្រាយនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ដើម្បីផ្តល់ឱកាសឲ្យបុគ្គលជាពិសេសណាមួយអាចគេចផុតពីការផ្តន្ទាទោស ។

នៅទីបំផុតដោយស្ថិតនៅក្រោម«សម្ពាធនៃភាពខ្វែងគំនិតគ្នានៃនិយាមរបស់តុលាការកូនកាត់ខុសៗគ្នាធម្មនុញ្ញនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិអាចនឹងត្រូវបាត់បង់ដោយយោងទៅលើភាពទន់ខ្សោយនៃអង្គច្បាប់ដែលទើបតែនឹងចាប់កំណើត» ។ ទោះបីជាមានការសន្មតថា តុលាការកូនកាត់ទាំងអស់បានដាក់ចេញនូវគោលនយោបាយតឹងរ៉ឹងមួយ ដើម្បីធានាបាននូវការគោរពនៅក្នុងប្រព័ន្ធតុលាការចម្រុះក៏ដោយ ក៏ការព្រួយបារម្ភរបស់ ចូណាថាន ចារណេ នៅតែជារឿងមួយដ៏សំខាន់ដែលត្រូវយកចិត្តទុកដាក់ដែរ ។ សម្មតិកម្មនេះមានភាពត្រឹមត្រូវដូចគ្នាសម្រាប់តុលាការពិសេសអន្តរជាតិពិតប្រាកដ ។ ថូម៉ាស់ ប៊ឺហេនថល គឺជាចៅក្រមម្នាក់នៅក្នុងតុលាការយុត្តិធម៌អន្តរជាតិកត់សម្គាល់ថា «ការបង្កើតសាលាក្តីអន្តរជាតិអាចនឹងជះឥទ្ធិពលជាអវិជ្ជមាន» ។

បញ្ហានៃការបំបែកច្បាប់ព្រហ្មទណ្ឌអន្តរជាតិគឺជារឿងមួយដ៏សំខាន់ដែលត្រូវលើកយកមកដោះស្រាយ និងយ៉ាងហោចណាស់ក៏ត្រូវមានការជំទាស់ខ្លះៗដែរ ។ ថ្វីបើការគំរាមកំហែងនេះយើងមិនគួរប្រានចោលក៏ដោយក៏ប៉ុន្តែ «ភ័ស្តុតាងនានាដែលបានពីការបង្កើតឡើងវិញនូវសាលាក្តីនៃច្បាប់អន្តរជាតិទូទៅ និងលក្ខណៈនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិបង្ហាញថា ខ្លឹមសារនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ គឺទំនងជាមិនត្រូវប្រេះឆាខ្លាំងពេកនោះទេ ។ បញ្ហាគឺមិនស្ថិតនៅត្រង់ថា ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនេះនឹងឈានទៅរកភាពខុសៗគ្នាលើយុត្តិសាស្ត្រនោះទេផ្ទុយទៅវិញគឺថាតើសាលាក្តីទាំងនោះនឹងប្រើប្រាស់នូវ «គ្រាមភាសាដូចគ្នា» និង «ធ្វើការវិនិច្ឆ័យត្រឹមត្រូវដូចគ្នាដែរឬទេ?» ទោះបីជាមានការខុសគ្នាបន្តិចបន្តួចក៏ដោយ ។

ការសិក្សាជាទូទៅរបស់លោក ចារណេ ក្នុងការកំណត់ពីផលប៉ះពាល់នៃការបង្កើតសាលាក្តីអន្តរជាតិបានកាត់បន្ថយនូវការព្រួយបារម្ភនានាដែលគិតថា តុលាការទាំងនោះបង្កការប៉ះពាល់ទៅលើធម្មនុញ្ញនៃប្រព័ន្ធច្បាប់អន្តរជាតិ ។ ផ្អែកតាមការពិនិត្យពិច័យទៅលើយុត្តិសាស្ត្រនៃសាលាក្តីអន្តរជាតិជាង១០ នៅក្នុងផ្នែកសំខាន់ៗចំនួន៨ ចារណេ កត់សម្គាល់ឃើញថា សាលាក្តីខុសៗគ្នានេះ «មានការយល់ដឹងដូចៗគ្នាទៅលើច្បាប់នោះ» និងខុសគ្នាបន្តិចបន្តួចនៅត្រង់ការបកស្រាយទៅលើខ្លឹមសារនៃច្បាប់អន្តរជាតិ ។ ចារណេ បានសរុបសេចក្តីថា «ភាពខុសៗគ្នានៅក្នុងចំណោមសាលាក្តីទាំងនោះដែលកំណត់សេចក្តីលើបញ្ហានៃច្បាប់អន្តរជាតិមិនមានលក្ខណៈសំខាន់ខ្លាំងពេកដែលអាចបង្កជាបញ្ហាចោទចំពោះលក្ខណៈរួមនិងធម្មនុញ្ញនៃច្បាប់នេះដូចជាប្រព័ន្ធច្បាប់មួយនោះទេ» ។

យោងតាមការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធនានានៅក្នុងសាលាក្តីអន្តរជាតិផ្សេងៗ វីល្លៀម ប៊ឺកវ៉ាយ យល់ឃើញថា «លក្ខណៈដែលបង្ហាញទៅនឹងសាលាក្តីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវីបានបង្កើតឡើងប្រព័ន្ធមួយយ៉ាងមានប្រសិទ្ធភាពហើយដែលការសម្រេចរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិយូហ្គោស្លាវីមានប្រសិទ្ធភាពដូចគ្នា ដូច្នេះហើយវាជួយធានាឲ្យប្រព័ន្ធច្បាប់អន្តរជាតិមានលក្ខណៈតែមួយ» ។ ដូចគ្នាដែរ ប៊ឺកវ៉ាយ ជឿជាក់ថា «វាអាចនឹងមានការគោរពដ៏អស្ចារ្យមួយ...ចំពោះការសម្រេចរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ» ។

តាមធាតុពិត ភាពខុសគ្នាបន្តិចបន្តួចនៅក្នុងយុត្តិសាស្ត្រនឹងមិនប៉ះពាល់ទៅលើលក្ខណៈរួមនិងសមត្ថភាពឡើយ ហើយវាអាចនឹងផ្តល់ជាឱកាសមួយសម្រាប់ការសាកល្បងដែលនឹងជួយអភិវឌ្ឍន៍

ច្បាប់អន្តរជាតិឲ្យកាន់តែល្អ ។ គំនិតនេះគឺជាលទ្ធផលដែលកើតចេញពីអំណះអំណាងរវាងលោក ម៉ៃឃើល ដហ្វ និង ឆាល សាបេល ទៅលើ «ការសាកល្បងលើលទ្ធិប្រជាធិបតេយ្យ» ។

ម្យ៉ាងវិញទៀត ការបង្កើតតុលាការព្រហ្មទណ្ឌកូនកាត់ អាចជាមធ្យោបាយមួយក្នុងការទប់ស្កាត់មិនឲ្យមានការប្រេះឆាទៅលើច្បាប់ព្រហ្មទណ្ឌអន្តរជាតិដែលអាចនឹងកើតឡើង ប្រសិនបើតុលាការជាតិជាច្រើនបានបង្កើតនូវយុត្តិសាស្ត្រដាច់ដោយឡែកពីគ្នា ។ នៅក្នុងការវិភាគរបស់គាត់ទៅលើយុត្តិសាស្ត្ររបស់សាលាក្តីអន្តរជាតិចំពោះបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងមនុស្សជាតិ ហ្គូណាអេល មេត្រូ សង្កេតឃើញថា «បើទោះជាពេលខ្លះតុលាការជាតិពឹងផ្អែកទៅលើនិយមន័យក្នុងតំបន់ខុសៗគ្នា» និយមន័យស្តីពីបទល្មើសព្រហ្មទណ្ឌប្រឆាំងនឹងមនុស្សជាតិ យ៉ាងណាក៏ដោយ «សាលាក្តីអន្តរជាតិទទួលស្គាល់ចំពោះលក្ខណៈតែមួយនៃយុត្តិសាស្ត្រ» ។

## ៥) អវត្តមាននៃអំណាចក្រោមជំពូកទី៧ក្នុងការស្នើសុំឲ្យមានកិច្ចសហប្រតិបត្តិការរបស់ប្រទេសនីមួយៗ

សាលាក្តីអន្តរជាតិពិសេសដែលត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខក្រោមជំពូកទី៧របស់ខ្លួនមានសិទ្ធិនិងអំណាចក្នុងការស្នើសុំឲ្យមានកិច្ចសហប្រតិបត្តិការពីប្រទេសនីមួយៗដែលផ្ទុយគ្នាពីតុលាការកូនកាត់ដែលត្រូវបានបង្កើតឡើងដោយគ្មានសិទ្ធិអំណាចទាំងនោះ(ទោះបីជាក្រុមប្រឹក្សាសន្តិសុខអាចបង្កើតសាលាក្តីកូនកាត់ក៏ដោយរហូតមកទល់ពេលនេះគឺគ្មានសញ្ញាណាមួយដែលបង្ហាញពីការគិតគូរចំពោះលទ្ធភាពនេះទេ) ។ ផ្អែកតាមទ្រឹស្តីវាធ្វើឲ្យតុលាការកូនកាត់មានលក្ខណៈទន់ខ្សោយយ៉ាងខ្លាំងពីព្រោះថា តុលាការទាំងនេះមានអានុភាពតិចតួចជាងប្រទេសទាំងឡាយដែលក្រុមឧក្រិដ្ឋជនរស់នៅ ។ ជាតួយ៉ាង តុលាការកូនកាត់ដែលមិនមែនបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខមិនអាចអនុវត្តការគំរាមកំហែងឬដាក់ទណ្ឌកម្មទៅលើប្រទេសដែលរឹងទទឹងបានឡើយ ។ យ៉ាងណាមិញការវិនិច្ឆ័យប្រកបដោយប្រសិទ្ធភាពគឺត្រូវពឹងផ្អែកសំខាន់ទៅលើឆន្ទៈក្នុងការចូលរួមសហការរបស់អាជ្ញាធរដើម្បីប្រមូលភស្តុតាងធ្វើការចោទប្រកាន់ទទួលបាននូវភស្តុតាងទីតាំងតាមចាប់ខ្លួននិងកាត់ទោសជនចាប់ចោទ ។

ក៏ប៉ុន្តែ តាមពិតទៅសាលាក្តីអន្តរជាតិពិសេសដែលបានបង្កើតឡើងដោយក្រុមប្រឹក្សាសន្តិសុខក្រោមជំពូកទី៧ មិនអាចប្រើប្រាស់អំណាចរបស់ក្រុមប្រឹក្សាសន្តិសុខក្នុងការដាក់ទណ្ឌកម្មឡើយ ព្រោះថាសាលាក្តីទាំងនេះពឹងផ្អែកទៅលើមិត្តភាពរបស់ប្រទេសផ្សេងៗក្នុងការសហប្រតិបត្តិការ ។ ក្នុងការអនុវត្តជាក់ស្តែងសាលាក្តីកូនកាត់មិនមានភាពទន់ខ្សោយជាងសាលាក្តីអន្តរជាតិពិសេសទេ នៅពេលដែលខ្លួនស្នើសុំជំនួយពីប្រទេសទាំងនោះ ។

បន្ថែមលើនេះទៀត គំរូច្បាប់រដ្ឋប្បវេណីនៃការជំនុំជម្រះក្តីស្វែងរកយុត្តិធម៌ជាអន្តរជាតិដែលធ្វើឡើងជាលក្ខណៈកំបាំងមុខអាចនឹងត្រូវបានអនុញ្ញាតប្រសិនបើមានភស្តុតាងបង្ហាញច្បាស់ថាជនជាប់ចោទទទួលបានការជូនដំណឹងគ្រប់គ្រាន់ ហើយការការពារក្តីគ្មានការជំទាស់ការជំនុំជម្រះក្តីធ្វើឡើងដោយផ្អែកទៅតាមគោលការណ៍យុត្តិធម៌និងអព្យាក្រឹត និងប្រសិនបើជនជាប់ចោទមានចេតនាគេចវេះពីការកាត់ទោស ។

ទីបំផុត យើងរស់នៅក្នុងពិភពមួយដែលគ្មានភាពល្អឥតខ្ចោះពោលគឺពិភពទីពីរនៃភាពល្អឥតខ្ចោះ ។ តុលាការកូនកាត់មិនតែងតែជាឧបករណ៍ក្នុងការផ្តល់នូវយុត្តិធម៌ដ៏ល្អឥតខ្ចោះនោះឡើយ ប៉ុន្តែចំណុចខ្វះខាតរបស់តុលាការនេះអាចនឹងត្រូវកាត់បន្ថយ ហើយវាអាចផ្តល់នូវដំណោះស្រាយដែលយើងត្រូវការបំផុតទៅលើបញ្ហានានាដែលតុលាការទាំងនោះមានសមត្ថកិច្ចអាចធ្វើទៅបាន ។

## ៦) ហេតុអ្វីបានជាជ្រើសរើសយកតុលាការកូនកាត់ហើយមិនរើសយកសាលាក្តីអន្តរជាតិពិសេស?

នៅក្នុងការពិចារណាលើការដាក់តុលាការកូនកាត់ជំនួសមកជាសាលាក្តីអន្តរជាតិពិសេសនោះយើងត្រូវរុករកនូវគុណវិបត្តិនៃសាលាក្តីអន្តរជាតិពិសេសដែលមានស្រាប់ ហើយសង្កត់ធ្ងន់ទៅលើភាពខ្វះចន្លោះរបស់តុលាការកូនកាត់ដែលយើងអាចកែតម្រូវបាន ។

### ក) គុណវិបត្តិរបស់សាលាក្តីព្រហ្មទណ្ឌអន្តរជាតិនៅក្នុងប្រទេសរ៉ាន់ដា

ដោយបានបង្កើតឡើងនៅក្នុងឆ្នាំ១៩៩៤ បន្ទាប់ពីសង្គ្រាមប្រល័យពូជសាសន៍នៅក្នុងប្រទេសរ៉ាន់ដារួចមកសាលាក្តីព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសរ៉ាន់ដាបានជួបប្រទះនូវបញ្ហាយ៉ាងច្រើននៅក្នុងដំណើរការការធ្លាក់ចុះនូវអសមត្ថភាពខាងផ្នែករដ្ឋបាល ព្រមទាំងបញ្ហាក្នុងការចាត់ចែងថវិកាមិនបានត្រឹមត្រូវ ។ ប្រការដែលគួរឲ្យ

សោកស្តាយនោះគឺថា សាលាក្តីនេះចាប់ផ្តើមដំណើរការក្នុងបរិយាកាសមួយដែលមិនមានការគ្រប់គ្រងត្រឹមត្រូវនិងមានអំពើពុករលួយតិចតួច ។ ដោយសារតែមានគំនិតលាក់បាំងរបស់ប្រព័ន្ធសហប្រជាជាតិនិងការមិនព្រមលាតត្រដាងនូវកំហុសរបស់ខ្លួនការបិទបាំងនេះបានអូសបន្លាយអស់រយៈពេលស្ទើរតែជិតពីរឆ្នាំរហូតដល់អគ្គអធិការបានចេញនូវរបាយការណ៍ទិតៀនមួយ ។ ជាការពិត ក្រុមអ្នកទិតៀនក៏បានអះអាងដែរថា «ការចោទប្រកាន់ពីអសមត្ថភាព» បានក្លាយទៅជា «ស្រមោលអន្ទោលតាមប្រាណតុលាការប្រទេសវ៉ាន់ដា» ។ មានការពិបាកយ៉ាងខ្លាំងខាងផ្នែកភាសាដោយសារថាជាញឹកញាប់មានការបកប្រែធ្វើឡើងដោយមិនបានគ្រោងទុកជាមុននិងជួនកាលពុំមានការបកប្រែទាល់តែសោះ ។ លើសពីនេះទៀតសាលាក្តីព្រហ្មទណ្ឌអន្តរជាតិរបស់រ៉្វាន់ដា «បានទទួលរងនូវការប៉ះទង្គិចខ្លាំងដោយសារមានការចោទប្រកាន់ពីបទប្រកាន់ពូជសាសន៍... និងមានការផ្សព្វផ្សាយថាជនសង្ស័យពីបទប្រល័យពូជសាសន៍បួន នាក់កំពុងតែធ្វើការនៅក្នុងក្រុមការពារក្តី» ។ ក្រុមអ្នកទិតៀនក៏បានអះអាងថាតុលាការនេះមានភាពយឺតយ៉ាវពេក ។

មួយចំណែកដោយសារតែភាពគ្មានប្រសិទ្ធភាពរបស់តុលាការ អំពើពុករលួយនិងការចំណាយដ៏ច្រើនរបស់សាលាក្តីនេះ និងដោយសារតែលក្ខណៈមិនអាចចូលចុះខាងវប្បធម៌និងរូបសាស្ត្រ តុលាការព្រហ្មទណ្ឌអន្តរជាតិរបស់រ៉្វាន់ដាមានមូលដ្ឋាននៅក្នុងអារូស្សា, តង់ហ្សានី មិនមែនស្ថិតនៅក្នុងប្រទេសរ៉្វាន់ដាទេ ធ្វើឲ្យតុលាការនេះទទួលនូវបរាជ័យយ៉ាងធ្ងន់ធ្ងរក្នុងការបម្រើផលប្រយោជន៍និងទំនាក់ទំនងជាសាធារណៈជាមួយនឹងប្រជាពលរដ្ឋនៃប្រទេសរ៉្វាន់ដា ។ អ្នកទាំងឡាយដែលនៅរស់រានមានជីវិតពីរបបប្រល័យពូជសាសន៍ដែលសាលាក្តីព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសរ៉្វាន់ដាត្រូវជួយនោះបានសម្តែងអារម្មណ៍ជាទូទៅថាតុលាការនេះជាអ្នកក្រៅពុំបានផ្តល់នូវការគាំទ្រ ឬថែមទាំងមានឥរិយាបថគំរោះគំរើយទៀតផង ។

ក្រុមអ្នកដោះស្រាយវិបត្តិអន្តរជាតិបង្ហាញនូវការយល់ស្របដែលថា «ជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍យល់ថាសាលាក្តីនេះស្ថិតនៅឆ្ងាយនិងខុសប្លែកពីទឹកដីរបស់ខ្លួន» ។ តាមពិត «មានសាក្សីជាច្រើនបានបដិសេធមិនព្រមធ្វើជាសាក្សី បន្ទាប់ពីក្រុមមួយនៃអ្នកដែលរស់រានជីវិតពីរបបប្រល័យពូជសាសន៍ដែលមានឈ្មោះថា អ៊ីប៊ុយកា បានធ្វើការរិះគន់ទៅលើសាលាក្តី ព្រមទាំងបានបញ្ឈប់ការសហការជាមួយនឹងសាលាក្តីនេះ» ។ ជាងនេះទៅទៀត «ជនរងគ្រោះដោយអំពើឧក្រិដ្ឋកម្មរបស់រណសិរ្សអ្នកស្នេហាជាតិរ៉្វាន់ដា បានរិះគន់ខ្លាំងៗថាជាឧបករណ៍មួយរបស់របបគីហ្គាលី ដែលចាត់ទុកសាលាក្តីព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសរ៉្វាន់ដាថាជានិមិត្តរូបមួយនៃយុត្តិធម៌សម្រាប់អ្នកឈ្នះ» ។

សាលាក្តីព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសរ៉្វាន់ដាបានបើកមជ្ឈមណ្ឌលព័ត៌មានរបស់ខ្លួននៅក្នុងឆ្នាំ២០០០ ក្រោយពីការបង្កើតសាលាក្តីនេះបានរយៈពេលប្រាំឆ្នាំ ។ លោកស្រី អាលីសាន់ដេសហ្វក ដែលជាសាស្ត្រាចារ្យនិងអ្នកស្រាវជ្រាវសញ្ជាតិរ៉្វាន់ដារបស់អង្គការឃ្លាំមើលសិទ្ធិមនុស្សរ៉្វាន់ដា ដែលបានធ្វើការយ៉ាងពេញទំហឹងជាមួយនឹងសាលាក្តីនេះបានប្រាប់អ្នកសារព័ត៌មានថា សាលាក្តីព្រហ្មទណ្ឌអន្តរជាតិរបស់ប្រទេសរ៉្វាន់ដា នៅតែគ្មានទំនាក់ទំនងជាមួយនឹងប្រជាពលរដ្ឋសាមញ្ញក្នុងប្រទេសរ៉្វាន់ដាដដែល ។ លោកស្រីនិយាយថា «ប្រជាពលរដ្ឋរ៉្វាន់ដាភាគច្រើនពុំសូវស្គាល់សាលាក្តីនេះទេ មជ្ឈមណ្ឌលព័ត៌មានរបស់សាលាក្តីនេះ ដែលមានមូលដ្ឋាននៅក្នុងរដ្ឋធានីគីហ្គាលីមានបំពាក់ទៅដោយប្រព័ន្ធកុំព្យូទ័រពុំអាចជួយអ្វីច្រើនដល់ជនរងគ្រោះនិងក្រុមគ្រួសារដែលនៅមានជីវិតមួយចំនួនធំទេ» ហើយ «ប្រមាណជាកៅសិបភាគរយនៃប្រជាពលរដ្ឋរ៉្វាន់ដាចំនួន ៨.៥លាននាក់ជាប្រជាកសិករ និងភាគច្រើនរស់នៅដោយគ្មានភ្លើងអគ្គិសនីប្រើប្រាស់» ។ ឯកសារដែលផ្សព្វផ្សាយតាមវិទ្យុនិងការសម្តែងអំពីការបង្កើតឡើងវិញនូវដំណើរការកាត់ក្តីនៅតាមសហគមន៍មូលដ្ឋាននានាដែលរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលគឺជះឥទ្ធិពលខ្លាំងទៅលើការយល់ដឹងរបស់ប្រជាពលរដ្ឋរ៉្វាន់អំពីដំណើរការកាត់ក្តីរបស់តុលាការនេះជាងកិច្ចខិតប្រឹងប្រែងដ៏តិចតួចរបស់តុលាការក្នុងការចុះផ្សព្វផ្សាយនៅតាមមូលដ្ឋាន ។ លោកស្រី ភីនីល អាយរ៉ុនសៃ អ្នកឯកទេសខាងប្រព័ន្ធការឆាឆា *(តុលាការប្រជាជន)* ក៏បានសន្និដ្ឋានដែរថា ប្រជាជនរ៉្វាន់ដាភាគច្រើន «ពុំសូវបានដឹងអំពីដំណើរការកាត់ក្តីនៅក្នុងអារូស្សាទេ គឺគ្រាន់តែដឹងថាតុលាការព្រហ្មទណ្ឌ

អន្តរជាតិរបស់រ៉ាន់ដា ជាសាលាក្តីបរទេសមួយនិងផ្លាស់ប្តូរទ្រង់ទ្រាយជានីតិក្រមបរទេស ហើយដំណើរការកាត់ក្តីដ៏យឺតយ៉ាវនៃសាលាក្តីនេះគឺជាភ័ស្តុតាងមួយបង្ហាញពីអប្រសិទ្ធភាពរបស់អង្គការសហប្រជាតិ ។ អ្វីដែលធ្ងន់ធ្ងរទៅទៀតគឺថាវាប្រាសចាកពីតម្រូវការរបស់ប្រជាពលរដ្ឋរ៉ាន់ដា» ។ នៅក្នុងការស្រាវជ្រាវនោះលោកស្រីបានស្រាវជ្រាវឃើញថា «ការមន្ទិលសង្ស័យបានបង្កជាការខឹងសម្បាចំពោះការលាក់ពុតដែលថា អ្នកដែលត្រូវទទួលទោសធ្ងន់ធ្ងរបំផុតបែរជាស្ថិតក្រោមដំណើរការកាត់សេចក្តីយ៉ាងប្រពៃនិងប្រកបដោយយុត្តិធម៌បំផុត» ។ ទីបំផុត ជននោះត្រូវបានកាត់ឲ្យជាប់ទោសនៅក្នុងពន្ធនាគារដ៏ល្អប្រណីតរបស់ប្រទេសលោកខាងលិច ហើយនៅក្នុងស្ថានភាពដែលរួចផុតពីការកាត់ទោសប្រហារជីវិតទៀតផង» ។

រដ្ឋាភិបាលនៃប្រទេសរ៉ាន់ដាដែលប្រហែលអាចជាដៃគូដ៏មានអំណាចបំផុតរបស់តុលាការនេះ ក្នុងការទម្លាយនូវវប្បធម៌និទ្ទណ្ឌភាពរបស់ប្រទេសរ៉ាន់ដា និងក្នុងការបង្កើតឡើងវិញនូវនីតិច្បាប់និងការចូលរួមក្នុងការអប់រំជាលក្ខណៈទ្រង់ទ្រាយធំបានសម្តែងនូវការមិនពេញចិត្តនិងការខឹងសម្បាចំពោះសាលាក្តីនេះយ៉ាងខ្លាំងដូចប្រជាពលរដ្ឋដែលនៅមានជីវិតពីរបបប្រល័យពូជសាសន៍ដូចបានរៀបរាប់ខាងលើអ៊ីចឹងដែរ ។

ចាប់តាំងពីពេលដែលអង្គការសហប្រជាជាតិរៀបចំធ្វើសេចក្តីព្រាងលក្ខន្តិកៈសម្រាប់សាលាក្តីនេះ រដ្ឋាភិបាលនៃប្រទេសរ៉ាន់ដាបានជំទាស់ព្រមទាំងបានលើកពីហេតុផលនៃការ ប្រឆាំងរបស់ខ្លួនទៀតផង ។ ការខឹងសម្បានោះគឺថាមូលដ្ឋានរបស់សាលាក្តីនេះត្រូវរៀបចំនៅក្នុងតំបន់អារូស្សានៃប្រទេសតង់ហ្សានី ហើយថាការស្នើសុំយុត្តាធិការនៃតុលាការមានរហូតដល់ហួសពីពាក់កណ្តាលខែកក្កដា ឆ្នាំ១៩៩៤ ដែលរាប់បញ្ចូលទាំងរយៈពេល បន្ទាប់ពីរដ្ឋាភិបាលរ៉ាន់ដាថ្មីឡើងកាន់អំណាច ។ រដ្ឋាភិបាលរ៉ាន់ដាបានអះអាងថា តុលាការគួរតែមានមូលដ្ឋាននៅក្នុងប្រទេសរ៉ាន់ដាដើម្បីឲ្យសាលាក្តីនេះអាចផ្តល់នូវគណនេយ្យភាព និងការផ្សះផ្សាបានល្អប្រសើរ ។ បើទោះជាមានកិច្ចប្រឹងប្រែងជាវិជ្ជមានខ្លះៗនៅក្នុងការចូលរួមចំណែកជាមួយរដ្ឋាភិបាលរ៉ាន់ដា ក៏ដោយ ក៏សាលាក្តីនេះបានបង្ហាញពីអសមត្ថភាពរបស់ខ្លួនដែលមិនបានរៀបចំទំនាក់ទំនងដ៏ស្មុគ្រស្មាញប្រកបដោយប្រសិទ្ធភាពជាមួយនឹងប្រព័ន្ធគ្រប់គ្រងក្រោយពីរបបប្រល័យពូជសាសន៍នៅក្នុងអំឡុងពេលដ៏ខ្លីនៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៩៩ ការធ្វើទំនាក់ទំនងជាមួយនឹងសាលាក្តីនេះកាន់តែចុះខ្សោយដោយហេតុថា «ទំនាក់ទំនងការទូតរវាងប្រទេសរ៉ាន់ដានិងសាលាក្តីនេះស្ថិតក្នុងសភាពធ្ងន់ធ្ងរក្រោយពេលដែលសាលាឧទ្ធរណ៍បានចេញដីកាដោះលែង *Jean-Bosco Barayagwiza* ជាប្រធាននៅក្នុងក្រសួងការបរទេសនិងជានាយកស្ថានីយវិទ្យុមួយសម្រាប់ឃោសនាឲ្យមានការខឹងសម្បាដោយសារតែមានការបំពានលើក្រមនីតិវិធី» ។ បើទោះបីជាបញ្ហាដ៏ធ្ងន់ធ្ងរនៅក្នុងទំនាក់ទំនងការទូតរវាងសាលាក្តីនេះនិងប្រទេសរ៉ាន់ដាត្រូវបានផ្សះផ្សាជាផ្លូវការយ៉ាងណាក៏ដោយ ក៏គេសង្កេតឃើញមានកិច្ចសហប្រតិបត្តិការគ្មានតិចតួចបំផុត ។

ទាំងការគាំទ្ររបស់រដ្ឋាភិបាលរ៉ាន់ដាចំពោះការឆាឆានិងការ


ខ្មែរមូស្លីមចូលរួមស្តាប់សវនាការ នួន ជា

សម្រេចអនុម័តច្បាប់រៀបចំអង្គការស្តីពីការរៀបចំដំណើរការកាត់ទោសលើបទល្មើសដែលបង្កើតឡើងនូវឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឬឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលបានប្រព្រឹត្តចាប់ពីថ្ងៃទី១ ខែតុលា ឆ្នាំ១៩៩០ គឺជាសញ្ញាមួយដែលបង្ហាញថាសាលាក្តីនេះបានធ្វើការយ៉ាងតិចតួចបំផុតក្នុងការកែលម្អស្ថាប័នតាក់តែងច្បាប់ ក៏ដូចជាស្ថាប័នតុលាការដែលមាននៅក្នុងប្រទេសរ៉្វាន់ដា ។ ដោយមានបុគ្គលិកបម្រើការជាង៨០០នាក់ និងថវិកាប្រមាណកៅសិបលានដុល្លារអាមេរិក សាលាក្តីនេះបានបង្វែរទិសដៅធនធានដ៏ច្រើនសន្ធឹកសន្ធាប់នេះដែលអាចត្រូវបានយកមកប្រើប្រាស់ដើម្បីស្តារឡើងវិញនូវផ្នែកខ្វះនៃប្រព័ន្ធតុលាការដ៏ខ្ទេចខ្ទាំរបស់ប្រទេសរ៉្វាន់ដា ។ ថវិការបស់តុលាការអាចត្រូវបានប្រើប្រាស់សម្រាប់កសាងឡើងវិញនូវអគារតុលាការថ្នាក់មូលដ្ឋាន និងធ្វើការកែលម្អពន្ធនាគាររៀបចំអាគារច្បាប់ឲ្យមានសម្ភារៈបរិក្ខារសមស្រប ព្រមទាំងជួយបំពាក់បំប៉នគណៈមេធាវីរបស់ប្រទេសរ៉្វាន់ដា ដែលទាំងអស់នេះ គឺជាកត្តាដែលមិនអាចកាត់ថ្លៃបាននៅក្នុងការស្តាបនាឡើងវិញនូវប្រព័ន្ធយុត្តិធម៌របស់ប្រទេសរ៉្វាន់ដា ក្នុងរយៈពេលយូរអង្វែង និងដែលជំរុញដល់ការបង្កើតនូវវប្បធម៌នីតិរដ្ឋមួយ ។



ប្រទេសរ៉្វាន់ដាត្រូវទទួលបន្ទុកចំពោះទណ្ឌិតជាង១៣០.០០០នាក់ ដែលត្រូវបានឃុំឃាំងនៅក្នុងពន្ធនាគារនៃប្រទេសនេះ ហើយនិងដំណើរការកាត់ទោសរបបប្រល័យពូជសាសន៍នៅក្នុងប្រទេសបានសម្រេចក្តីប្រមាណជា៩.០០០០ករណី ដែលមាននៅក្នុងបញ្ជីនៅរវាងឆ្នាំ១៩៩៦ដល់ឆ្នាំ២០០២ ដែលនេះគឺជាល្បឿនមួយដែលបានសម្រេចឡើងដោយពុំមានការធានាចំពោះដំណើរការវិនិច្ឆ័យដ៏ត្រឹមត្រូវចំពោះពិរុទ្ធជន ។ ដោយមើលឃើញថា «បើទោះជាអាចរក្សាបាននូវកម្រិតល្បឿនប៉ុននេះក៏ដោយ ក៏ដំណើរការនេះនឹងត្រូវការរយៈពេលរហូតដល់១២ឆ្នាំ នៅក្នុងការកាត់ទោសជនជាប់ចោទពីបទប្រល័យពូជសាសន៍ដែលមានចំនួនប្រហែលពី១១០.០០០នាក់ ទៅ១៣០.០០០នាក់ ដែលត្រូវបានឃុំខ្លួននៅក្នុងពន្ធនាគារដ៏ណែនតាន់តាប់នោះ» ដូច្នេះ ឥឡូវនេះប្រទេសរ៉្វាន់ដាបានងាកទៅរកប្រព័ន្ធកាឆាឆាដែលជាគំរូនៃប្រព័ន្ធយុត្តិធម៌មួយដែលរឹតតែធ្វើឲ្យឃ្លាតឆ្ងាយពីស្តង់ដារអន្តរជាតិថែមទៀត ។ ភាពអស់សង្ឃឹមដែលជំរុញឲ្យរដ្ឋាភិបាលរ៉្វាន់ដាប្រកាន់យកនូវប្រព័ន្ធយុត្តិធម៌មួយដែលមានលក្ខណៈផ្ទុយពីដំណើរការដ៏យឺតយ៉ាវរបស់សាលាក្តីដែលខកខានមិនបានបំពេញនូវសេចក្តីត្រូវការរបស់ជនរងគ្រោះដែលទាមទារឲ្យមានដំណើរការយុត្តិធម៌មួយដែលមានភាពឆាប់រហ័ស និងមានអព្យាក្រឹត មិនលម្អៀងចំពោះឧក្រិដ្ឋជនកំពូលៗ ។

សរុបសេចក្តីមកការខ្វះអសមត្ថភាពរបស់សាលាក្តី នៅក្នុងការផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងប្រជាជនក្នុងប្រទេស ឬជាមួយនឹងប្រព័ន្ធតុលាការជាតិបានជះឥទ្ធិពលយ៉ាងធំធេងមកលើការខ្វះសមត្ថភាពរបស់ខ្លួន ដើម្បីបំពេញនូវអាណត្តិដ៏ទូលំទូលាយរបស់ខ្លួនប្រកបដោយសីលធម៌ក្នុងការជំរុញឲ្យមាននីតិរដ្ឋ និងបណ្តុះនូវវប្បធម៌នៃការទទួលខុសត្រូវ ។

***(នៅមានត)***

**អេរ៉ែល ហ៊ីហ្គូនេត**

# បញ្ហានៃការធ្វើបណ្តឹងឧទ្ធរណ៍ដោយអៀង សារី ជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧

## I. *អ្នកផ្តល់សារណា*

*អ៊ែន ហាញ៉ខល ជាទីប្រឹក្សាច្បាប់របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅទីក្រុងភ្នំពេញប្រទេសកម្ពុជា ។ អ៊ែន ហាញ៉ខល ធ្លាប់ធ្វើការជាមួយអង្គការក្រៅរដ្ឋាភិបាលទាក់ទងនឹងបញ្ហាសិទ្ធិមនុស្សនិងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ អស់រយៈពេលជាង១០ឆ្នាំនិងជាសមាជិកគណៈមេធាវីនៅរដ្ឋកាលីហ្វ័រញ៉ានៃសហរដ្ឋអាមេរិក ។ យោបល់ដែលបញ្ចេញនៅក្នុងសារណានេះ គឺជាយោបល់ផ្ទាល់ខ្លួន និងមិនឆ្លុះបញ្ចាំងអំពីទស្សនៈ ឬគោលនយោបាយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាទេ ។*

## II. *សេចក្តីសង្ខេបអំណះអំណាង*

*សារណានេះត្រូវបានធ្វើឡើងតាមរយៈសេចក្តីជូនដំណឹងជាសាធារណៈរបស់អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អង្គជំនុំជម្រះវិសាមញ្ញ) ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលអនុញ្ញាតឲ្យមានការផ្តល់សារណារបស់អ្នកមិនមែនជាភាគីនៃរឿងក្តីដោយអនុលោមទៅតាមមាត្រា៣៣នៃវិធានផ្ទៃក្នុង ។*

*ជនជាប់ចោទ អៀង សារី កំពុងព្យាយាមរកការដោះលែងបណ្តោះអាសន្នឃុំខ្លួននៅក្នុងផ្ទះរបស់គាត់ដោយសំអាងទៅលើហេតុផលជាច្រើន ហើយហេតុផលមួយក្នុងចំណោមហេតុផលទាំងនោះគឺគាត់មានសុខភាពទ្រុឌទ្រោម ។ វិធាននីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញមិនបានចែងអំពីកាលៈទេសៈ ឬលក្ខខណ្ឌដែលជនជាប់ចោទអាចត្រូវដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយសារមូលហេតុសុខភាពនោះទេ ។ ដោយសារមូលហេតុនេះវាជារឿងចាំបាច់ដែលត្រូវទៅរកមើលវិធាននីតិវិធីរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិ ។ ដូចអង្គជំនុំជម្រះវិសាមញ្ញដែរមិនមានសាលាជំនុំជម្រះក្តីណាមួយចែងច្បាស់លាស់អនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយសារបញ្ហាសុខភាពនោះទេ ។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែង សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិទាំងនោះបានអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្ននៅក្នុងកាលៈទេសៈបីយ៉ាងៈ ពេលដែលការព្យាបាលវេជ្ជសាស្ត្រមិនមាននៅក្នុងកន្លែងឃុំឃាំងនោះ ឬប្រទេសនោះ ដោយសារបុព្វហេតុមនុស្សធម៌នៅពេលដែលលក្ខខណ្ឌរបស់ជនជាប់ចោទមិនអាចស្ថិតនៅក្នុងមន្ទីរឃុំឃាំងបាន និងនៅពេលដែលជនជាប់ចោទមិនអាចចូលរួមក្នុងការជំនុំជម្រះក្តីកើត ។*

*នៅពេលដែលជនជាប់ចោទត្រូវដោះលែងដោយសារត្រូវការការព្យាបាលជាចាំបាច់នោះ ការដោះលែងនោះត្រូវធ្វើឡើងដោយមានកំណត់លក្ខខណ្ឌចំពោះសេរីភាពធ្វើដំណើរបានត្រឹមតែនៅក្នុងមន្ទីរព្យាបាល និងត្រូវត្រឡប់មកកាន់កន្លែងឃុំខ្លួនវិញភ្លាមបន្ទាប់ពីការព្យាបាលត្រូវបញ្ចប់ ។ ករណីតែមួយគត់ដែលជនជាប់ចោទត្រូវដោះលែងឲ្យត្រឡប់ទៅផ្ទះ ដោយសារមូលហេតុសុខភាពទំនងជានៅពេលដែលជនជាប់ចោទត្រូវបានគេពិនិត្យឃើញថាមានជំងឺមហារីកដែលមិនអាចវះកាត់បាន និងដែលមិនអាចព្យាបាលបានដោយមានការបញ្ជាក់ថា ជនជាប់ចោទអាចមានជីវិតរស់នៅយ៉ាងយូរពីរឬបីខែទៀតប៉ុណ្ណោះ ។ ប្រសិនបើលក្ខខណ្ឌសុខភាពរបស់លោក អៀង សារី មិនមែនជិតដល់ដំណាក់កាលចុងក្រោយបង្អស់នោះទេ គាត់មិនគួរត្រូវដោះលែងពីកន្លែងឃុំខ្លួនរបស់អង្គជំនុំជម្រះវិសាមញ្ញ និងដាក់ឲ្យនៅក្រោមការឃុំខ្លួនក្នុងផ្ទះដោយសំអាងលើមូលហេតុសុខភាពតែមួយនោះទេ ។*

## III. *អំណះអំណាង*

### *ក) នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញមិនបានបញ្ជាក់ច្បាស់លាស់អំពីបទដ្ឋានសម្រាប់កំណត់ថាតើពេលណាដែលការដោះលែងនៅក្រៅឃុំបណ្តោះអាសន្នអាចធ្វើទៅបានដោយសំអាងលើបញ្ហាសុខភាព*

*១) មេធាវីរបស់ អៀង សារី បានជំទាស់ទៅនឹងការរកឃើញរបស់ចៅក្រមស៊ើបអង្កេតដែលបានរកឃើញថា «មកទល់ពេលនេះមិនមានឯកសារណាមួយរបស់មេធាវីដែលធ្វើឲ្យ [ពួកគេ]*

ជឿជាក់ថាស្ថានភាពសុខភាពរបស់ជនជាប់ចោទមិនអាចនៅក្នុងមន្ទីរឃុំឃាំងបាននោះទេ» ។ មេធាវីបានអះអាងថា ដោយសារស្ថានភាពបេះដូងរបស់លោក អៀង សារីៈ

*គាត់ត្រូវការជាចាំបាច់មិនត្រឹមតែការព្យាបាលជាប្រចាំនិងសមរម្យនោះទេ ថែមទាំងបរិស្ថានរស់នៅមួយដែលសមរម្យបំផុតសម្រាប់សុខភាពទ្រុឌទ្រោមរបស់គាត់ទៀតផង ។ បើទោះបីជាមានការព្យាបាលវេជ្ជសាស្ត្រក៏ដោយ... ស្ថានភាពរបស់កន្លែងឃុំឃាំងគឺមិនសមស្របសម្រាប់អ្នកដែលមានសុខភាពទ្រុឌទ្រោមដូចគាត់ទេ ។*

ដោយសារហេតុផលនេះ មេធាវីស្នើសុំឲ្យដាក់ការឃុំឃាំងលោក អៀង សារី នៅក្នុងផ្ទះ ។

២) ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញបានចែងថា «លក្ខខណ្ឌសម្រាប់ការចាប់ខ្លួន និងការឃុំឃាំងខ្លួនរបស់ជនជាប់ចោទ ត្រូវគោរពទៅតាមច្បាប់ជាធរមាន» ។ ច្បាប់ជាធរមានរួមមានទាំងវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញនិងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា ។

៣) វិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញបានបញ្ជាក់ថា ជនជាប់ចោទនឹងត្រូវដោះលែង នៅពេលដែលលក្ខខណ្ឌសម្រាប់ការឃុំឃាំងខ្លួនលែងបំពេញបានទៀត ហើយលក្ខខណ្ឌដែលមានចែងទាំងអស់មិនមានទាក់ទងនឹងបញ្ហាសុខភាពទេ ។ វិធានផ្ទៃក្នុងក៏បានចែងទៀតថា តុលាការអាចបង្គាប់ឲ្យមានការត្រួតពិនិត្យវេជ្ជសាស្ត្រឬចិត្តសាស្ត្រ ដើម្បីកំណត់ថាតើ «ជនជាប់ចោទ.... មានកាយសម្បទា ខាងផ្លូវកាយ និងផ្លូវចិត្តអាចចូលរួមក្នុងការជំនុំជម្រះក្តី ឬក៏ដោយសារមូលហេតុផ្សេងទៀត» ។ ប៉ុន្តែវិធានផ្ទៃក្នុងមិនបានផ្តល់ការណែនាំអំពីបទដ្ឋានសមស្របសម្រាប់កំណត់ថាតើពេលណាដែលសុខភាពទ្រុឌទ្រោមនឹងអាចធ្វើឲ្យជនជាប់ចោទមិនអាចចូលរួមជំនុំជម្រះក្តីបាន ឬប្រសិនបើនៅពេលណាដែលសុខភាពទ្រុឌទ្រោមអាចយកមកសំអាងសម្រាប់អនុញ្ញាតឲ្យមានការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្ននោះទេ ។

៤) ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាមានចែងអំពីបញ្ហាសុខភាពតែនៅក្នុងដំណាក់កាលចាប់ខ្លួនដំបូងប៉ុណ្ណោះ ដោយបានចែងថាព្រះរាជអាជ្ញាអាចបញ្ជាឲ្យមានការពិនិត្យមើលសុខភាពជនដែលត្រូវចាប់ខ្លួនដើម្បីបញ្ជាក់ថាតើស្ថានភាពសុខភាពរបស់ជនត្រូវចាប់នោះ «សមស្របសម្រាប់ការចាប់ខ្លួនឬទេ» ។ ដូចវិធានផ្ទៃក្នុងដែរ ក្រមនីតិវិធីព្រហ្មទណ្ឌនេះមិនបានចែងអំពីលក្ខខណ្ឌដើម្បីកំណត់អំពី «ការដែលអាចចូលរួមសវនាការ» បាននោះទេ ។

៥) ដោយយោងទៅលើភាពខុសចន្លោះនៅក្នុងច្បាប់នីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញ វាជាការចាំបាច់ណាស់ក្នុងការស្វះស្វែងរកការណែនាំ «ក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ» ។

**១) សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិអនុញ្ញាតឲ្យមានការដោះលែងក្រៅឃុំបណ្តោះអាសន្ន នៅពេលដែលការព្យាបាលវេជ្ជសាស្ត្រមិនមាន ដោយសារបុព្វហេតុមនុស្សធម៌និងនៅពេលដែលជនជាប់ចោទមិនអាចចូលរួមក្នុងការជំនុំជម្រះក្តីបាន**

៦) ច្បាប់នីតិវិធីរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី និងរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន បានអនុញ្ញាតឲ្យមានការដោះលែងនៅក្រៅឃុំបណ្តោះអាសន្ន នៅពេលដែលអង្គជំនុំជម្រះនៃសាលាដំបូងជឿជាក់ថា ជនជាប់ចោទនឹងបង្ហាញខ្លួននៅ ពេលជំនុំជម្រះនិងមិនបង្កគ្រោះថ្នាក់ដល់ជនរងគ្រោះនិងសាក្សី ។ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិ អង្គជំនុំជម្រះនៃសាលាដំបូងត្រូវតែដោះលែងជនត្រូវចាប់ខ្លួន លុះត្រាណាតែអង្គជំនុំជម្រះគិតថាការឃុំខ្លួនបណ្តោះអាសន្ននេះគឺសំខាន់ណាស់ដើម្បីធានាវត្តមានរបស់ជននោះនៅពេលជំនុំជម្រះ ដើម្បីជៀសវាងការបង្កគ្រោះថ្នាក់ដល់ការស៊ើបអង្កេត ឬសវនាការ ឬដើម្បីការពារកុំឲ្យមានការបង្កបទល្មើសថ្មីទៀត ។ មិនមានលក្ខន្តិកៈច្បាប់បង្កើតសាលាជំនុំជម្រះក្តីនិងច្បាប់នីតិវិធីរបស់សាលាជំនុំជម្រះក្តីទាំងនេះមួយណាមានចែងច្បាស់លាស់ ដោយអនុញ្ញាតឲ្យមានការដោះលែងនៅក្រៅឃុំបណ្តោះអាសន្នដោយសារមូលហេតុសុខភាពនោះទេ ។ ទោះជាយ៉ាងណាក៏ដោយ សាលាជំនុំជម្រះក្តីអន្តរជាតិធ្លាប់បានអនុញ្ញាតមានការដោះលែងក្រៅឃុំបណ្តោះអាសន្ននៅពេលដែលជនជាប់ចោទអាចបង្ហាញថា ជនជាប់ចោទត្រូវការការព្យាបាលវេជ្ជសាស្ត្រដែលមិនអាចរកបាននៅក្នុងកន្លែងឃុំខ្លួន ឬប្រទេសឃុំខ្លួន ខ្លួនកំពុងតែប្រឈមមុខនឹងជំងឺដែលឈានដល់ដំណាក់

កាលចុងក្រោយ និងមិនមានពេលវេលាច្រើនសម្រាប់រស់នៅឬមិនអាចចូលរួមក្នុងសវនាការបាន ។

៧) ដូចចៅក្រមអង្គជំនុំជម្រះវិសាមញ្ញដែរ នៅក្នុងការពិចារណាថាតើការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយសារមូលហេតុសុខភាពសមរម្យឬអត់នោះ អង្គជំនុំជម្រះនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី និងរ៉្វាន់ដា និងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន អាចបញ្ជាឲ្យមានការត្រួតពិនិត្យវេជ្ជសាស្ត្រផ្លូវចិត្ត ឬផ្អែកវិបត្តិស្មារតីចំពោះជនដែលកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតព្រហ្មទណ្ឌ ។ សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌទាំងនេះក៏ពិចារណាផងដែរទៅលើរបាយការណ៍សុខភាពនិងរបាយការណ៍របស់អ្នកជំនាញដែលផ្តល់ជូនដោយភាគីនៅក្នុងរឿងក្តី និងសក្ខីភាពរបស់សាក្សីដែលជាអ្នកជំនាញ ។

### ១) ការដោះលែងនៅក្រៅឃុំបណ្តោះអាសន្នជាទូទៅអនុញ្ញាតតែនៅពេលដែលមិនមានការព្យាបាលគ្រប់គ្រាន់

៨) វិធានទូទៅដែលប្រើប្រាស់ដោយសាលាជំនុំជម្រះក្តីអន្តរជាតិគឺថា «ជំងឺធ្ងន់ធ្ងរតែមួយមុខ មិនអាចទទួលបានការដោះលែងនៅក្រៅឃុំបណ្តោះអាសន្នទេ ដរាបណាមានការព្យាបាលគ្រប់គ្រាន់ផ្តល់ឲ្យជនជាប់ចោទដោយសាលាជំនុំជម្រះក្តី» ។ ជាក់ស្តែង នៅក្នុងតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាលីអូន ជនជាប់ចោទ ហ៊ីងហ្កា ន័រមេន និងជនជាប់ចោទម្នាក់ទៀតត្រូវបានបញ្ជូនទៅកាន់ប្រទេសសេណេហ្កាល់ «ដើម្បីទទួលបានការព្យាបាលដែលគេគិតថាជាធម្មតា ប៉ុន្តែការព្យាបាលនេះមិនអាចរកបាននៅក្នុងប្រទេសសេរ៉ាលីអូន» ។

៩) នៅក្នុងសំណុំរឿងស្តានីហ្ស៊ីក នៅសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី ខាងមេធាវីបានអះអាងថា «ជនជាប់ចោទមិនអាចព្យាបាលបានទេនៅក្នុងកន្លែងឃុំខ្លួន និងថាប្រសិនបើជនជាប់ចោទនៅតែស្ថិតនៅក្នុងមន្ទីរឃុំខ្លួន ជនជាប់ចោទអាចបាត់បង់ជីវិត ឬមិនអាចចូលរួមយ៉ាងមានប្រសិទ្ធភាពនៅក្នុងសវនាការ» ។ អង្គជំនុំជម្រះនៃសាលាដំបូងបានរកឃើញថា ភ័ស្តុតាងពិតជាបានបង្ហាញថា ជនជាប់ចោទ «មានជំងឺធ្ងន់គួរសម» ។ ប៉ុន្តែភាគីនៅក្នុងរឿងក្តីបានជំទាស់ទៅនឹងស្ថានភាពធ្ងន់ធ្ងរនៃជំងឺរបស់គាត់ ។ អង្គជំនុំជម្រះបានសង្កត់ធ្ងន់ថា បញ្ហាដែលទាក់ទងនោះគឺ «ថាតើជនជាប់ចោទ[អាច] ទទួលបានការព្យាបាលគ្រប់គ្រាន់ឬទេ នៅពេលឃុំខ្លួននៅក្នុង [មន្ទីរឃុំខ្លួនរបស់អង្គការសហប្រជាជាតិ]» ។ អង្គជំនុំជម្រះនៃសាលាដំបូងបានចេញសាលក្រមមិនអនុញ្ញាតឲ្យនៅក្រៅឃុំបណ្តោះអាសន្នដោយផ្អែកសេចក្តីសម្រេចចិត្តទៅលើសក្ខីភាពរបស់សាក្សីខាង



ប្រជាជនកំពុងតម្រង់ជួរចូលស្តាប់សវនាការ នួន ជា

ព្រះរាជអាជ្ញា និងខាងមេធាវីដែលយល់ស្របថា ការព្យាបាលអាចធ្វើឡើងបាននៅក្នុងមន្ទីរឃុំឃាំងនៅក្នុងប្រទេសហុល្លង់ និងថាស្ថានភាពរបស់ជនជាប់ចោទត្រូវបានដោះស្រាយតាមរយៈការផ្តល់ឲ្យនូវការព្យាបាលនេះ ។

១០) ដូចគ្នាដែរនៅក្នុង សំណុំរឿងរបស់ស្រូហ្គា អង្គជំនុំជម្រះកំពូលនៃសាលាជំនុំជម្រះក្តី ព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបាន ពិចារណាអំពីសំណើរបស់មេធាវីដែលថាជនជាប់ចោទគួរតែត្រូវដោះលែងនៅមុនគេណោហ្គូសម្រាប់រយៈពេល៨ខែដើម្បីទទួលការព្យាបាលវះកាត់ដូរដាក់ឆ្អឹងត្រគាកសិប្បនិមិត្តទាំងមូល ។ បើទោះបីជាព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងសំណើសុំដោះលែងនៅក្រៅឃុំបណ្តោះអាសន្ននេះក៏ដោយ អង្គជំនុំជម្រះនៃសាលាកំពូលបានបដិសេធសំណើរបស់មេធាវីដោយសារខាងមេធាវីខកខានមិនបានបង្ហាញថាការវះកាត់និងការថែទាំសុខភាពបន្ទាប់ពីការវះកាត់នោះមិន «គ្រប់គ្រាន់» ទេនៅក្នុងមន្ទីរសុខភាពរបស់សាលាជំនុំជម្រះក្តីនៅក្នុងប្រទេសហុល្លង់ ។

**២) ការដោះលែងដោយផ្អែកលើមូលហេតុមនុស្សធម៌គឺសមរម្យនៅពេលដែលជនជាប់ឃុំឃាំងមានជំងឺដែលប៉ះពាល់ដល់អាយុជីវិតភ្លាមៗ**

១១) អង្គជំនុំជម្រះនៃសាលាដំបូងរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបានថ្លែងថា «ការដោះលែងអាចធ្វើទៅបាននៅពេលដែលស្ថានភាពសុខភាពរបស់ជនជាប់ចោទមិនសមរម្យទៅនឹងការឃុំឃាំងខ្លួនបែបណាមួយ» ។ ប៉ុន្តែជំងឺធ្ងន់ធ្ងរតែមួយមុខមិនអាចអនុញ្ញាតឲ្យមានការដោះលែងនោះទេ នៅពេលដែលលក្ខខណ្ឌនៃជំងឺនោះមិនមែនដល់ដំណាក់កាលចុងក្រោយ ឬប៉ះពាល់ដល់អាយុជីវិតភ្លាមៗ ឬមិនអាចព្យាបាលបាននៅក្នុងកន្លែងឃុំខ្លួន ។ «ការដែលថាជនជាប់ចោទដែលមានជំងឺនឹងមានអារម្មណ៍ល្អ និងអាចទទួលយកការព្យាបាលនៅក្នុងប្រទេសរបស់ជនជាប់ចោទបានច្រើនជាងដោយមានថែទាំពីក្រុមគ្រួសារ មិន...អាចធ្វើឲ្យករណីរបស់ជនជាប់ចោទជាករណីពិសេស...» ដែលនាំទៅដល់ការដោះលែងនៅក្រៅឃុំឡើយ ។

១២) នៅក្នុងសំណុំរឿងរូតាហ្កាន់ដា ខាងមេធាវីបានអះអាងថាជនជាប់ចោទបានកើតមានជំងឺយ៉ាងធ្ងន់ធ្ងរបន្ទាប់ពីការបញ្ជូនខ្លួនគាត់ទៅកាន់កន្លែងឃុំឃាំងខ្លួនរបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដា ។ អង្គជំនុំជម្រះនៃសាលាដំបូងបានច្រានចោលសំណើសុំឲ្យការដោះលែងនៅក្រៅឃុំដោយសារសាលាជំនុំជម្រះក្តី «មិនទទួលបានឯកសារដែលធ្វើឲ្យអង្គជំនុំជម្រះជឿជាក់ថាស្ថានភាពជំងឺរបស់ជនជាប់ចោទកាន់តែធ្ងន់ធ្ងរជាងមុន ដែលតម្រូវឲ្យមានការផ្លាស់ប្តូរស្ថានភាពឃុំខ្លួនរបស់ជនជាប់ចោទទេ» ។ ដូចគ្នាដែរនៅក្នុងសំណុំរឿងប៊ីកាមុមប៉ាកា ខាងមេធាវីបានអះអាងថា «ដោយសារតែការឃុំឃាំងខ្លួន ស្ថានភាពសុខភាពរបស់ជនជាប់ចោទគឺងាយនឹងក្លាយទៅជាធ្ងន់ធ្ងរជាងមុន» ។ បន្ទាប់ពីការថ្លឹងថ្លែងហេតុផលដោយអង្គជំនុំជម្រះនៅក្នុងសំណុំរឿងរូតា ហ្កាន់ដា អង្គជំនុំជម្រះនៃសាលាដំបូងបានច្រានចោលសំណើសុំនៅក្រៅឃុំនេះ ។

១៣) ផ្ទុយទៅវិញ នៅក្នុងសំណុំរឿងប្រាជ្យានីននិងអ្នកផ្សេងទៀត នៅឯសាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវី ជនជាប់ចោទតាលីក បានស្នើសុំដោះលែងខ្លួនគាត់ឲ្យទៅនៅក្នុងផ្ទះក្រុមគ្រួសាររបស់គាត់នៅក្នុងទីក្រុងបាន់ចាលូកា នៅប្រទេសបូស្នៀ និងអ៊ែរហ្សេហ្គូវីន ដើម្បីទទួលបានការព្យាបាល ។ អ្នកជំនាញផ្នែកសុខភាព ដែលរួមមានទាំងមន្ត្រីវេជ្ជសាស្ត្រប្រចាំនៅមន្ទីរឃុំឃាំងបានរាយការណ៍ថា តាលីកមានជំងឺមហារីក ជំងឺមហារីករបស់គាត់គឺ «មិនអាចវះកាត់និងមិនអាចព្យាបាលបានទេ» ហើយគាត់អាចរស់នៅបានយ៉ាងយូរបំផុតប៉ុន្មានខែទៀតប៉ុណ្ណោះ ហើយមិនមានការព្យាបាលវេជ្ជសាស្ត្រណាមួយដែលនឹងអាចធ្វើឲ្យស្ថានភាពជំងឺរបស់គាត់ធូរស្បើយនោះទេ ។ ដោយសារមូលហេតុទាំងនេះ អ្នកជំនាញផ្នែកសុខភាពបានយល់ស្របថា ស្ថានភាពរបស់គាត់គឺមិនសមរម្យសម្រាប់ការស្ថិតនៅក្នុងមន្ទីរឃុំឃាំង ឬសម្រាប់ចូលរួមសវនាការទេ ។ អង្គជំនុំជម្រះនៃសាលាដំបូងបានរកឃើញថា ដោយសារស្ថានភាពរបស់ជនជាប់ចោទមិនអាចព្យាបាលបាននិងថាជនជាប់ចោទទំនងជាមិនអាចនៅមានជីវិតរហូតដល់ចុងបញ្ចប់នៃសវនាការរបស់គាត់ អង្គជំនុំជម្រះនៃសាលាដំបូងមានកាតព្វកិច្ចធ្វើអន្តរាគមន៍មុនពេលដែលគាត់ឈាន «ទៅដល់ការស្លាប់» និងថាការដោះលែងឲ្យនៅក្រៅឃុំដោយគ្មានលក្ខខណ្ឌគឺជារឿងចាំបាច់ ។

១៤) ស្រដៀងគ្នាដែរ នៅក្នុងសំណុំរឿងឌូគី នៅពេលដែលជនជាប់ចោទមានជំងឺ ដែលមិនអាចព្យាបាលបាន ហើយកំពុងស្ថិតនៅក្នុងដំណាក់កាលចុងក្រោយបំផុត អង្គជំនុំជម្រះនៃសាលាដំបូងបានអនុញ្ញាតឲ្យមានការដោះលែងនៅក្រៅឃុំបណ្ដោះអាសន្ន ដោយផ្អែកលើមូលហេតុមនុស្សធម៌ដោយសារ «ស្ថានភាពធ្ងន់ធ្ងរបំផុតនៃលក្ខខណ្ឌសុខភាព» ។

**៣) ការដោះលែងដោយសារមិនអាចចូលរួមសវនាការគឺអាចធ្វើទៅបាននៅពេលដែលជនជាប់ចោទមិនអាចអនុវត្តសិទ្ធិរបស់ខ្លួនយ៉ាងមានប្រសិទ្ធភាពនៅក្នុងសវនាការ**

១៥) នៅពេលជនជាប់ចោទមានបញ្ហាសុខភាពផ្លូវកាយឬផ្លូវចិត្តដែលបានធ្វើឲ្យខូចលទ្ធភាពប្រើប្រាស់យ៉ាងមានប្រសិទ្ធភាពនូវសិទ្ធិរបស់ជនជាប់ចោទនៅក្នុងសវនាការតុលាការអាចសម្រេចថាជនជាប់ចោទមិនអាចចូលរួមសវនាការបាន និងត្រូវដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្ន ។ «បញ្ហាគឺមិនមែនថាតើជនជាប់ចោទមានជំងឺផ្អែកកាយសម្បទា ឬផ្លូវចិត្តនោះទេ ប៉ុន្តែ...ថាតើជនជាប់ចោទនោះអាចអនុវត្តសិទ្ធិរបស់គាត់បានយ៉ាងមានប្រសិទ្ធភាពនៅក្នុងសវនាការប្រឆាំងគាត់ឬទេ» ។ ទំនាក់ទំនងត្រូវតែរកឲ្យបានរវាងការវិភាគលើស្ថានភាពជំងឺផ្សេងៗ និង «ឥទ្ធិពលពិតប្រាកដដែលប៉ះពាល់ដល់លទ្ធភាពផ្សេងៗរបស់ជនជាប់ចោទ» ។

១៦) សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបានកំណត់លទ្ធភាពផ្សេងៗនោះដោយមានបញ្ចូលៈ លទ្ធភាពក្នុងការអះអាងថាខ្លួនមានកំហុសឬអត់យល់អំពីចរិតនៃបទចោទប្រកាន់ យល់អំពីដំណើរការរបស់សវនាការ យល់អំពីភាពពិស្ដារនៃភ័ស្ដុតាង ណែនាំមេធាវី យល់អំពីផលវិបាកនៃសវនាការ និងផ្ដល់សក្ខីភាព ។ បន្ទុកគឺត្រូវធ្លាក់ទៅខាងមេធាវីក្នុងការបង្ហាញដោយ «យោងទៅលើស្ថានភាពប្រហែល» ថា ជនជាប់ចោទគឺមិនអាចចូលរួមក្នុងសវនាការបានទេ ។

១៧) ជាក់ស្ដែង នៅក្នុងសំណុំរឿងស្ដានីហ្ស៊ីក ខាងមេធាវីបានអះអាងថា «ស្ថានភាពសុខភាពរបស់ជនជាប់ចោទ និងជាពិសេសជំងឺពោះវៀនបានធ្វើឲ្យកាយសម្បទារបស់គាត់កាន់តែយ៉ាប់យ៉ឺន ដូច្នេះជំងឺនេះបានធ្វើឲ្យខូចលទ្ធភាពរបស់គាត់ក្នុងការចូលរួមរៀបចំការពារក្ដីយ៉ាងមានអត្ថន័យនៅក្នុងសំណុំរឿងរបស់គាត់» ។ ប៉ុន្តែអង្គជំនុំជម្រះនៃសាលាដំបូងរបស់សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបានរកឃើញថា មិនមានឯកសារវេជ្ជសាស្ត្រណាមួយនៅក្នុងចំណោមឯកសារទាំងបីដែលត្រូវបានដាក់ជូនសាលាជំនុំជម្រះក្ដីដោយខាងមេធាវីបានបង្ហាញដោយយោងទៅលើស្ថានភាពប្រហែលថា ជនជាប់ចោទមិនអាចចូលរួមនៅក្នុងការការពារក្ដីរបស់គាត់ ដូច្នេះឯកសារនេះមិនបានចង្អុលបង្ហាញឲ្យឃើញនៅ «ហេតុផលគ្រប់គ្រាន់» ដែលតម្រូវឲ្យមានការស៊ើបអង្កេតអំពីលទ្ធភាពរបស់ជនជាប់ចោទក្នុងការចូលរួមសវនាការទេ ។

១៨) ផ្ទុយទៅវិញ នៅក្នុងសំណុំរឿងកូវ៉ាសេវី សាលាជំនុំជម្រះក្ដីព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសអតីតយូហ្គោស្លាវីបានពិចារណាថាតើការដោះលែងឲ្យនៅក្រៅឃុំបណ្ដោះអាសន្នអាចធ្វើបានឬទេក្នុងករណីដែលជនជាប់ចោទមានបញ្ហាផ្អែកផ្លូវចិត្ត ។ ខាងមេធាវីបានស្នើសុំឲ្យមានការដោះលែងក្រៅឃុំបណ្ដោះអាសន្នដើម្បីឲ្យជនជាប់ចោទអាចទទួលបានការព្យាបាលនៅក្នុងមន្ទីរពេទ្យឯកទេសផ្លូវចិត្តនៅក្នុងប្រទេសស៊ែរប៊ី និងម៉ុនតេណេហ្គ្រូ ។ របាយការណ៍ពីអ្នកជំនាញពីររូប ដែលតែងតាំងដោយសាលាជំនុំជម្រះក្ដីពីអ្នកជំនាញចិត្តសាស្ត្រមួយរូបដែលតែងតាំងដោយខាងមេធាវីនិងអ្នកចិត្តសាស្ត្ររបស់កន្លែងមន្ទីរឃុំឃាំង ទាំងអស់គ្នាបានបញ្ជាក់ថាជនជាប់ចោទ «មានជំងឺផ្អែកផ្លូវចិត្តយ៉ាងធ្ងន់ធ្ងរដែលបច្ចុប្បន្ននេះធ្វើឲ្យគាត់មិនអាចការពារខ្លួនថាមានកំហុសឬអត់ និងមិនអាចចូលរួមសវនាការ» បាន និងបានឲ្យយោបល់ថា ជនជាប់ចោទត្រូវទទួលបានការព្យាបាលនៅក្នុងមន្ទីរពេទ្យដែលប្រើប្រាស់ភាសាដើមកំណើតរបស់គាត់ ។ ដោយសារមូលហេតុនេះ អង្គជំនុំជម្រះបានដោះលែងជនជាប់ចោទ ។

**៤) លក្ខខណ្ឌនៃការដោះលែងដោយសារមូលហេតុសុខភាពជាទូទៅតម្រូវឲ្យមានការដាក់កំហិតការធ្វើដំណើររបស់ជនជាប់ចោទត្រឹមតែក្នុងបរិវេណមន្ទីរពេទ្យ**

១៩) នៅពេលដែលជនជាប់ចោទត្រូវដោះលែងជាបណ្ដោះអាសន្នដោយសាលាជំនុំជម្រះក្ដីអន្តរជាតិដោយសារមូលហេតុសុខភាព លក្ខខណ្ឌនៃការដោះលែងជាទូទៅត្រូវកំណត់ឲ្យជនជាប់ចោទត្រឹមតែនៅក្នុងមជ្ឈមណ្ឌលព្យាបាលដែលនៅទីនោះជនជាប់

ចោទទទួលបានការព្យាបាល ហើយតម្រូវឲ្យពួកគេត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញបន្ទាប់ពីការព្យាបាលត្រូវបញ្ចប់ ។ ជាក់ស្តែងនៅក្នុងសំណុំរឿងរបស់ ស្រូហ្កា ដែលជនជាប់ចោទត្រូវបានដោះលែងឲ្យទទួលការវះកាត់នៅក្នុងប្រទេសម៉ុនតេណេហ្គ្រូ ជនជាប់ចោទតម្រូវឲ្យ “ស្ថិតនៅតែក្នុងបរិវេណនៃមន្ទីរព្យាបាល....និងកន្លែងថែទាំសុខភាព” និងបន្ទាប់មកត្រូវត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញ ។ ដូចគ្នាដែរនៅក្នុងសំណុំរឿងកូវ៉ាវេវី ដែលជនជាប់ចោទត្រូវបានរកឃើញថាមិនអាចចូលរួមសវនាការបានដោយសារមូលហេតុជំងឺផ្លូវចិត្តធ្ងន់ធ្ងរ អង្គជំនុំជម្រះនៃសាលាដំបូងបានអនុញ្ញាតឲ្យមានការដោះលែងនៅក្រៅឃុំបណ្តោះអាសន្នឲ្យទៅព្យាបាលនៅក្នុងមន្ទីរព្យាបាលជំងឺផ្លូវចិត្តពិសេស ដោយមានដាក់លក្ខខណ្ឌថា ជនជាប់ចោទមិនអាចចាកចេញពីបរិវេណមន្ទីរពេទ្យទេ ។ ជាងនេះទៅទៀត បន្ទាប់ពីរយៈពេល៦ខែ គេតម្រូវឲ្យមានការត្រួតពិនិត្យមើលស្ថានភាពផ្លូវចិត្តរបស់ជនជាប់ចោទម្តងទៀតដើម្បីវាយតម្លៃថាតើស្ថានភាពរបស់ជនជាប់ចោទបានផ្លាស់ប្តូរគ្រប់គ្រាន់សម្រាប់ឲ្យជនជាប់ចោទអាចត្រឡប់មកចូលក្នុងសវនាការវិញ ។ មានតែនៅក្នុងសំណុំរឿងប្រាដ្យា នីន និងអ្នកផ្សេងទៀត និងសំណុំរឿងឌ្យូគី ដែលជនជាប់ចោទត្រូវបានរកឃើញថាមានជំងឺមហារីកដំណាក់កាលចុងក្រោយដែលមិនអាចវះកាត់បាននិងមានជីវិតរស់នៅតែរយៈពេលប៉ុន្មានខែប៉ុណ្ណោះ ដែលការឃុំខ្លួននៅក្នុងផ្ទះត្រូវតុលាការរកឃើញថាសមរម្យ ។

### IV. *សេចក្តីសន្និដ្ឋាន*

(២០) យុត្តិសាស្ត្ររបស់សាលាជំនុំជម្រះក្តីព្រហ្មទណ្ឌអន្តរជាតិស្របៗគ្នាទាក់ទងទៅនឹងការដោះលែងឲ្យនៅក្រៅឃុំផ្អែកទៅលើបញ្ហាសុខភាពគឺតែនៅពេលដែលការព្យាបាលគ្រប់គ្រាន់មិនអាចរកបាន នៅពេលដែលជនជាប់ចោទត្រូវរកឃើញថាមានជំងឺធ្ងន់ធ្ងរដំណាក់កាលចុងក្រោយ និងមានជីវិតរស់នៅតែក្នុងរយៈពេលខ្លី ឬនៅពេលដែលជនជាប់ចោទត្រូវតុលាការរកឃើញថាមិនអាចចូលរួមសវនាការបាន ។ នៅក្នុងករណីរបស់លោក អៀង មិនមានការអះអាងណាមួយដែលថា ស្ថានភាពសុខភាពរបស់គាត់បានរារាំងគាត់មិនឲ្យចូលរួមបានយ៉ាងមានប្រសិទ្ធភាពក្នុងការការពារក្តីរបស់គាត់ និងដែលធ្វើឲ្យគាត់មិនអាចចូលរួមក្នុងសវនាការបាននោះទេ ។ ប្រសិនបើគាត់ត្រូវការការព្យាបាលពិសេសដែលអង្គជំនុំជម្រះវិសាមញ្ញមិនអាចផ្តល់ជូនបាននៅក្នុងកន្លែងឃុំខ្លួន ការដោះលែងដោយកំណត់ឲ្យធ្វើដំណើរត្រឹមតែនៅក្នុងបរិវេណមន្ទីរពេទ្យដើម្បីទទួលបានការព្យាបាលនិងសម្រាប់តែក្នុងរយៈពេលព្យាបាល គឺជារឿងសមរម្យ ។ ប៉ុន្តែប្រសិនបើខាងមេធាវីមិនអាចបង្ហាញថា ស្ថានភាពរបស់លោក អៀង សារី គឺដល់ដំណាក់កាលចុងក្រោយនិងដែលអាចបង្កជាមរណភាពភ្លាមៗទេ លោក អៀង សារី មិនគួរត្រូវដោះលែងបណ្តោះអាសន្នឃុំខ្លួននៅក្នុងផ្ទះរបស់គាត់ដោយសារមូលហេតុសុខភាពតែមួយមុខនោះទេ ។ **អ៊ែន ហាញឌុល**

**ទីប្រឹក្សាច្បាប់មជ្ឈមណ្ឌលឯកសារកម្ពុជា**

# ដំណឹងស្វែងរកឪពុក



ខ្ញុំបាទឈ្មោះ ខូវ ថាបូរិន និងបងប្រុស ខូវ ថាបូរះ ហៅ ដក់ ម្តាយឈ្មោះ ប៉ែន វ៉ាន់ (បានទទួលដំណឹងថាស្លាប់នៅក្នុងរបបប៉ុលពត) សូមប្រកាសស្វែងរកឪពុកឈ្មោះ ម៉ុង ខុន (បច្ចុប្បន្នអាយុប្រហែល៦៨ឆ្នាំ) អតីតទាហានស័ក្តិបួនកន្លះនៅក្នុងរបបសាធារណរដ្ឋខ្មែរនិងពូឈ្មោះ ម៉ុង សាយ មានផ្ទះនៅខាងក្រោយវាំង ។ យើងខ្ញុំទាំងបីបានបែកពីគាត់តាំងពីឆ្នាំ១៩៧៥ ដែលពេលនោះសភាពការណ៍ច្របូកច្របល់ គាត់ក៏បញ្ជូនយើងខ្ញុំទាំងពីរទៅរស់នៅជាមួយជីដូននៅឯភូមិអន្លង់វិល ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង ហើយគាត់ត្រឡប់ធ្វើការនៅភ្នំពេញ ហើយក៏បាត់ដំណឹងរហូត ។ថ្មីៗខ្ញុំបាទបានជួបស្ត្រីម្នាក់ដែលទៅលេងស្រុកកំណើតបានប្រាប់ថាឈ្មោះនេះប្រហែលជាអាចនៅរស់ក្នុងប្រទេសបារាំង ។ គាត់សន្យាថានឹងពឹងមិត្តភក្តិរបស់គាត់ដែលរស់នៅទីនោះឲ្យជួយរកឈ្មោះនេះ ប៉ុន្តែត្រូវរង់ចាំពេលគាត់ត្រឡប់ទៅប្រទេសបារាំងវិញបន្ទាប់ពីការបោះឆ្នោត ។

ដូចបានរៀបរាប់ខាងលើនេះ ប្រសិនបើបងប្អូនញាតិមិត្តណាបានស្គាល់ឬដឹងរស់នៅកន្លែងណា សូមមេត្តាផ្តល់ដំណឹងតាមអាសយដ្ឋានផ្ទះលេខ១២ ផ្លូវ២២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ យើងខ្ញុំទាំងពីរនឹងមានដូនជាសគុណ ។ សូមអរគុណ ។

# ជីវិតពិតឆ្លងកាត់របបខ្មែរក្រហម

**(តចប់)**

**ក្លាយជាអ្នកទោសដោយមិនដឹងខ្លួន**

ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៧៣ ខ្ញុំបានទៅទាក់ទងប្រជាជនភូមិអម្ពិលរៀងឲ្យជួយភ្ជួរដាស់ថ្នាលសាប ។ ត្រឡប់មកដល់ផ្លូវបត់ចូលមន្ទីរ តា ដៃ ស្រ៊ិន ជិះកង់ចេញពីមន្ទីរ គាត់ក៏ឈប់កង់និងផ្តាំខ្ញុំឲ្យចាត់ចែងគម្រោងធ្វើស្រែ ។ ក្រោយមក ដៃ ស្រ៊ិន ត្រូវឈ្លបចាប់ចងស្លាបសេកបណ្តើរឆ្លងកាត់ផ្លូវជាតិលេខ២ដោយ ចោទថាជាខ្មែរយៈពួកបូព៌ា ។

នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៧៣ តំណាងរបស់មន្ទីរវប្បធម៌តំបន់៣៣ បានចុះសួរសុខទុក្ខអង្គភាពយើងដោយភ្ជាប់មកជាមួយលិខិតរបស់ប្រធានវប្បធម៌តំបន់មួយច្បាប់ ប្រាប់ឲ្យបុគ្គលិកនៅមន្ទីរវប្បធម៌ ព្រមទាំងគ្រួសារទៅជួបជុំគ្នានៅមន្ទីរតំបន់ដែលមានទីតាំងនៅស្រុកព្រៃកប្បាស ។ ខ្ញុំនិងភរិយាក៏ជួយដឹកជញ្ជូនកូននិងសម្ភារៈរបស់ប្រពន្ធ ដៃ ស្រ៊ិន ។ វេលាម៉ោង២រសៀល និរសារបាននាំយើងទៅដល់មន្ទីរស្នាក់ការសាខាវប្បធម៌តំបន់ស្ថិតនៅក្នុងភូមិព្រៃឈើទាល ឃុំផ្តៅ ស្រុកព្រៃកប្បាស ។ មន្ទីរបានរៀបចំទទួលបាយនិងកន្លែងស្នាក់នៅបណ្តោះអាសន្ន ។ ព្រឹកឡើងទើបបើកការប្រជុំរៀនសូត្រវគ្គបណ្តុះបណ្តាលនយោបាយ ។ សមមិត្តប្រធានគណៈតំបន់៣៣ ភួង សានិត ឡើងខទ្វេសនាមនិងសំណេះសំណាលជាមួយបុគ្គលិកអង្គភាពយើង ។ រៀនបានមួយសប្តាហ៍ ភួង សានិត ឲ្យខ្ញុំនិង ទិន ណារិន្ទ សរសេរជីវទស្សន៍និងឡើងរាយការណ៍ពីស្ថានភាពដឹកនាំកន្លងមក ។ បន្ទាប់មក ភួង សារិត ប្រធានមន្ទីរវប្បធម៌តំបន់និងជាសមាជិកក្នុងតំបន់៣៣ បានបំបែកអង្គភាពខ្ញុំទាំងក្រុមគ្រួសារនិងកូនចៅឲ្យនៅក្រោមការគ្រប់គ្រងរបស់មន្ទីរតំបន់៣៣ ដោយធ្វើការបែងចែកជា៣សាខាគឺ ទី១ ឃុំបសេដ្ឋ ស្រុក៥៣ ទី២ នៅមន្ទីរសាខាវប្បធម៌តំបន់ភូមិព្រៃឈើទាល និងទី៣ អង្គភាពផលិតកម្មវប្បធម៌តំបន់ស្នាក់ការភូមិកំពែង ឃុំកំពែង ។ ចំណែកខ្ញុំស្នាក់នៅភូមិព្រៃឈើទាល ។ ភួង សានិត ក្នុងមួយសប្តាហ៍មកសម្រាកនៅទីស្នាក់ការមួយយប់ ដើម្បីដើរពិនិត្យការងារវប្បធម៌ចំនួន៦ស្រុកក្នុងតំបន់៣៣ ។ នៅទីនោះ ខ្ញុំមានភារកិច្ចរែកទឹកដាក់ពាង ចិញ្ចឹមជ្រូក រកបន្លែ ហាន់ និងបុកដើមចេក ឲ្យចំណីសត្វ និងដាំដំណាំសម្រាប់ផ្គត់ផ្គង់អង្គភាព ។ បង ណុប ជាលេខាមន្ទីរសរសេររបាយការណ៍ទាំងយប់ទាំងថ្ងៃមិនដែលហ៊ានចេញក្រៅទេ ។ ក្រោយពីហូបបាយខ្ញុំអង្គុយជជែកលេងនិងជួយសរសេររបាយការណ៍រហូតម៉ោង៦ព្រឹកប្រគល់ឲ្យបង ភួង សានិត យកទៅចូលរួមប្រជុំព្រឹកនេះ ។ ម៉ោង៦ល្ងាច ភួង សានិត បានហៅខ្ញុំនឹងបង ណុប មកហូបបាយជុំគ្នារួចប្រាប់ថា៖ សាខន ឯង (ខ្ញុំ) អង្គការតំបន់សម្រេចឲ្យកម្ទេច តែខ្ញុំលើកសំណូមពរឲ្យទុកតាមដាន ព្រោះមិនមែនជារឿងកំហុសបុគ្គល និងប្រាប់ឲ្យខំកសាងខ្លួនថែមទៀត ។ ចាប់ពីថ្ងៃនេះសមមិត្តមានសេរីភាពដើរចេញក្រៅបាន ។ ក្រោយមកសមមិត្តប្រធាននាំខ្ញុំចុះដើរធ្វើការជាមួយគាត់រហូតដល់បសេដ្ឋ និងបានប្រគល់ឯកសារគ្រប់មុខឲ្យខ្ញុំធ្វើនិងគ្រប់គ្រងថ្នាំពេទ្យរបស់តំបន់ ។

**ភូមិបឹងប្រីយ៍**

ដើមឆ្នាំ១៩៧៤ តំបន់៣៣ បានរៀបចំស្នាក់ការនៅវត្តកំពែងស្ថិតក្នុងភូមិកំពែង ដើម្បីប្រមូលកម្លាំងចុះធ្វើស្រែប្រាំងក្នុងឃុំពន្លៃ ព្រៃផ្តៅ រហូតដល់ឃុំអង្គបូរី ។ ខ្ញុំបានស្នាក់នៅជាមួយ ភួង សានិត នៅភូមិព្រៃសំបួរ ឃុំអង្គរបូរី និងបានបង្កើតសិប្បកម្មជាងឈើមួយកន្លែងធ្វើរហាត់ទឹកសម្រាប់ធាក់ទឹកបញ្ចូលស្រែ-ប្រាំង ។ ក្រោយមកគាត់បានចាត់តាំងខ្ញុំឲ្យទៅធ្វើការនៅមន្ទីរវប្បធម៌ស្រុកបរសេដ្ឋវិញ ។ នៅទីនោះមានរោងប្រក់ស្លឹក២ល្វែងភ្ជាប់ដោយជង្រុកស្រូវមួយនិងរោងបាយស្ថិតនៅខាងជើងផ្សារនិងវត្តបរសេដ្ឋ និងមានយុវជន៣នាក់នៅប្រចាំការ ។

ថ្ងៃទី២ ខែមករា ឆ្នាំ១៩៧៥ តំបន់៣៣បានសម្រេចរៀបចំតំបន់ស្វយ័តមួយនៅលើតំបន់ភ្នំ ខាងលិចឃុំផុង ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ស្រុក៥៣ តំបន់៣៣ ។ ម៉ោង៩ព្រឹក បន្ទាប់ពីទទួលបានការចាត់តាំងពី សានិត ខ្ញុំរៀបចំសាក់កាដូ អង្ករ និងត្រីងៀត

ព្រោះយើងត្រូវស្នាក់នៅច្រើនថ្ងៃ ចំពោះតាៗ រៀបចំឆ្នាំងដាំបាយ និងបីដុងទឹក ។ ម៉ោង៤ល្ងាច យើងទៅដល់វត្តផុង និរសារឃុំម្នាក់ជូនដំណើរខ្ញុំឆ្លងកាត់ជ្រោះព្រៃរបោះដែលមានចម្ងាយប្រហែល៣០ គីឡូម៉ែត្រទើបទៅដល់ភូមិបឹងប្រីយ៍ដោយមានឈ្លបឃុំមួយកងហៅយាមការពារ ។ នៅតំបន់ស្វយ័តភូមិបឹងប្រីយ៍ ភួង សានិត ជាគណៈតំបន់ តាដោក អតីតគណៈប្រធានមន្ទីរសាធារណការតំបន់៣៣ ជាប្រធានគណៈកម្មការនិង យឹម សាធ អតីគណៈប្រធានមន្ទីរពាណិជ្ជកម្មតំបន់៣៣ ជាអនុប្រធាន ។

ថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៥ និរសារនៃមន្ទីរតំបន់៣៣ បានមកប្រាប់គណៈកម្មាធិការភូមិស្វយ័តបឹងប្រីយ៍ឲ្យត្រៀមលក្ខណៈទទួលប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ ។ ពេលល្ងាច យើងឃើញក្បួនរទេះគោក្របី និងមនុស្សប្រុសស្រីក្មេងចាស់ជាច្រើនរយនាក់បានមកដល់ភូមិដែលភាគច្រើនមកពីស្រុកថ្ពង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ និងមួយចំនួនមកពីស្រុកកណ្ដាលស្ទឹង ស្រុកដង្កោ និងមុខកំពូល ខេត្តកណ្ដាល ហើយជាគ្រួសារដែលមានប្ដីប្រពន្ធបងប្អូនធ្វើការក្នុងរបប លន់ នល់ ។ រយៈពេលកន្លះខែយើងទទួលបានប្រជាជនជម្លៀសមកជាង២០០គ្រួសារ សរុបជាង ៦០០នាក់ ក្នុងនោះមានប្រជាជនឃុំផុងមួយចំនួនដែលពីមុនធ្លាប់មានលំនៅនៅភូមិបឹងប្រីយ៍ ។

ខែមីនា ឆ្នាំ១៩៧៥ ខ្ញុំដឹកនាំកម្លាំងនារីនិងយុវជនជាង៥០ នាក់ កាប់ឆ្ការដីចម្ការ១០ហិកតាតាមមាត់ស្ទឹង និងបង្កេះភ្នំ ដើម្បីបុកដាំពោតនិងស្រូវចម្ការដោយឆ្លាស់គ្នា ។ កន្លងបានមួយខែយើងចាប់ផ្ដើមអស់ស្បៀងជាបណ្ដើរៗ ព្រោះគ្រួសារជម្លៀសនីមួយៗយកស្បៀងអាហារស្រូវអង្ករមកតិចតួចណាស់ ។ ពេលនោះតំបន់បានចេញលិខិតខ្ទេសនាមឲ្យភូមិស្វយ័តចុះទៅទាក់ទងស្នើសុំស្បៀងពីស្រុកគងពិសី ។

ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំបាននាំក្បួនរទេះគោចំនួន ៣០គ្រឿងទៅដឹកស្រូវដែលសុំបានទៅម្តុំភូមិរលួសខាងជើងវត្តផុង ឃុំផុង ។ ពេលកំពុងកើបស្រូវដាក់រទេះ ខ្ញុំឮវិទ្យុភ្នំពេញផ្សាយថាកងទ័ពរំដោះចូលវាយរំដោះទីក្រុងភ្នំពេញបានទាំងស្រុង ។ ដំណឹងនេះធ្វើឲ្យខ្ញុំនិងប្រជាជនក្នុងភូមិស្រែកអបអរគ្រប់គ្នា ។

**ស្លាប់ដោយអត់អាហារ**

ថ្ងៃទី២៥ ខែឧសភា បន្ទាប់ពីរំដោះបានទីក្រុងភ្នំពេញ ខ្ញុំនិង សានិត មកលេងស្រុកកំណើតនៅឃុំចារ ស្រុកព្រៃកប្បាស ។ ម៉ោង៥ល្ងាចយើងមកដល់ផ្ទះក្នុងភូមិចារសម្រាកមួយយប់ព្រឹកឡើង សានិត បានបបួលខ្ញុំទៅវត្តភ្នំទំពែក ឃុំក្រាំងយ៉ូវ ស្រុកស្អាង ខេត្តកណ្ដាល ដើម្បីស៊ើបសួររកញាតិមិត្តរួចឆ្លងទៅភូមិកោះអន្លង់ចិន ឃុំសិត្បូ ស្រុកស្អាង រកប្រពន្ធគាត់ដែលបែកគ្នាតាំងពីឆ្នាំ១៩៧០ ។ ប៉ុន្តែមិនបានទទួលដំណឹងអ្វីទាំងអស់ សានិត ត្រឡប់ទៅមន្ទីរស្រុកបសេដ្ឋវិញ ។ បន្ទាប់មកបាន ខ្ញុំ និង ឈី(ត្រូវជាប្អូនថ្លៃរបស់សានិត) បានទៅភូមិរីក្សជ័យរួចបងសានិតក៏បានជួបប្រពន្ធគាត់នៅស្រុកកំណើត ។ ថ្ងៃបន្ទាប់ខ្ញុំនិងមិត្តឈីឌុបប្រពន្ធ សានិត ជាមួយកូន២ នាក់ និងសម្ភារៈមួយចំនួនមកស្នាក់នៅផ្ទះខ្ញុំនៅភូមិចារបាន២ យប់ ។ ទើបខ្ញុំទំនាក់ទំនងនិរសារជូនប្រពន្ធនិងកូន៣នាក់ទៅទីស្នាក់ការរបស់ សានិត នៅស្រុកបសេដ្ឋ ។ ចំណែកខ្ញុំឈឺគ្រុនសម្រាកព្យាបាលនៅផ្ទះរយៈមួយសប្តាហ៍ ឮដំណឹងនេះ សានិត និងវឿន និរសារបានមកសួរសុខទុក្ខខ្ញុំ និងផ្ដាំឲ្យខ្ញុំត្រឡប់ទៅអង្គភាពវិញពេលព្យាបាលជា ។ ពេលនេះនៅភូមិបឹងប្រីយ៍ មានមេដឹកនាំ២នាក់គឺ សានិត និង តាដោក ។ ចំណែកក្រុមខ្ញុំមានមនុស្ស៩នាក់រួមទាំង ឈី និងយ៉ែមម្នាក់ទៀត ។

ដើមខែ៩ ឆ្នាំ១៩៧៥ ភូមិបឹងប្រីយ៍មានប្រជាជនជិត ៣០០គ្រួសារសរុបជិត១០០០នាក់ បណ្ដាលឲ្យមានការខ្វះខាតអាហារបរិភោគនិងកើតជំងឺរាក គ្រុនក្ដៅ ហើមជាបន្តបន្ទាប់ ។ ពេលនោះ ប្រជាជនដែលជម្លៀសមកទាំងក្មេងទាំងចាស់ចាប់ផ្ដើមស្លាប់ជាបន្តបន្ទាប់ក្នុងមួយថ្ងៃៗស្លាប់មានពី៤-៥នាក់ ។ នៅពេលនោះ សានិត និងតាដោក ខាងតំបន់អញ្ជើញឲ្យទៅចូលរៀនវគ្គបណ្ដុះបណ្ដាល នយោបាយ ។ ដូចនេះភារកិច្ចគ្រប់គ្រងត្រូវធ្លាក់មកលើខ្ញុំ និង ណុប ជាអ្នកដោះស្រាយជំនួស ។ រំលងបានមួយខែ ប្រជាជនពុំមានអាហារបរិភោគគ្រប់គ្រាន់គួបផ្សំគ្មានថ្នាំពេទ្យសម្រាប់ព្យាបាលបណ្ដាលឲ្យប្រជាជនស្លាប់រហូតដល់១០នាក់ក្នុងមួយថ្ងៃ ។ ចំណែកខ្ញុំក៏ធ្លាក់ខ្លួនឈឺគ្រុនក្ដៅចុកស្មុះដង្ហើម និងសន្ធប់ ។ សានិត ដែលនៅប្រជុំរៀនសូត្របានទាក់ទងថ្នាំពេទ្យពីមន្ទីរតំបន់យកមកឲ្យខ្ញុំលេប និងសាកសួរសុខទុក្ខរួចត្រឡប់ទៅរៀនវិញ ។ ក្រោយមកខ្ញុំបញ្ជាឲ្យប្រជាជនកាប់ពោតលើផ្ទៃដី១ហិកតា សរុបទាំងអស់១០ហិកតា

ដើម្បីយកមកចែកគ្នាស្ងោរហូប ។ ពេលនោះ ណុប បានរាយការណ៍ទៅគណៈតំបន់ចោទថា ខ្ញុំកាន់ជើងខ្មាំងបើកឲ្យប្រជាជនចូលកាច់ពោត ។ រំលងបានមួយថ្ងៃ សានិត និងតាដោក ត្រឡប់មកភូមិបឹងប្រីយ៍វិញ ។ ខ្ញុំបានរៀបរាប់ពីកង្វះខាតខាងជីវភាពដែលបណ្ដាលឲ្យប្រជាជនស្លាប់ជាច្រើន ប៉ុន្ដែខាងតំបន់ណែនាំឲ្យយើងម្ចាស់ការដោះស្រាយផលិតសម្រាប់ផ្គត់ផ្គង់ខ្លួនឯង ។ ក្រោយពីស្ដាប់ការពន្យល់របស់ខ្ញុំចប់សមមិត្តទាំងពីរបានឯកភាពគាំទ្រ និងស្ដីបន្ទោសឲ្យណុបដែលរាយការណ៍ខុស ។

## ត្រឡប់មករស់នៅភូមិកំណើត

ទោះបីបានលេបថ្នាំរួចហើយក្ដី ក៏ជំងឺគ្រុនក្ដៅខ្ញុំតែងរើឡើងវិញជាញឹកញាប់ ។ ឃើញដូចនេះ សានិត និង ដោក បានយកខ្ញុំទៅព្យាបាលនៅមន្ទីរពេទ្យតំបន់៣៣ ។ យុវជន៥នាក់បានលើកខ្ញុំដាក់ក្នុងអង្រឹងសែងទៅកាន់មន្ទីរពេទ្យតំបន់ ។ ម៉ោង១២យប់ខ្ញុំប្រាប់ឲ្យ រី និង វឿន ទៅខ្ចីកង់អ្នក ភូមិដែលធ្លាប់ស្គាល់គ្នាបាន២គ្រឿង ដើម្បីជូនខ្ញុំទៅព្យាបាលនៅផ្ទះវិញព្រោះនៅមន្ទីរពេទ្យមានអ្នកជំងឺច្រើនកំពុងរង់ចាំគ្រូពេទ្យ ។ ម៉ោង៤ភ្លឺ យើងចាកចេញពីមន្ទីរពេទ្យ ហើយមកសម្រាកព្យាបាលនៅផ្ទះម្ដាយក្មេកខ្ញុំ ។ ព្រឹកឡើង រី និង វឿន ត្រូវត្រឡប់ទៅអង្គភាពវិញហើយខ្ញុំផ្ដាំអ្នកទាំងពីរឲ្យជួយលាក់រឿងនេះរួចខ្ញុំសរសេរសំបុត្រផ្ញើឲ្យ សានិត រៀបរាប់ពីសភាពជំងឺធ្ងន់របស់ខ្ញុំដែលមិនអាចត្រឡប់ទៅធ្វើការអង្គភាពវិញ ។ ស្នាក់នៅផ្ទះម្ដាយក្មេកបាន១០ថ្ងៃ ខ្ញុំត្រឡប់មកផ្ទះចាស់នៅភូមិអម្ពិល រួចធ្វើលិខិតក្លែងក្លាយផ្ញើទៅមន្ទីរសង្គមកិច្ចដើម្បីសុំថ្នាំពេទ្យ ។

ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ យាយរបស់ខ្ញុំស្លាប់បន្ទាប់ពីធ្វើបុណ្យសពបាន៣ថ្ងៃប្អូនស្រីនិងប្អូនថ្លៃអតីតប៉ូលិសសម័យ លន់ នល់ ព្រមទាំងកូន២ទៀតត្រូវជម្លៀសឲ្យទៅនៅភូមិភាគពាយ័ព្យ ។

ខែកុម្ភៈ ឆ្នាំ១៩៧៦ អង្គភាពរបស់ខ្ញុំនៅភូមិបឹងប្រីយ៍ត្រូវរំសាយ ខ្ញុំក៏សរសេរលិខិតមួយច្បាប់ផ្ញើជូន ទាវ ទុំ ជា ប្រធានឃុំសុំមករស់នៅមូលដ្ឋានវិញ ។ ពេលនោះខ្ញុំត្រូវចាត់តាំងឲ្យទៅជីកព្រែកលើកប្រឡាយជាមួយបងប្អូនក្នុងភូមិនិងត្រូវមកហូបបាយរួមក្នុងសហករណ៍ ។ រាល់ថ្ងៃខ្ញុំត្រូវធ្វើពលកម្មធ្ងន់ធ្ងរធ្វើឲ្យជំងឺឫសដូងបាតខ្ញុំកាន់តែធ្ងន់ធ្ងរ និងចាប់ផ្ដើមគ្រុនក្ដៅ ។ មេកងក៏ បានអនុញ្ញាតឲ្យខ្ញុំឈប់សម្រាក និងបានផ្លាស់ទៅដាំដំណាំជាមួយកងតាៗវិញ ។ ខ្ញុំមានតួនាទីបណ្ដុះកូនបន្លែនិងដាក់ជីបាញ់ថ្នាំរហូតដំណាំបានផលយកទៅផ្គត់ផ្គង់រោងបាយ ។

## កងដាំដំណាំ

ដើមខែមេសា ឆ្នាំ១៩៧៦ កងដាំបន្លែខ្ញុំត្រូវបញ្ជូនឲ្យទៅបោះទីតាំងនៅខាងត្បូងភ្នំដា ដើម្បីចូលរួមលើកទំនប់ដែលមានជម្រៅ១០ម៉ែត្រនិងបណ្ដោយ១០គីឡូម៉ែត្រ ចាប់ពីឃុំអង្គរបូរីឃុំកំពង់អម្ពិល ដល់ព្រំដែនវៀតណាមដើម្បីការពារទឹកជំនន់រដូវវស្សា ។ ដើមខែមិថុនា ឆ្នាំ១៩៧៦ គណៈកងបានប្រកាសឲ្យក្រុមលើកទំនប់ទាំងអស់ឈប់សម្រាកមួយព្រឹកព្រោះ ហ៊ូ នឹម សមាជិកការិយាល័យនយោបាយមជ្ឈិមបក្សនិងជារដ្ឋមន្ត្រីឃោសនាការចូលរួមធ្វើមីទ្ទីងប្រចាំឆ្នាំ ។ គាត់បានលើកឡើងពីរដ្ឋធម្មនុញ្ញដែលរៀបចំអនុម័តក្នុងពេលថ្មីៗនេះ និងកោតសរសើរដល់បងប្អូនទាំងអស់ដែលខំប្រឹងធ្វើការងារ ។ ក្រោយមកជំងឺគ្រុនក្ដៅខ្ញុំរើម្ដងទៀត ប្រធានកងបានបញ្ជូនខ្ញុំទៅព្យាបាលនៅ មន្ទីរពេទ្យស្រុកដែលមានគ្រូខ្មែរជាអ្នកព្យាបាលនិងផ្សំថ្នាំឲ្យដាំទឹកផឹក ។ ព្យាបាលរយៈពេល១០ថ្ងៃ នៅតែមិនបានធូរស្បើយខ្ញុំក៏ សុំយកថ្នាំទៅដាំផឹកនៅផ្ទះចុងភូមិ ។ បន្ទាប់មកប្រធានកងបានចាត់តាំងឲ្យខ្ញុំចូលក្រុមដាំដំណាំជាមួយក្រុមតាៗវិញសរុបទាំងអស់៣០នាក់ ។

ពាក់កណ្ដាលខែធ្នូ ឆ្នាំ១៩៧៦ ប្រធានភូមិចាត់តាំងខ្ញុំ វិត និងទ្រី ឲ្យទៅដាំដំណាំនៅក្បាលខ្មោច ព្រែកសឿ ស្ថិតក្នុងឃុំពោរំចាក និងឃុំបានកាមព្រំប្រទល់ស្រុកកោះធំ ។ ប្រធានសហករណ៍ឃុំចារបានផ្ដល់អង្ករចំនួន២០កំប៉ុង អំបិល និងប្រហុកមួយចំនួនសម្រាប់ការធ្វើដំណើរនេះ ។ យើងសង់រោងនៅវាលជាប់បឹងដោយកាប់ដើមត្រែងមកក្រៀបធ្វើជញ្ជាំង និងប្រក់ដំបូលរោងដែលមានផ្ទៃដីទទឹង១០០ម៉ែត្រ ។ ថ្ងៃបន្ទាប់យើងត្រួសត្រាយស្មៅ និងរៀបចំបណ្ដុះកូនបន្លែ ល្ពៅ ត្រសក់ ត្រឡាច និងប៉េងប៉ោះ ហើយខ្ញុំចាត់ឲ្យពូទ្រី ជាអ្នកដាំបន្លែ ចំណែក វិត ជាអ្នករកត្រី ។ ខែកុម្ភៈឆ្នាំ១៩៧៧ ខ្ញុំទទួលសំបុត្ររបស់ ទាវ ទុំ ឲ្យខ្ញុំ និងវិតត្រឡប់មកសហករណ៍វិញ ។ យើងទាំងពីរធ្វើដំណើរទៅឃុំចារម៉ោង៩យប់ ព្រឹកឡើងខ្ញុំបានទៅជួបគាត់នៅឯផ្ទះ ។ គាត់បានហុចសៀវភៅធំមួយក្បាលសៀវភៅតូច៣ក្បាល ប៊ិច៣ដើម និងបន្ទាត់មួយ ដោយប្រាប់ខ្ញុំ

ថា៖ មិត្តឯងត្រូវដើរស្រង់ប្រវត្តិរូបកម្មាភិបាលតាំងពីកងវរៈ កងរយ កងហា រហូតគណៈភូមិដែលមានឈ្មោះក្នុងសៀវភៅនេះ ធ្វើយ៉ាងណាកុំឲ្យម្ចាស់ប្រវត្តិរូបដឹងខ្លួនមុន ហើយរយៈពេល១-២ថ្ងៃត្រូវប្រមូលឲ្យគាត់មួង ។ ថ្ងៃដំបូងខ្ញុំធ្វើនៅភូមិអំពិល មេកង មេភូមិ៤នាក់ រួចក៏យកមកប្រគល់ឲ្យ ទាវ ទុំ ពិនិត្យ ។ បន្ទាប់មកគាត់ក៏ណែនាំឲ្យស្រាវជ្រាវប្រវត្តិសមមិត្តនារី ភឹម យ៉ុម ជាប្រធាននារីឃុំ ។ ខ្ញុំក៏ចុះទៅភូមិបាំងបាត់ ជួបឪពុកនារី យ៉ុម ផ្ទាល់តែផ្តល់ព័ត៌មានមិនច្បាស់ ខ្ញុំបានសួរមិត្តនារី ភន ជាប្អូនបង្កើតបានផ្តល់ព័ត៌មានច្បាស់លាស់ ដែលយើងចង់បាន ។ ក្រោយមកខ្ញុំចេះតែដើរស្រាវជ្រាវអ្នកផ្សេងៗទៀតដែលនៅសេសសល់ ។ រយៈពេលកន្លះខែក្រោយមកប្រធានឃុំបានបង្កើតអង្គភាពដាំដំណាំរួមនៅម្តុំវត្តចារ រួចចាត់តាំងខ្ញុំអ្នកបច្ចេកទេស ។ ក្រុមយើងបានភ្ជួរដីលើករងធ្វើជាប្រឡាយបាចទឹកចូល ដាំសណ្តែកកួររហូតចេញកួរបេះយកទៅផ្គត់ផ្គង់រោងបាយនៅសល់ចែកតាមសហករណ៍ និងយកទៅឲ្យមិត្ត ដាំ ជាគណៈឃុំថ្មី និងមិត្ត ទុំ ជាអនុឃុំ ។

## មរណភាពរបស់ប្រពន្ធខ្ញុំ

ខែមេសា ឆ្នាំ១៩៧៧ ប្រពន្ធខ្ញុំដែលទើបសម្រាលកូនប្រុសបាន២ខែ ត្រូវគណៈកងនារីឲ្យចុះធ្វើការនៅមូលដ្ឋានដូចជា ដកស្ទូងស្រូវនិងបេះបន្លែមកផ្គត់ផ្គង់រោងបាយបណ្តាលឲ្យឈឺទាស់គ្មានទឹកដោះសម្រាប់កូនបៅ ។ ចំណែកកូនប្រុសខ្ញុំចាប់ផ្តើមរាកមួលគណៈកងក៏បញ្ជូនមកព្យាបាលនៅពេទ្យឃុំចារបានមួយរយៈបញ្ជូនបន្តទៅព្យាបាលនៅពេទ្យស្រុក ។ រយៈពេលមួយសប្តាហ៍រវល់មើលថែទាំកូនប្រពន្ធខ្ញុំក៏ចាប់ផ្តើមធ្លាក់ខ្លួនឈឺរាក និងហើមជើងដោយសារដេកមិនបានគ្រប់គ្រាន់និងគ្មានអាហារបរិភោគ ។ ឆ្លៀតពេលថ្ងៃសម្រាកពីការងារខ្ញុំតែងតែទៅសួរសុខទុក្ខ និងវេចម្ហូបពីកងដំណាំដែលតាៗលាក់ទុកយកទៅឲ្យប្រពន្ធខ្ញុំ ។ ដោយអស់លទ្ធភាពព្យាបាលប្រពន្ធខ្ញុំក៏ស្លាប់ចំណែកកូន បងស្រីខ្ញុំជាអ្នកមើលថែជំនួស ។

## ចោទថាខ្មាំង

រាល់ថ្ងៃដោយសារពុំមានអាហារបរិភោគគ្រប់គ្រាន់នៅក្នុងភូមិក្មេងនាំគ្នាលួចកាប់អំពៅដកដំឡូង បេះផ្លែឈើ រហូតមានពាក្យចោទថា៖ រូបខ្ញុំ និងមិត្ត ហ៊ឹម ជាអ្នកបង្កើតឲ្យមានចោរនៅក្នុងភូមិ ។ ប្រធានភូមិបានលើកឡើងក្នុងអង្គប្រជុំ ប៉ុន្តែប្រធានកងខ្ញុំបានបដិសេធដោយសារខ្ញុំមិនដែលដើរចេញពីចម្ការ ។ ក្រោយពីបញ្ចប់ភារកិច្ចដាំដំណាំ គណៈកងបានចាត់តាំងឲ្យខ្ញុំពង្រាបដីទួលដាំដើមចេកវិញ ។ ថ្ងៃមួយពេលខ្ញុំត្រឡប់មកផ្ទះឃើញរបស់របរខោអាវនៅរាយប៉ាយពេញផ្ទះនិងបាត់របស់មួយចំនួន ។ ពេលដើរទៅសហករណ៍ឃើញតាៗកំពុងហែកវេចនានុក្រមមួរបារីដក់ខ្ញុំបានស្នើសុំយកមកវិញ ប៉ុន្តែពួកគេចោទថា ខ្ញុំមានគំនិតអភិរក្សនិយមរក្សាទុករបស់ខ្មាំងបដិវត្តន៍ ។ ខ្ញុំបានជម្រាបសមមិត្ត យ៉ េ ជាប្រធានភូមិ គាត់បានណែនាំប្រធានរោងបាយឈប់ទៅយកសៀវភៅទៅប្លុកដាសស្នាមពីផ្ទះខ្ញុំព្រោះមានឯកសារនិងបញ្ជីខ្លះគាត់ផ្ញើនៅនឹងខ្ញុំ ។

ខែវិច្ឆិកា ឆ្នាំ១៩៧៧ ពេលកំពុងហូបបបរក្នុងរោងបាយ ខ្ញុំឃើញនារីម្នាក់កំពុងអង្គុយក្តួតចង្កេះមុខរោងបាយរួចដើរមកសុំបិលប្រធានចុងភៅឈ្មោះ ប៉េង ។ ប៉ុន្តែមិនត្រឹមមិនឲ្យអំបិលនារី ប៉េង បានជេរប្រទេចថែមទៀត ។ ឮសម្តីនេះខ្ញុំក៏តបវិញថា គ្នាគ្រាន់តែសុំអំបិលម្តេចបងបន្ទោសឲ្យគាត់ មិនបានសុំត្រីអាំងឬសាច់មាន់លីងពីបងឯណា ។ ប៉េង ស្តាប់រួចដើរចូលទៅក្នុងបន្ទប់រោងបាយខាងក្រោយ មួយសន្ទុះប្រធានសហករណ៍ សេក ប៊ិន ចេញពីក្នុងបន្ទប់មកឈរច្រត់ចង្កេះពីក្រោយខ្នងខ្ញុំរួចនិយាយខ្លាំងៗសំដៅមកខ្ញុំថា៖ ចាំបាច់រកឯណាខ្មាំងប្រឆាំងសហករណ៍ ។ ឮពាក្យនេះ ខ្ញុំក៏រុញចានបបរចេញពីមុខដើរទៅអង្គុយក្រោមផ្ទះ ។ ម៉ោង១២កន្លះថ្ងៃត្រង់ខ្ញុំឃើញមិត្ត យ៉េ ជិះកង់ចូលមកដល់រួចប្រកាសឲ្យបងប្អូនចូលមករោងទាំងអស់គ្នាដែលមានអ្នកខ្លះពុំទាន់ហូបបបររួចផងខ្ញុំក៏ដើរចូលទៅរោងបាយ ។ ពេលនោះ យ៉េ ឡើងនិយាយអំពីសភាពការណ៍នៃបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ និង គោលនយោបាយរៀបចំសហករណ៍បាយរួម ។ បន្ទាប់មកគាត់ឲ្យខ្ញុំឡើងមានយោបល់ពេលនោះខ្ញុំលើកយកការដឹកនាំរបស់អង្គការបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យថា៖ មានតែអង្គការមួយគត់ដែលដឹកនាំប្រទេសបានសម្រេចជោគជ័យលើគ្រប់វិស័យឆ្លៀតពេលនោះខ្ញុំក៏លើករឿងមិត្ត ប៊ិន ដែលមកពោលពាក្យចោទ «ខ្មាំងប្រឆាំងនឹងសហករណ៍» ។ ខ្ញុំនិយាយចប់ ទុំ ប្រកាសបិទអង្គប្រជុំដោយមិននិយាយអ្វីទាំងអស់ បន្ទាប់មកគាត់ជិះកង់វិលទៅភូមិចារវិញ ។

## អង្គការផ្សំផ្គុំឲ្យមានគូស្រករ

នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ១៩៧៨ វេលាម៉ោង៣រសៀល

សមមិត្ត វង់ ប្រធានសហករណ៍ភូមិចារទៅប្រាប់បង យ៉េ ប្រធានភូមិអម្ពិលបាននាំខ្ញុំទៅរៀបការ ។ ទៅដល់សហករណ៍ភូមិចារខ្ញុំឃើញមានរៀបកៅអីជាជួរចំនួន៦ ទើបខ្ញុំដឹងថាមង្គលការនេះមាន៣គូ ។ យ៉ុម និង យ៉េ តំណាងឲ្យ អង្គការឃុំអង្គុយចំពីមុខ ។ ដំបូង យ៉េ ឡើងប្រកាសកម្មវិធីនិងប្រកាសហេតុពីការរៀបចំថ្មីរួចហើយប្រកាសឈ្មោះសាមីខ្លួនទាំង៣ដែលសុទ្ធតែពោះម៉ាយនិងមេម៉ាយ ។ ក្រោយពីប្រកាសចប់នារី យ៉ុម ឡើងមានមតិអំពីគោលនយោបាយរបស់បក្សក្នុងការរៀបចំគ្រួសារបែបលក្ខណៈទំនើបរបស់បដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ ។ បន្ទាប់មកសាមីខ្លួនទាំង៦នាក់ឡើងចាប់អារម្មណ៍និងប្តេជ្ញាចិត្តម្តងម្នាក់ៗ និងតំណាងឪពុកម្តាយចុងក្រោយហើយប្រកាសបិទកម្មវិធី ។ ក្រោយពីចប់កម្មវិធីខ្ញុំនិងបងប្អូនប្រមាណ១០នាក់ទៅលេងផ្ទះម្តាយក្មេកខ្ញុំ ។ ពេលឃើញខោអាវរបស់ខ្ញុំរហែកនាងក៏ទៅបើកហិបយកអាវខ្មៅដៃវែងមួយនិងខោខ្មៅជើងវែងមួយឲ្យផ្លាស់ ។ វេលាម៉ោង៤ភ្លឺ ខ្ញុំត្រឡប់មកធ្វើការនៅកងបោកស្រូវភូមិអម្ពិលវិញ ម៉ោង៣រសៀលខ្ញុំខ្ចីបានកង់មួយពីរោងសហករណ៍ឌុបប្រពន្ធ ខ្ញុំមករស់នៅភូមិអម្ពិលវិញ ។

ដើមឆ្នាំ១៩៧៨ប្រជាជនថ្មីដែលជម្លៀសមកពីតំបន់ផ្សេងប្រមាណ១០រទេះគោ ត្រូវអង្គការយកទៅសម្លាប់នៅទួលបាញ់អង្កុញ និងទួលភូមិក្តីដោយប្រាប់ថាបញ្ជូនឲ្យទៅរស់នៅស្រុកកំណើតវិញ ។ ពេលខ្លះមាននារី ឈួន គណៈកងនារី អ៊ាង និង ប៉ោក ជាប្រធានឈ្លបឃុំ បានមកអួតអាងពីការសម្លាប់មនុស្សនៅរោងបាយសហករណ៍ ។ ក្នុងនោះវត្តចារ វត្តធម្មវិន័យ វត្តព្រៃល្វា និងមន្ទីរពេទ្យស្រុកក៏ជាកន្លែងសម្លាប់ មនុស្សប្រមាណ៧០០នាក់ ។

ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ម៉ោង១២យប់ ខ្ញុំឃើញមានទាហានបាក់ទ័ពនិងមានប្រជាជនភៀសខ្លួនជាច្រើននៅខាងកើតទន្លេក្នុងស្រុកស្អាង និងស្រុកកោះធំ ។ ពេលនោះ ខ្ញុំបបួលបងប្អូននៅសហករណ៍ត្រឡប់មកផ្ទះវិញ ។ ថ្ងៃទី១៦ ប្រពន្ធខ្ញុំកើតបានកូនស្រីម្នាក់ ៗបងថ្លៃខ្ញុំក្រាលចំបើងលើរទេះរួចលើកប្រពន្ធ ខ្ញុំឲ្យជិះយើងជម្លៀសទៅនៅភូមិបាំងបាត់ដើម្បីគេចចេញពីគ្រាប់ផ្លោង ។

នៅថ្ងៃ២៨ ខែមករា ឆ្នាំ១៩៧៩ យើងនាំគ្នាទឹមរទេះបរមកផ្លូវថ្នល់ជាតិ ក៏ជួបក្បួនរថយន្តកងទ័ពវៀតណាមតាមបណ្តោយផ្លូវជាតិលេខ២ពីទិសកើតទៅលិច ។ ខ្ញុំនិងបងប្អូនក៏សម្រេចចិត្តចូលមករស់នៅក្នុងភូមិវិញ ។ ថ្ងៃទី២២ ខែកុម្ភៈអង្គប្រជុំមួយបានបើកឡើងនៅរោងសហករណ៍ភូមិចារលោក មុល តុន ត្រូវបានជ្រើសតាំងជាប្រធានឃុំ ចំណែកខ្ញុំទទួលបន្ទុកឃោសនាចាត់តាំងដែលជាសេនាធិការឲ្យលោកប្រធាន ។ យើងបានបង្កើតក្រុមសាមគ្គីបង្កបង្កើនផលមួយក្រុមចាប់ពី១០ទៅ ១៥គ្រួសារ ហើយចែកចេញជាមនុស្សពេញកម្លាំងពលកម្មអ្នកមានប្តីប្រពន្ធ មេម៉ាយ ក្មេងកំព្រានិងពិការ ។ទោះបីជាយ៉ាងនេះក្តីក៏ប្រជាជននៅតែជួបប្រទះកង្វះខាតស្បៀងដដែល ។ ដូច្នេះនៅតាមអង្គភាពស្នាក់ការឃុំយើងយកឆ្នាំងខ្ទះធំៗសម្រាប់ស្ងោរពោតចែកគ្នាហូបជាមួយអំបិលនិងឆៃប៉ូវ ។ ពេលខ្លះកងទ័ពវៀតណាមក៏បានផ្តល់ជាអង្ករ មេ្សៅមី គ្រាប់ពោតស្ករស ដល់អ្នកភូមិយើងខ្លះដែរ ។

នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៨៩ ខ្ញុំត្រូវបានផ្ទេរការងារទៅធ្វើការនៅការិយាល័យចំណុះឲ្យមន្ទីរស្រុកព្រែកប្បាសទទួលភារៈប្រធានការិយាល័យឃោសនាការនិងព័ត៌មានព្រោះមានភាពស្ទុកស្ទាញចំពោះការងារឃុំដោយសាររើសកងទ័ពហើយក្រោយមកខ្ញុំក៏សុំសម្រាកពីការងារមួយរយៈ ។ ចាប់ពីឆ្នាំ១៩៩៣ ខ្ញុំចូលធ្វើជាប្រធានការិយាល័យព័ត៌មានស្រុកព្រែកប្បាស រហូតដល់ថ្ងៃទី១ ខែតុលា ឆ្នាំ១៩៩៩ ទើបខ្ញុំចូលនិវត្តន៍មកប្រកបមុខរបរលក់ដូរនិងធ្វើស្រែចម្ការវិញ ។

**សាន្ត សុខ**

# ដំណឹងស្វែងរកកូន

ខ្ញុំបាទឈ្មោះ គឹម ហេង ភេទប្រុស អាយុ៨៣ឆ្នាំ (ត្រូវជាឪពុក) បច្ចុប្បន្នរស់នៅភូមិស្វាយចេក ឃុំតាត្រាវ ស្រុកអង្គរធំ ខេត្តសៀមរាប សូមសួររកកូនឈ្មោះ ហេង ហួយ ធ្លាប់រៀនដល់ថ្នាក់ទី១២សង្គមចាស់ ។ នៅឆ្នាំ១៩៧៥ ហួយ ត្រូវបញ្ជូនទៅធ្វើការនៅតាមផ្លូវជាតិលេខ៦អា (ភ្នំពេញ) ។ មួយរយៈក្រោយមក ហួយបានផ្លាស់មកធ្វើការនៅខេត្តសៀមរាបវិញ ។

ប្រសិនបើបងប្អូនញាតិមិត្តណាបានស្គាល់ឬដឹងរស់នៅកន្លែងណា សូមមេត្តាផ្តល់ដំណឹងមកមជ្ឈមណ្ឌលឯកសារកម្ពុជា ទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ជំរើជីវិតក្នុងរបបខាលពិឃាដ

ខ្ញុំជាកសិករនៅភូមិព្រៃថ្នាំង ឃុំក្រាំងអំពិល ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ ។ ខ្ញុំជាកូនពៅក្នុងចំណោមបងប្អូនប្រាំបីនាក់ ស្លាប់ពីរនាក់ ។ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ខ្ញុំត្រូវខ្មែរក្រហមជម្លៀសទៅភូមិ៤ ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ដែលជាតំបន់ដាច់ស្រយាល ។ ក្រុមគ្រួសាររបស់ខ្ញុំជួបការលំបាកវេទនាគ្រប់បែបយ៉ាងទោះបីយើងជាកសិករក៏ដោយ ។ បងស្រីខ្ញុំម្នាក់ឈ្មោះ ប៉ាង សាម៉ុន មានប្តីឈ្មោះ ស៊ីវ សុភី បានរៀបការសម័យលន់ នល់ មានកូនស្រីឈ្មោះ សៀង ចាន់ធី អាយុ២ឆ្នាំ ។ ឆ្នាំ១៩៧៧ បងថ្លៃរបស់ខ្ញុំត្រូវអង្គការចាត់តាំងឲ្យឃ្វាលក្របីនិងភ្ជួររាស់ដីធ្វើស្រែ ។ ថ្ងៃមួយពេលកំពុងភ្ជួរស្រាប់តែក្របីដេក បងថ្លៃរបស់ខ្ញុំក៏យកទម្ពក់វនាស់វាយឲ្យដើរទៅមុខ ពេលនោះ ញ៉ាញ់ បានចោទបងថ្លៃខ្ញុំថា ខ្មាំងប្រឆាំងអង្គការ ។ ញ៉ាញ់ បានបញ្ជាឲ្យឈ្លបហៅបងថ្លៃខ្ញុំទៅដោយប្រាប់ថា ទៅមើលប្រពន្ធសម្រាលបានកូនប្រុសមួយនៅមន្ទីរពេទ្យ ឃុំព្រៃក្មេង តំបន់ក្បាលដំរី ។ ពេលនោះបងថ្លៃដឹងខ្លួនថា ប្រាកដជាស្លាប់ ព្រោះនៅក្នុងក្រុមតែងតែបាត់មនុស្សជាបន្តបន្ទាប់ ។ ពេលឈ្លបបណ្តើរបងថ្លៃខ្ញុំដល់ដើមឈើធំមួយដែលមានព្រៃដុះព័ទ្ធជុំវិញ បងថ្លៃក៏ក្រាញឱបនឹងដើមឈើជាប់មិនព្រមដើរទៅមុខទៀតទោះបីជាវាយដំយ៉ាងណាក្តី ឈ្លបក៏បានសម្លាប់បងថ្លៃខ្ញុំនៅទីនោះតែម្តង បន្ទាប់មកឈ្លបក៏ទៅប្រាប់ បងស្រីខ្ញុំដែលកំពុងមានជំងឺឲ្យចេញពីមន្ទីរពេទ្យដោយប្រាប់ថាប្តីនៅរង់ចាំទទួល រួចក៏បណ្តើរបងស្រីខ្ញុំដែលបីកូនខ្ចីនៅក្នុងដៃជាមួយក្មួយស្រីខ្ញុំដែលមានរូបរាងស្គមស្គាំងនិងមានជំងឺទៅទៀតផង ។ ដោយសារ ក្មួយស្រីខ្ញុំមិនអាចដើរបានឆ្ងាយ ឈ្លបក៏សម្លាប់បងស្រីនៅក្បែរមន្ទីរពេទ្យ ហើយទុកក្មួយខ្ញុំទាំងពីរនាក់ចោលនៅទីនោះ ។ ចំណែកម្តាយ របស់ខ្ញុំតែងតែទន្ទឹងមើលផ្លូវបងស្រីខ្ញុំត្រឡប់មកផ្ទះវិញ ក្រោយមកគាត់ក៏បានទទួលដំណឹងពីអ្នកដើររកឬសឈើធ្វើថ្នាំប្រាប់ថា បងស្រីត្រូវឈ្លបយកទៅសម្លាប់បាត់ហើយ ។ ចាប់តាំងពីថ្ងៃនោះមក រាល់ពេលត្រឡប់មកពីធ្វើការម្តងៗ ម្តាយរបស់ខ្ញុំតែងតែអង្គុយយំនិងមិនព្រមបរិភោគអាហារ ។ ឪពុកខ្ញុំតែងតែលួងលោមគាត់ឲ្យកាត់ចិត្ត ព្រោះបារម្ភគ្មានកម្លាំងធ្វើការ ហើយត្រូវអង្គការចោទថា ក្បត់ទៀត ។ ឆ្នាំ១៩៧៩ ម្តាយរបស់ខ្ញុំចាប់ផ្តើមធ្លាក់ខ្លួនឈឺបាក់កម្លាំងរហូតទទួលមរណភាព ចំណែកឪពុករបស់ខ្ញុំក៏ចូលបួសជាព្រះសង្ឃ ដើម្បីឧទ្ទិសដល់វិញ្ញាណក្ខន្ធប្រពន្ធនិងកូនចៅដែលបានស្លាប់យ៉ាងវេទនា ។ មិនយូរប៉ុន្មានគាត់ក៏ទទួលអនិច្ចកម្មទៀត ទុកឲ្យបងប្អូនខ្ញុំទាំងប្រាំមួយនាក់រស់នៅជាកូនកំព្រារហូតមកដល់សព្វថ្ងៃ ។

ខ្ញុំសូមជូនដំណឹងនេះដល់លោកនាយកស្ថាប័ន ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះក្នុងរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ ។ ខ្ញុំក៏សូមអំពាវនាវដល់អង្គការសហប្រជាជាតិឲ្យជួយឃ្លាំមើលបណ្តាប្រទេសជាសមាជិកនិងប្រជាជនដែលស្រលាញ់យុត្តិធម៌និងឲ្យលោកជ្រាបពីទុក្ខវេទនារបស់ប្រជាជនកម្ពុជាក្នុងរបបនោះ ដើម្បីធ្វើយ៉ាងណានាំមេដឹកនាំខ្មែរក្រហមមកផ្តន្ទាទោសចំពោះមុខជនរងគ្រោះដែលទន្ទឹងរង់ចាំអស់រយៈពេលជាង៣ទសវត្សរ៍មកហើយ ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អង្គការសហប្រជាជាតិដែលបានខិតខំប្រឹងប្រែងបង្កើតឲ្យមានសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម និងនាំយកយុត្តិធម៌ជូនជនរងគ្រោះ ។ ពិសេសសូមថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលបានខិតខំស្រាវជ្រាវប្រមូលឯកសារ និងភ័ស្តុតាងទាក់ទងទៅនឹងរបបវាលពិឃាដនេះព្រមទាំងថ្លែងអំណរគុណដល់អ្នកដែលបានរួមចំណែកបង្កើតឲ្យមានកម្មវិធីដ៏មានសារសំខាន់សម្រាប់មនុស្សជាតិ ។ **ប៉ាង ឆន**

## ពាក្យស្លោកខ្មែរក្រហម

**◆ ពង្រីកពង្រីក សហភាព ខណ្ឌអធន គ្រប់ផ្នែក សតិអារម្មណ៍ ចាត់តាំង សេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច វិទ្យាសាស្ត្រ ឱ្យខ្លាំងក្លា ថ្លាលទ្រៅជានិច្ច រៀងរហូតទៅជាស្ថាពរ។**

**(ដកស្រង់ចេញពីសៀវភៅលេខ៦៦)**







ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 99, March 2008 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.